វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
*Working Together for Positive Change*

# ការចិញ្ចឹមជីវិតដោយពឹងផ្អែកលើទន្លេមេគង្គ

## របាយការណ៍ការសិក្សាស្រាវជ្រាវនៅស្រុកសំបូរ



ភ្នំពេញ កម្ពុជា
ខែមេសា ឆ្នាំ២០១២

# ការចិញ្ចឹមជីវិតដោយពឹងផ្អែកលើទន្លេមេគង្គ
# របាយការណ៍ការសិក្សាស្រាវជ្រាវនៅស្រុកសំបូរ

ការបោះពុម្ពផ្សាយនេះអាចធ្វើការដកស្រង់ចេញមួយផ្នែកក្នុងគោលបំណងផ្តល់ឱ្យនូវប្រភពចំណេះដឹងយ៉ាងពេញលេញ

កាលបរិច្ឆេទបោះពុម្ព:   ខែមេសា ឆ្នាំ២០១២

បោះពុម្ពដោយ:   វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
កម្មវិធីបរិស្ថាន
គម្រោងសិទ្ធិសហគមន៍ និង ទំនប់វារីអគ្គិសនី

រចនាអត្ថបទដោយ: លោក ភួន យូ មន្ត្រីព័ត៌មាន និង ការបោះពុម្ពផ្សាយ

**សម្ព័ន្ធទន្លេកម្ពុជា** សហការជាមួយ **វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

គ្រប់រូបភាពដែលបានប្រើប្រាស់សម្រាប់ការបោះពុម្ពបានផ្តល់ជូនដោយអង្គការអុកស្វាមអូស្ត្រាលី ហើយថតដោយលោក ហ្លេន ដាញ៉ែល (Glenn Daniels) និង ម៉ាណា ហ្គាំ (Manna Gum) និងលើកលែងតែរូបភាពមួយចំនួន ដែលបានបញ្ជាក់។

## ការប្រកាសបដិសេធ

របាយការណ៍នេះត្រូវបានរៀបចំសម្រាប់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និង សម្ព័ន្ធទន្លេកម្ពុជា។ ទស្សនៈនិងគំនិតដែលបានលើកឡើងក្នុងអត្ថបទនេះ វាជាលទ្ធផលរបស់អ្នកស្រាវជ្រាវតែមួយគត់ វាមិនមែនជាគំនិត ឬទស្សនៈដែលលើកឡើងដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ឬ សម្ព័ន្ធទន្លេកម្ពុជា ឬសមាជិកណាមួយរបស់អង្គការទាំងពីរខាងលើនោះទេ។

**©វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

# អ្នកនិពន្ធ/អ្នកសិក្សាស្រាវជ្រាវ

**អេសស្តេឡា អេសស្តូរៀ** បាន និងកំពុងធ្វើការងារលើផ្នែកអភិវឌ្ឍន៍ជាង១៥ឆ្នាំមកហើយ។ ជាអ្នកចូលរួមយ៉ាងសកម្មលើយុទ្ធនាការការងារតស៊ូមតិនៅសហគមន៍មូលដ្ឋានក្នុងប្រទេសហ្វីលីពីន។ អេសស្តេឡា អេសស្តូរៀ ក៏បានធ្វើការផងដែរជាមួយសហគមន៍ជនជាតិដើមភាគតិច នៅខេត្តរតនគិរីក្នុងប្រទេសកម្ពុជា ដើម្បីឆ្ពោះទៅរកកំណែទំរង់ប្រព័ន្ធវិម្ឋការ និងវិសហម្ឋការក្នុងភាពជាដៃគូសម្រាប់អភិបាលកិច្ចក្នុងតំបន់។ នៅកំឡុងពេល ដែលនាងធ្វើការជាមួយអង្គការអុកស្វាមអាមេរិច ដែលមានការិយាល័យ នៅតំបន់អាស៊ីអាគ្នេយ៍ ក្នុងប្រទេសកម្ពុជា អេសស្តេឡា អេសស្តូរៀ បានចូលរួមយ៉ាងមោះមុត ជាមួយបណ្តាញសង្គមស៊ីវិល គោល-នយោបាយតស៊ូមតិ ការឃោសនា និងគ្រប់គ្រងការផ្តល់ជំនួយស្តីពីបញ្ហានៅតាមដងទន្លេមេគង្គ។ អេសស្តេឡា អេសស្តូរៀ បានទទួលសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកផ្សព្វផ្សាយនៅតាមតំបន់ជនបទ និងបង្រៀននៅមហាវិទ្យាល័យកសិកម្មអន្តរជាតិ ឡាវិនស៊ីន ហើយបានបញ្ចប់អនុបណ្ឌិត និងកំពុងបន្តថ្នាក់បណ្ឌិតផ្នែកទស្សនៈវិជ្ជានៅសាកលវិទ្យាល័យឃ្វីនឡែន Queensland ប្រទេសអូស្ត្រាលី។ ពេលបច្ចុប្បន្ននាង គឺជាមន្ត្រីគម្រោងនៃគម្រោងជនភាសខ្លួន និងជនផ្លាស់ប្តូរទីលំនៅមិននិយាយអង់គ្លេសនៃមហាវិទ្យាល័យឃ្វីនឡែន Queensland ភាគខាងត្បូង និងជាមជ្ឈមណ្ឌលវប្បធម៌ចំរុះនៃប្រទេសអូស្ត្រាលី។

ម.ឯ.ឯ.ក AIDOC
Code: 139-037
Date:
Donated by:

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះបានរៀបចំដោយ អេសស្តេឡា អេសស្តូរៀ សហការណ៍ជាមួយសមាជិកសម្ព័ន្ធទន្លេកម្ពុជា (RCC) និងការសហការសម្របសម្រួល និងគាំទ្រជាពិសេសពី វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia) អង្គការអុកស្វាមអូស្ត្រាលី (Oxfam Australia) និងសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រធានភូមិ និងអ្នកដែលចូលរួមដឹកនាំក្រុម ដើម្បីធ្វើការសម្ភាសន៍ជាមួយប្រជាពលរដ្ឋ ដែលមកពីភូមិទាំង៦។ ហើយក៏សូមអរគុណចំពោះការគាំទ្រពីក្រុមការងារអង្គការ អុកស្វាមអូស្ត្រាលី ខេត្តក្រចេះ ដែលមាន លោក ឈួន ឡា និង លោក សំ សុវណ្ណ និងក្រុមការងាររបស់គាត់ ដែលបានជួយដល់អ្នកស្រាវជ្រាវនៅកំឡុងពេលធ្វើការសិក្សានៅតំបន់គោលដៅ និង ការរៀបចំសិក្ខាសាលាបង្ហាញពីលទ្ធផល។

ក្រៅពីនេះក៏សូមអគុណផងដែរដល់ក្រុមការងារផ្សេងទៀតដូចជា លោកស្រី ជា ផល្លីកា លោក តុន គុន្ធែល និង កញ្ញា អាមី ត្រេនឌិម។ ហើយអគុណផងដែរ ចំពោះការគាំទ្ររបស់បណ្ឌិត កាល់ មីដលតុន និង អ៊ីកយុងផាក កំឡុងពេលធ្វើការសិក្សានៅភូមិគោលដៅ។ ជាចុងក្រោយ សូមអគុណចំពោះអ្នកដែលបានចែករំលែកព័ត៌មាន និង ឯកសារទាំងអស់ ព្រមទាំងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia) បណ្តាញទន្លេអន្តរជាតិ (International Rivers) អង្គការមូលនិធិសង្គ្រោះសត្វព្រៃសាកល (World Wildlife Foundation) ខេត្តក្រចេះ អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (Community Economic Development) អង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (Cambodia Rural Development Team) និងអង្គការអុកស្វាមអូស្ត្រាលី (Oxfam Australia)។

សូមអរគុណយ៉ាងពិសេស ចំពោះអង្គការអុកស្វាមអូស្ត្រាលី ដែលបានផ្តល់ជូននូវរូបភាពជាច្រើនសំរាប់ប្រើប្រាស់ក្នុងរបាយការណ៍នេះ។

# ពាក្យកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CC | ក្រុមប្រឹក្សាឃុំ-សង្កាត់ |
| CED | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| CRDT | អង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា |
| EIA | ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន |
| FACT | សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល |
| GDP | ផលទុនជាតិសរុបក្នុងស្រុក |
| GMS | មហាអនុតំបន់ទន្លេមេគង្គ |
| Ha | ហិកតា |
| IUCN | សហព័ន្ធអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ |
| Kg | គីឡូក្រាម |
| Km | គីឡូម៉ែត្រ |
| Kwh | គីឡូវ៉ាត់ក្នុងមួយម៉ោង |
| Lao PDR | សាធារណរដ្ឋប្រជាមានិតឡាវ |
| LMB | អាងទន្លេមេគង្គក្រោម |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MIME | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| MLAI | វិទ្យាស្ថានតស៊ូមតិផ្នែកច្បាប់ទន្លេមេគង្គ |
| MOU | អនុសារណៈ នៃការយោគយល់ |
| MRC | គណៈកម្មការទន្លេមេគង្គ |
| MW | មេហ្គាវ៉ាត់ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| RCC | សម្ព័ន្ធទន្លេកម្ពុជា |
| Riel | រូបិយប័ណ្ណកម្ពុជា ប្រាក់រៀល |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |

| | |
|---|---|
| TERRA | ឆ្ពោះទៅកាន់ភាពប្រសើរឡើងវិញនៃប្រព័ន្ធអេកូឡូស៊ី និង សម្ព័ន្ធភាពនៃតំបន់ |
| VDC | គណៈកម្មការអភិវឌ្ឍន៍ភូមិ |
| WWF | មូលនិធិសង្គ្រោះសត្វព្រៃសាកល |

# មាតិកា


សេចក្តីថ្លែងអំណរគុណ................................................ II

ពាក្យគ្រាត់................................................ III

មាតិកា................................................ V

សង្ខេបអត្ថបទ................................................ IX

១.សេចក្តីផ្តើម................................................ ១

១.១ ទន្លេមេគង្គ................................................ ៤

១.២ គោលបំណងនៃការស្រាវជ្រាវ................................ ៥

១.៣ វិធីសាស្ត្រស្រាវជ្រាវ................................ ៥

១.៣.១ ការជ្រើសរើសភូមិគោលដៅសម្រាប់ធ្វើការសំភាសន៍.......................... ៦

១.៣.២ ការសិក្សាឯកសារ................................................ ៧

១.៣.៣ ការបង្ហាញ និងសិក្ខាសាលាបញ្ជាក់ពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ......... ៨

១.៤ ទំហំនៃការស្រាវជ្រាវ................................ ៩

២. សាវតា : បរិបទថ្នាក់ជាតិ និង តំបន់.......................... ១០

២.១ តម្រូវការប្រើប្រាស់ថាមពល................................ ១៤

២.២ សារៈសំខាន់របស់ទន្លេមេគង្គ................................ ១៦

២.៣ វិស័យផលផលៈ ប្រាក់ចំណូល និងប្រភពអាហារ................ ១៧

៣. និន្នន័យ................................................ ២០

៣.១ ខេត្តក្រចេះ................................................ ២០

៣.១.១ សម្ពាធនៃការអភិវឌ្ឍន៍................................ ២២

៣.២ ស្រុកសំបូរ................................................ ២៣

៣.៣ ផែនការគម្រោងសាងសង់ទំនប់វារីអគ្គិសនីសំបូរ...................... ២៤

៤. ការស្ទង់មតិ................................................ ៣៤

**៤.១. ចំណីមានប្រជាសាស្ត្រក្នុងភូមិគោលដៅទាំង៦ .................... ៣៤**

៤.១.១ ភូមិយារ ............................................................ ៣៦

៤.១.២ ភូមិកោះសំ ............................................................ ៣៧

៤.១.៣ ភូមិសំភិន ............................................................ ៣៩

៤.១.៤ ភូមិកោះផ្តៅ ............................................................ ៤០

៤.១.៥ ភូមិដីរ ............................................................ ៤១

៤.១.៦ ភូមិខ្សាច់លាវ ............................................................ ៤២

**៤.២ ការចិញ្ចឹមជីវិត និងប្រាក់ចំណូល .................... ៤៤**

៤.២.១ សកម្មភាពនេសាទ ............................................................ ៤៦

៤.២.២ ការដាំបន្លែតាមច្រាំងទន្លេ ............................................................ ៤៧

៤.២.៣ ប្រាក់ចំណូលពីការចិញ្ចឹមសត្វ ............................................................ ៤៨

៤.២.៤ ប្រាក់ចំណូលពីការងារជាកម្មករស៊ីឈ្នួលតាមរដូវកាល និង ប្រាក់ចំណូលពីប្រភពផ្សេងៗ ............................................................ ៥១

**៤.៣ ការផ្តល់សេវាកម្មសង្គមមូលដ្ឋាន .................... ៥២**

**៤.៤ សកម្មភាពរបស់ស្ត្រី .................... ៥៤**

**៤.៥ ធនធានព្រៃឈើ .................... ៥៥**

**៤.៦ ការប្រើប្រាស់ទន្លេមេគង្គ .................... ៥៦**

៤.៦.១ លំហូរទឹកតាមរដូវកាល ............................................................ ៥៦

៤.៦.២ ជួរទឹក និងអន្លង់ជ្រៅៗ ............................................................ ៥៧

៤.៦.៣ គុណភាព និងបរិមាណទឹកទន្លេ ............................................................ ៥៩

**៤.៧ វិស័យទេសចរណ៍ .................... ៦០**

**៤.៨ កម្មវិធីអភិវឌ្ឍន៍ស្រុកសំបូរ .................... ៦១**

**៤.៩ ប្រព័ន្ធអគ្គិសនី .................... ៦២**

**៥. បញ្ហា និងការគំរាមកំហែងនានាលើជីវភាពរស់នៅ .................... ៦៤**

៥.១ ការភ័យខ្លាច ការបារម្ភ និងភាពមិនប្រាកដប្រជា.................... ៦៤

៥.២ សន្តិសុខស្បៀង និងសុខភាព................................ ៦៥

៥.៣ តម្លាភាព និងគណនេយ្យភាព................................ ៦៥

៥.៤ គម្រោងអភិវឌ្ឍន៍នានាបានរាំងស្ទះ........................... ៦៦

៥.៥ សំណឹកច្រាំងទន្លេ.......................................... ៦៧

៥.៦ បរិមាណ និងគុណភាពទឹកទន្លេ............................... ៦៧

៥.៧ សម្បទានដី និងសកម្មភាពនិស្សារណកម្ម........................ ៦៨

៥.៨ ការឆ្លើយតបរបស់អ្នកភូមិ.................................... ៦៩

៦. សេចក្តីសន្និដ្ឋាន................................................ ៧០

៦.១ ការចិញ្ចឹមជីវិត និង ទន្លេមេគង្គ.............................. ៧០

៦.២ មូលដ្ឋានសេវាកម្មសង្គម..................................... ៧១

៦.៣ ស្ត្រី....................................................... ៧២

៦.៤ ព្រៃឈើ..................................................... ៧២

៦.៥ បញ្ហា និងការគំរាមកំហែងនានា............................... ៧២

៦.៦ គម្រោងអភិវឌ្ឍន៍នានា........................................ ៧៣

៧. អនុសាសន៍...................................................... ៧៤

៨. ឯកសារយោង.................................................... ៧៨

ឧបសម្ព័ន្ធ : គំរូសំណួរណែនាំអំពីការស្រាវជ្រាវ.......................... ៨៦

## តារាង និងផែនទី

ផែនទី ១: ផែនទីគំរោងសាងសង់ទំនប់វារីអគ្គីសនីទាំង១១នៅដងទន្លេមេនៃទន្លេមេគង្គ....... ១១
ផែនទី ២: ផែនទីបង្ហាញពីខេត្តក្រចេះ........ ២០
ផែនទី ៣: ផែនទីស្រុកសំបូរបង្ហាញភូមិចំនួន៦ក្នុងការសិក្សាស្រាវជ្រាវ........ ៣៤

តារាងទី ១ : ចំនួនប្រជាជនតាមឃុំ........ ២៣
តារាងទី ២: ព័ត៌មានជុំវិញដីសម្បទាន........ ២៤
តារាងទី ៣: គំរោងទំនប់វារីអគ្គិសនីសំបូរ........ ២៩
តារាងទី ៤: ព័ត៌មានប្រជាសាស្ត្រនៃភូមិទាំង៦........ ៣៥
តារាងទី ៥: អន្លង់ជ្រៅក្នុងតំបន់ស្រុកសំបូរ........ ៥៧

## រូបភាព

រូបភាពទី ១: ដីស្រែរបស់កសិករ........ ៣៧
រូបភាពទី ២: សកម្មភាពនេសាទរបស់អ្នកភូមិ........ ៣៨
រូបភាពទី ៣: សកម្មភាពកសិកម្មរបស់ស្ត្រីនៅក្បែរភូមិ........ ៣៩
រូបភាពទី ៤: សកម្មភាពអ្នកភូមិស្រោចសួនដាំបន្លែតាមច្រាំងទន្លេ........ ៤២
រូបភាពទី ៥: សកម្មភាពធ្វើស្រែក្នុងភូមិ........ ៤៥
រូបភាពទី ៦: ស្ត្រីជាមួយនឹងក្របីរបស់គាត់នៅវាលស្រែ........ ៤៩
រូបភាពទី ៧: ស្ត្រីឱ្យចំនីទៅមាន់របស់គាត់........ ៥០
រូបភាពទី ៨: ស្ត្រីឱ្យចំនីទៅជ្រូករបស់គាត់........ ៥១

# សង្ខេបប្រតិបត្តិ

របាយការណ៍ស្រាវជ្រាវនេះបង្ហាញពីព័ត៌មានស្តីពីស្ថានភាពរស់នៅរបស់ប្រជាជនដែលពឹងផ្អែកលើធនធានទន្លេចំនួន ៦ភូមិ ក្នុងស្រុកសំបូរ ខេត្តក្រចេះ ប្រទេសកម្ពុជា ដែលពួកគាត់នឹងត្រូវទទួលរងផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីសំបូរ។ តាមទំហំនៃការស្ទង់មតិ ពេលវេលា និងធនធានដែលមានសម្រាប់ធ្វើការ ស្រាវជ្រាវនេះ បានបង្ហាញអោយឃើញថា ការស្ទង់មតិ និង ការសិក្សាខាងលើផ្តោតតែលើការចិញ្ចឹមជីវិត និងផលប៉ះពាល់ពីការសាងសង់វារីអគ្គិសនីតែមួយប៉ុណ្ណោះដែលមាននៅស្រុកសំបូរ និងតំបន់ជិតៗនេះ តែគោលបំណងដែលបានព្រៀងទុកសម្រាប់ការស្ទង់មតិថ្នាក់មូលដ្ឋាននេះគឺ ដើម្បីបំពេញចំណេះដឹងមូលដ្ឋានដល់អង្គការសង្គមស៊ីវិល សម្រាប់គាំទ្រដល់បញ្ហាសង្គម និងបរិស្ថាន ដែលនឹងកើតមានឡើងពីការសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំ។ ជាងនេះទៅទៀត ដើម្បីជួយបង្កើនការយល់ដឹង និងពិចារណាពីការសំរេចចិត្តចំពោះការអភិវឌ្ឍន៍ក្នុងប្រទេស និងតំបន់។

ក្នុងឆ្នាំ ២០០៩ មានគម្រោងសាងសង់ទំនប់វារីអគ្គិសនីចំនួន១៩កន្លែង នៅតាមបណ្តោយអាងទន្លេមេគង្គ (MRC SEA ២០០៩) ក្នុងនោះមាន ១១គម្រោង ស្ថិតនៅតាមអាងទន្លេមេគង្គក្រោមដែលមាននៅក្នុងប្រទេស ថៃ កម្ពុជា ឡាវ និង ប្រទេសវៀតណាម។ ក្នុងចំណោមគម្រោងទាំង១១ខាងលើមាន២ទីតាំងស្ថិតនៅក្នុង ប្រទេសកម្ពុជាដែលមួយនៅ ខេត្តស្ទឹងត្រែង មានកំលាំង ៩៨០ មេហ្គាវ៉ាត់ និងមួយទៀតនៅស្រុកសំបូរ ខេត្តក្រចេះដែលមានកំលាំង ២៦០០ មេហ្គាវ៉ាត់ និងកំលាំងរក្សាទុក ៤៦៥មេហ្គាវ៉ាត់ (MRC SEA ២០០៩)។

គម្រោងទំនប់វារីអគ្គិសនីសំបូរនេះត្រូវបានគេនិយាយថាមានផលប៉ះពាល់ខ្លាំង និងពិបាកទទួលបានផលចំណេញតាមរយៈការលក់អគ្គិសនីចេញទៅក្រៅប្រទេស (CNMC,២០០៩)។ មានមនុស្សប្រមាណជា ១៩.០៣៤នាក់ នឹងទទួលរងផលប៉ះពាល់ដោយផ្ទាល់ (MRC SEA, Vol.១១ ២០០៩)។ ហើយប្រជាជនទាំងនោះអាចនឹងត្រូវប្រឈមមុខនឹងការផ្លាស់ប្តូរលំនៅដ្ឋានរបស់ខ្លួន។ មានប្រជាជនរាប់លាននាក់ទៀតដែលរស់នៅតាមដងទន្លេមេគង្គក្រោមនឹងទទួលរងឥទ្ធិពលពីការ

សាងសង់ទំនប់នេះ។ ទិន្នន័យនៃគម្រោងវារីអគ្គិសនីស្រុកសំបូរបានបង្ហាញឱ្យឃើញថា ផ្ទៃដីប្រហែលជា ៦២០ គីឡូម៉ែតការ៉េ នឹងត្រូវជន់លិច (MRC SEA, Vol. ១១ ២០០៩) ដែលរួមបញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធ ដូចជាអាគាររដ្ឋាភិបាល មន្ទីរពេទ្យ សាលារៀន ប្រាសាទ ផ្លូវថ្នល់ ផ្ទះសំបែង ប្រព័ន្ធស្រោចស្រព ស្រែចំការ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតជាច្រើន។ ភាពអន្តរាយបែបនេះអាចជាការពាក់ពន្ធ័យ៉ាងសំខាន់ដល់ផ្នែកសង្គម ដោយសារតែកង្វះខាតសេវាកម្មសង្គមមូលដ្ឋាននៅក្នុងស្រុក។ ហើយក៏មានគម្រោងអភិវឌ្ឍន៍ជាច្រើនទៀត ដែលបានជួយនៅតាមបណ្តាភូមិដ្ឋាននានានៃតំបន់ដែលនឹងរងផលប៉ះពាល់ផងដែរ ហើយស្រុកសំបូរនឹងរងការបាត់បង់។ លើសពីនេះទៀតវានឹងបណ្តាលធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានរយៈពេលខ្លី និងរយៈពេលវែងដល់បរិស្ថាន សេដ្ឋកិច្ច និង សង្គម ដោយសារតែការសាងសង់ទំនប់វារីអគ្គិសនីនៅស្រុកសំបូរ។ ក្នុងនោះការបាត់បង់ត្រី បណ្តាលឱ្យប៉ះពាល់ដល់សង្គមគ្រួសារជាច្រើនដែលការចិញ្ចឹមជីវិត និងប្រាក់ចំណូលរបស់ពួកគេគឺអាស្រ័យលើធនធានទន្លេ។

ការស្រាវជ្រាវបង្ហាញថា ការប្រកបរបររួមផ្សំ ដូចជាការធ្វើស្រែចំការ ការនេសាទ ដាំបន្លែតាមច្រាំងទន្លេ ការចិញ្ចឹមសត្វ ការលក់កំលាំងពលកម្មតាមរដូវកាល និងការកាប់ព្រៃឈើគឺជាសកម្មភាពចិញ្ចឹមជីវិត និងប្រភពផ្តល់ថវិកាស្ទើរតែគ្រប់ក្រុមគ្រួសារទាំងអស់ នៅតាមបណ្តាភូមិដែលបានធ្វើការសម្ភាសន៍នោះ។

ការស្រាវជ្រាវសន្និដ្ឋានថា មានការជាប់ទាក់ទងគ្នាយ៉ាងខ្លាំងរវាងការងារធ្វើស្រែចំការ ការនេសាទ ការដាំបន្លែតាមច្រាំងទន្លេ ការលក់កំលាំងពលកម្មតាមរដូវកាល ទៅតាមរដូវកាលនៃលំហូរទឹកទន្លេមេគង្គ និង ធនធានរបស់វា។ នេះបង្ហាញឱ្យឃើញពីទំនាក់ទំនងសំខាន់មួយដែលធ្វើអោយមនុស្សមានប្រភពប្រាក់ចំណូលពេញមួយឆ្នាំ ហើយធ្វើឱ្យការចិញ្ចឹមជីវិតតាមបែបប្រពៃណីមានចីរភាពសម្រាប់មនុស្សជំនាន់ក្រោយៗទៀត។

ស្ថានភាពនៃការរស់នៅខាងលើនេះបានបង្ហាញផងដែរថា ដើម្បីឱ្យតម្រូវការចំណីអាហារប្រចាំថ្ងៃរបស់គ្រួសារនីមួយៗមានភាពគ្រប់គ្រាន់ និងរស់នៅសមរម្យ លុះត្រាតែធនធានសម្រាប់ចិញ្ចឹមជីវិតទាំងអស់នោះគង់វង្ស និងប្រាក់ចំណូលមានស្ថេរភាព។ ប្រសិនបើមានផ្នែកណាមួយនៃការរួមផ្សំសម្រាប់របរចិញ្ចឹមជីវិតខាងលើបាត់បង់ វានឹងអាចធ្វើអោយប្រជាជនរងការប៉ះពាល់ និងធ្វើអោយកើតមានភាពក្រីក្រ។

គម្រោងសាងសង់ទំនប់វារីអគ្គិសនីសំបូរ នឹងធ្វើអោយប៉ះពាល់ជាអវិជ្ជមានដល់កម្មវិធីអភិវឌ្ឍន៍ និងពន្យឺតចំណាប់អារម្មណ៍របស់ភ្នាក់ងារអភិវឌ្ឍន៍នានា និងកម្មវិធីអភិវឌ្ឍន៍របស់រដ្ឋាភិបាលខ្លួនឯងផ្ទាល់ ហើយធ្វើឱ្យស្រុកសំបូរទាំងមូលបាត់បង់សេវាកម្មសង្គមមូលដ្ឋាន និងធ្វើឱ្យភាពក្រីក្រកើនឡើងដោយសារតែស្ថានភាពបែបនេះ។

មាតិកានៃការស្រាវជ្រាវនេះត្រូវបានបង្ហាញដូចខាងក្រោម សេចក្តីផ្តើមដំបូង នឹងបង្ហាញពីគោលបំណងនៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រ ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ។ ទីពីរបង្ហាញព័ត៌មានទូទៅពីបរិបទតំបន់ និងជាតិ និង លទ្ធផលស្រាវជ្រាវ។ ចំនុចចុងក្រោយនិយាយពីសេចក្តីបញ្ចប់ និងអនុសាសន៍។

# ១. សេចក្ដីផ្ដើម

សព្វថ្ងៃនៅបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ការផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់ គឺជាគោលសំខាន់ក្នុងការអភិវឌ្ឍន៍ ប្រសិនបើគ្មានថាមពលអគ្គិសនីផ្គត់ផ្គង់គ្រប់គ្រាន់ទេនោះ វិស័យឧស្សាហកម្មក៏មិនអាចរីកចំរើនបានដែរ ហើយប្រទេសនឹងជាប់គាំងក្នុងភាពអន់ថយ។ នៅតាមតំបន់ខ្លះនៃពិភពលោក ដូចជាតំបន់ទន្លេមេគង្គ ដែលមានលក្ខណៈអំណោយផលដោយធនធានជលសាស្ត្រដែលអាចយកមកប្រើប្រាស់សម្រាប់ទាញយកថាមពលបាន ដើម្បីដោះស្រាយបញ្ហានៅក្នុងប្រទេស។

ស្របពេលជាមួយគ្នានេះដែរ គម្រោងសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំ ដែលត្រូវបានគេដឹងថាមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គម ជាពិសេសប៉ះពាល់ដល់សហគមន៍ជាច្រើនដែលរស់នៅជិតទំនប់វារីអគ្គិសនី តំបន់ស្តុកទឹក និងអ្នកដែលរស់នៅផ្នែកខាងក្រោមគឺប្រាកដជានឹងត្រូវផ្លាស់ប្តូរទីលំនៅ។ ផលប៉ះពាល់ទាំងនេះវានឹងធ្វើឱ្យច្របូកច្របល់ដល់ការរស់នៅរបស់ប្រជាជន និងការចិញ្ចឹមជីវិត។ ក្រៅពីនេះនឹងធ្វើអោយមានការប្រែប្រួលនូវរបបទឹក និងបាត់បង់ធនធានក្នុងទឹក ព្រមទាំងប៉ះពាល់ផងដែរចំពោះការបំលាស់ទីលំនៅរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ផ្ទាល់ និងសហគមន៍នៅតំបន់ផ្សេងទៀតដែលពឹងផ្អែកផ្ទាល់លើធនធានទន្លេរួមគ្នា។ ការជះឥទ្ធិពល ទាំងនេះនឹងរួមចំណែកបង្កើតឱ្យមានបញ្ហាលើ កម្មសិទ្ធិកាន់កាប់ដីធ្លីចំពោះប្រជាជន ដែលរស់នៅក្នុងតំបន់ប៉ះពាល់ផ្ទាល់ និងប្រជាជនដែលរស់នៅតាមដងទន្លេ ហើយបង្កើតឱ្យមានការគំរាមគំហែងដល់ធនធានព្រៃឈើបន្ថែមទៀត។

តាមរយៈការជំរុញការអភិវឌ្ឍន៍ធនធានទឹកនៅតាមដងទន្លេមេគង្គថ្មីៗនេះ ការបង្កើតវារីអគ្គិសនី គឺជាចំនុចចំបងដែលបានលើកឡើងដោយអ្នកចូលរួម ជាពិសេសវិស័យឯកជន។ តម្រូវការថាមពលអគ្គិសនី ៩០% សម្រាប់ប្រើប្រាស់ក្នុងតំបន់ត្រូវបានលើកឡើងថា អាចទាញយកបានតែតាមរយៈការសាងសង់ទំនប់វារីអគ្គិសនីប៉ុណ្ណោះ ហើយការធ្វើគំរោងទៅថ្ងៃអនាគតបានបង្ហាញថា ថាមពលអគ្គិសនីចំនួន ១.៥០០មេហ្គាវ៉ាត់ នឹងអាចទាញយកពីតួនៃទន្លេមេគង្គដោយការសាងសង់តំនប់វារីអគ្គិសនីនៅកំឡុង ឆ្នាំ២០២០ ខាងមុខ (*MRC SEA: Key Framing*

*Issues,* ២០០៩)។ ភាគច្រើននៃថាមពលដែលទទួលបានខាងលើត្រូវបានធ្វើគំរោងសំរាប់ការនាំចេញជាឧទាហរណ៍ ៧០% នៃថាមពលដែលនឹងទទួលបានពីគំរោងទំនប់វារីអគ្គិសនីនៅស្រុកសំបូរ ខេត្តក្រចេះ នឹងត្រូវលក់ចេញទៅក្រៅប្រទេសដូចជា ប្រទេសថៃ វៀតណាម និងចិន (*MRC, SEA Vol. 11,* ២០០៩)។

ការប្រើប្រាស់ថាមពលនៅប្រទេសកម្ពុជាមានបរិមាណតែ ២៩ គីឡូវ៉ាត់ម៉ោងក្នុងមួយគ្រួសារ បរិមាណនេះទាបជាងគេបង្អស់ក្នុងបណ្តាប្រទេសតាមដងទន្លេមេគង្គ។ បើប្រៀបធៀបជាក់ស្តែងជាមួយប្រទេសឡាវវិញ គឺប្រទេសឡាវប្រើប្រាស់ថាមពលអគ្គិសនីប្រមាណ ៩៥គីឡូវ៉ាត់ម៉ោងក្នុងមួយគ្រួសារ ប្រទេសថៃ ៤០៩ គីឡូវ៉ាត់ម៉ោងក្នុងមួយគ្រួសារ និងប្រទេសវៀតណាមមានចំនួន ២៤២ គីឡូវ៉ាត់ម៉ោង ក្នុង១គ្រួសារ (*MRC SEA: Key Framing Issues,* ២០០៩)។ កត្តាទាំងនេះ បានបញ្ជាក់យ៉ាងច្បាស់ថាទំនប់វារីអគ្គិសនីទាំងអស់នៅប្រទេសកម្ពុជានឹងត្រូវបានផលិតអគ្គិសនីច្រើនជាងតំរូវការ ។

តែទោះជាយ៉ាងណាក៏ដោយ វិបត្តិសេដ្ឋកិច្ចសាកលនៅតែបង្កើតអោយមានភាពមិនច្បាស់លាស់ពីទីផ្សារថាមពលអគ្គិសនីនៅក្នុងរយៈពេលខ្លី។ ឧទាហរណ៍ ក្រោយពីទទួលរងនូវវិបត្តិសេដ្ឋកិច្ចប្រទេសថៃ វាអាចនឹងត្រូវការរយៈពេលច្រើនឆ្នាំដើម្បីកសាងសេដ្ឋកិច្ចខ្លួនឡើងវិញជាជាងការពិចារណាលើការទិញចូលនូវថាមពលអគ្គិសនី។ រីឯប្រទេសវៀតណាមវិញ កំពុងឋិតនៅក្នុងដំណើរការធ្វើកំណែទំរង់ទីផ្សារថាមពលរយៈពេលច្រើនឆ្នាំ ឧទាហរណ៍ ប្រទេសវៀតណាមអាចជាដៃគូប្រកួតប្រជែងផែនការផលិតថាមពលជាមួយប្រទេសកម្ពុជានា ឆ្នាំ២០១៤ (ព្រោះគំរោងកំណែទំរង់របស់វៀណាមបានចាប់ផ្តើមតាំងពីឆ្នាំ២០០៥) ហើយប្រទេសវៀតណាម នឹងក្លាយជាអ្នកប្រកួតប្រជែងលក់ថាមពលជាមួយប្រទេសកម្ពុជានា ឆ្នាំ២០២២ ទៀតផង (*MRC SEA: Key Framing Issues,* ២០០៩)។

សូចនាការនៃការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាក្នុងពេលថ្មីៗបានបង្ហាញថា កំណើនតំរូវការថាមពលអគ្គិសនីរបស់ប្រទេសកម្ពុជានៅចន្លោះឆ្នាំ ២០០៥ ដល់ ២០២៥ មានកំរិតអប្បរមាដែលប្រហែលជាតិចជាង ៥.០០០ មេហ្គាវ៉ាត់ ក្នុងកំឡុងពេល២០ឆ្នាំទៅមុខទៀតបើប្រៀបធៀបប្រទេសឡាវ វៀតណាម និងប្រទេសថៃ (*ADB,* ២០០៨) ជាឧទាហរណ៍ កំណើនតំរូវការថាមពលរបស់ប្រទេសថៃនឹងកើនឡើងដល់ ៥០.០០០ មេហ្គាវ៉ាត់ នៅកំឡុងពេល

២០ឆ្នាំខាងមុខ (*ADB, Economics of Energy Integration report,* ២០០៨)។ យោងតាមរបាយការណ៍ ឆ្នាំ២០០៩ របស់ធនាគារពិភពលោកបានបង្ហាញថា ស្ថានភាពសេដ្ឋកិច្ចនៅក្នុងតំបន់បានផ្លាស់ប្តូរ។ ហើយការប៉ាន់ប្រមាណគំរោងផ្អែកថាមពលគឺផ្អែកលើការប្រើប្រាស់ថាមពលដើម្បីបន្តជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងតំបន់។ របាយការណ៍ ដដែលរបស់ធនាគារពិភពលោកបានវិភាគលើបញ្ហានេះផងដែរថា កំណើនកំរិតជីវភាពរបស់ប្រជាជនកម្ពុជា និងកំណើននៃសេដ្ឋកិច្ចនឹងត្រូវធ្លាក់ចុះបើប្រៀបធៀបនៅនឹង ប្រទេសឡាវ និង វៀតណាម។

ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី គឺជាផែនការអទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងចំណោមផែនការដទៃទៀតជាច្រើន ដែលផែនការនេះនឹងក្លាយជាផែនការប្រវត្តិសាស្ត្រមួយ ហើយជាគោលការណ៍ ការសាងសង់ទំនប់វារីអគ្គិសនីនេះ នឹងត្រូវធ្វើឡើងនៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាដាច់ខាត (*Inter Press Service,* ២០០៨)។

មានការសិក្សាជាច្រើនបានលើកឡើងថា សារៈសំខាន់របស់វិស័យជលផលនៅក្នុងផលទុនជាតិសរុបក្នុងស្រុកប្រទេសកម្ពុជា បានចូលរួមលើកស្ទួយជីវភាព បង្កើតប្រាក់ចំណូល និងជាប្រភពផ្តល់ប្រូតេអ៊ីនដល់សហគមន៍ដែលរស់នៅពឹងផ្អែកលើដងទន្លេ និងប្រជាជនដទៃទៀតទូទាំងប្រទេសកម្ពុជា។ ផ្អែកលើការលើកឡើងរបស់គណៈកម្មការទន្លេមេគង្គ (*MRC Catch and Culture,* ខែកញ្ញា ឆ្នាំ២០០៨) ទំនប់វារីអគ្គិសនីដែលនឹងត្រូវសាងសង់នៅលើតួទន្លេមេគង្គនឹងក្លាយជាឧបសគ្គសំរាប់ត្រីធ្វើបំលាស់ទីឡើងចុះ កត្តាទាំងនេះ នឹងនាំឱ្យជះឥទ្ធិពលដល់មនុស្សដែលរស់នៅដោយពឹងផ្អែកលើធនធានត្រីក្នុងទន្លេ។ បំលាស់ប្តូរជលសាស្ត្រនឹងនាំអោយមានការកែប្រែទំហំ រយៈពេល និងពេលវេលាធម្មជាតិនៃទឹកជំនន់ប្រចាំឆ្នាំដូចជាការកើនឡើងនូវកំរិតទឹកជំនន់ ដែលការប្រែប្រួលនេះនឹងធ្វើអោយប៉ះពាល់ដល់ទិន្នផលស្រូវ ជាពិសេសសហគមន៍ដែលរស់នៅដោយពឹងផ្អែកលើបឹងទន្លេសាប ដូចជា កម្មករ នេសាទ និងអ្នកធ្វើការផ្សេងៗទៀត។

ក្រៅពីនេះ ទិន្នផលនេសាទក៏ជាចំនុចសំខាន់ផងដែរនៅក្នុងវិស័យកសិកម្មនៅប្រទេសកម្ពុជា វាបានចូលរួម ១២ភាគរយនៅក្នុងកំរិតជីវភាពរបស់ប្រជាជន (*MRC,* ២០០៤) បន្ថែមលើផលិតផលកសិកម្មដ៏ទៃទៀត ដូចជាស្រូវ ការចិញ្ចឹមសត្វ ។ល។ មិនតែប៉ុណ្ណោះ ផលប្រយោជន៍ផ្សេងទៀតជាច្រើនពីវិស័យជលផលដែលត្រូវប្រើប្រាស់សំរាប់គាំទ្រដល់សន្តិសុខស្បៀង ការចិញ្ចឹម

ជីវិត ជីវៈចម្រុះ និងតួនាទីអេកូឡូស៊ី។ ត្រីមានតួនាទីសំខាន់សំរាប់ការចិញ្ចឹមជីវិតរបស់មនុស្ស បើទោះបីជាផលប្រយោជន៍ទាំងនោះមិនមែនជាផ្នែកមួយនៃសេដ្ឋកិច្ចជាតិក៏ដោយ (*MRC Catch and Culture,* ខែកញ្ញា ឆ្នាំ២០០៨)។

ធាតុចូល និងការប្រឹក្សាយោបល់សាធារណៈនៅក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍន៍មានកំរិតតិចតួចបំផុត ដែលនេះជាឧបសគ្គក្នុងរបៀបវារៈនៃការអភិវឌ្ឍន៍ប្រទេសដោយរដ្ឋាភិបាល។ ការប្រឹក្សាយោបល់សារធារណៈ ជាឧទាហរណ៍រាល់គំរោងសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគេជឿថា មិនមានការស្មោះត្រង់ និងលាតត្រដាង និងមិនមានការពិគ្រោះយោបល់ជាមួយវិស័យសារណៈ។ ការសំរេចចិត្តថាតើនរណា? អ្វីខ្លះ? នៅពេលណា? និងក្រុមសង្គមស៊ីវិល ជាពិសេសសហគមន៍ដែលនឹងទទួលរងផលប៉ះពាល់អវិជ្ជមានពីការធ្វើផែនការសាងសង់ទំនប់វារីអគ្គិសនីឱ្យបានចូលរួមក្នុងការធ្វើការសំរេចចិត្តយ៉ាងសំខាន់នេះ ត្រូវបានដាក់ឆ្ងាយពីការជ្រើសរើស និងយល់ថាមិនចាំបាច់។

គំរោងផែនការសាងសង់ទំនប់វារីអគ្គិសនីសំបូរនេះ គឺជាគំរោងមួយដែលមានការចែកចាយព័ត៌មានតិចតួចបំផុត និងមិនទាន់ពេលវេលាទៀតផង ជាពិសេសការធ្វើវិមជ្ឈការ និងការផ្តល់សិទ្ធិក្នុងការសំរេចចិត្តទៅកាន់ភាគីពាក់ព័ន្ធក្នុងជួររាជរដ្ឋាភិបាល ដូចជាក្រសួងឧស្សាហ៍កម្ម រ៉ែ និងថាមពល គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន និងក្រសួងផែនការ។ ទង្វើទាំងនេះបានធ្វើអោយសង្គមស៊ីវិលគិតថា វាមានបញ្ហា និងផលប៉ះពាល់អវិជ្ជមានដល់សហគមន៍។

## ១.១ ទន្លេមេគង្គ

ទន្លេមេគង្គមានប្រវែងប្រហែល ៤.៩០០ គីឡូម៉ែត្រ ពីប្រទេសចិន និងប្រទេសភូមា ហើយលាតសន្ធឹងរហូតដល់ប្រទេសកម្ពុជា ថៃ ឡាវ និងប្រទេសវៀតណាម។ ជាទន្លេដែលវែងជាងគេលំដាប់ទី១២ ក្នុងពិភពលោក ហើយជាអាងទន្លេដែលធំជាងគេលំដាប់ទី ២១ ដែលគ្របដណ្តប់ទំហំ ៧៩៥ ០០០គីឡូម៉ែត្រ (*MRC, ២០០៥*)។ ទន្លេនេះជាប្រភពដែលផ្តល់ត្រីធំជាងគេនៅលើពិភពលោក ហើយការនេសាទត្រីជាផ្នែកមួយដ៏សំខាន់ ជាស្បៀង និងប្រាក់ចំណូលសំរាប់ប្រជាជនជាង ៥៥លាននាក់ ដោយអាចប្រមូលផលត្រីបានជាង ២,៥លានតោន ក្នុងមួយឆ្នាំ

មានតំលៃ២,៥ពាន់លានដុល្លា ហើយមានទំហំស្មើនឹងប្រមាណជាមួយភាគបួននៃត្រីទឹកសាបក្នុងពិភពលោក *(CNMC & WorldFish Centre, ២០០៧)* ។

៥% នៃតំបន់ដីសើមសរុបនៅអាស៊ីដែលមានសារៈសំខាន់ថ្នាក់អន្តរជាតិ គឺត្រូវបានរកឃើញថាមាននៅក្នុងប្រទេសកម្ពុជា *(Baran, et. al., ២០០៧)*។ តំបន់នេះគ្របដណ្តប់ជាង ៣០% នៃប្រទេសកម្ពុជាដែលមានតំបន់ទំនាបលិចទឹកតាមដងទន្លេមេគង្គ និងដងទន្លេសាប ហើយនិងតំបន់ឆ្នេរសំខាន់ៗមួយចំនួនទៀតដូចជាស្ទឹងកោះផ្ការ និង ស្ទឹងកែបជាដើម *(Baran, et. al., ២០០៧)* ។

៨៦% ដែលស្មើនឹង ១៥៥.០០០គីឡូម៉ែត្រក្រឡានៃផ្ទៃដីប្រទេសកម្ពុជា គឺភាគច្រើនជាតំបន់ទំនាបតាមដងទន្លេមេគង្គ ហើយទន្លេនេះហូរកាត់ប្រទេសកម្ពុជាក្នុងខេត្តស្ទឹងត្រែង និងបន្តហូរកាត់ភាគខាងត្បូងនៃខេត្តក្រចេះមុននឹងហូរធ្លាក់ចូលទន្លេសាបក្បែររាជធានីភ្នំពេញ *(MIME &CNMC, ២០០៣)* ។

## ១.២ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងជាឯកសារស្តីពីស្ថានភាពរស់នៅជាមូលដ្ឋាន និងផ្នែកពាក់ព័ន្ធផ្សេងៗទៀត និងល័ក្ខខ័ណ្ឌសង្គមសំខាន់ៗរបស់ភូមិទាំង៦ ដែលអាស្រ័យផលតាមដងទន្លេ ក្នុងស្រុកសំបូរ ខេត្តក្រចេះដែលទំនងនឹងត្រូវទទួលរងផលប៉ះពាល់ដល់សហគមន៍ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីស្រុកសំបូរ ។ របាយការណ៍នេះនឹងត្រូវបានគេប្រើប្រាស់សំរាប់ពង្រឹងចំណេះដឹងជាមូលដ្ឋាន នៃកិច្ចការសង្គមស៊ីវិល និងការតស៊ូមតិ ស្តីពីបញ្ហាសង្គម និងបរិស្ថានដែលបណ្តាលមកពីគំរោងសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំ ហើយក៏នឹងត្រូវប្រើប្រាស់ផងដែរដើម្បីពង្រឹងការយល់ដឹងក្នុងចំណោមអ្នកធ្វើការសំរេចចិត្តក្នុងការអភិវឌ្ឍន៍ជាច្រើនក្នុងប្រទេស និងតំបន់។

## ១.៣ វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះ រួមមាន ការសំភាសន៍ជាបុគ្គល និងជាក្រុមនៅក្នុងភូមិដែលបានជ្រើសរើស ទាំង៦ និងឯកសារមួយចំនួនទៀត។ ព័ត៌មានដែលប្រមូលបានជាប្រភេទ

ទិន្នន័យបែបគុណភាពដោយប្រមូលពីអាជ្ញាធរភូមិ-ឃុំ និងប្រជាជន។ ការសំភាសន៍ដោយប្រើបញ្ជីរសំនួរ ដែលបានរៀបចំឡើងដោយសមាជិកសម្ព័ន្ធទន្លេកម្ពុជា និងកែតំរូវអោយត្រូវនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ។ ការសំភាសន៍មានភាពហ្មត់ចត់ ដូច្នេះអ្នកសំភាសន៍មិនអនុញ្ញាតអោយសួរសំនួរក្រៅពីបញ្ជីសំនួរឡើយ។ ការប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល ថ្នាក់ជាតិ និងខេត្ត និងតាមស្ថាប័នមួយចំនួន ដូចជាគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងមន្ទីរផែនការខេត្តក្រចេះត្រូវបានរៀបចំឡើងផងដែរ។ ហើយក៏មានការប្រជុំជាច្រើនជាមួយនឹងបណ្តាអង្គការក្រៅរដ្ឋាភិបាល ដែលកំពុងធ្វើការក្នុងស្រុកសំបូររួមមាន អង្គការសង្គ្រោះសត្វព្រៃសាកល អង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងអង្គការអុកស្វាមអូស្ត្រាលី ដើម្បីប្រមូលឯកសារដែលជាប់ពាក់ពន្ធ័។

ការសិក្សានេះ ចំណាយពេលអស់ ២៦ថ្ងៃ ចាប់ពីថ្ងៃទី ២៨ខែធ្នូ ឆ្នាំ ២០០៩ រហូតដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១០ ដែលរាប់ទាំងពេលធ្វើដំណើរ និងការរៀបចំផ្សេងៗ។ បន្ថែមលើការងារសំភាសន៍ និងការស្រង់ឯកសារដែលមានស្រាប់ ក៏នៅមានកិច្ចការសំខាន់ៗមួយចំនួនទៀតបានរៀបចំឡើង រួមបញ្ចូលទាំងបទបង្ហាញពីលទ្ធផលនៃការសិក្សាស្រាវជ្រាវលើកដំបូង និងការរៀបចំសិក្ខាសាលាសំរាប់សហគមន៍ដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវនេះ។ លើសពីនេះទៅទៀត សមាជិកសម្ព័ន្ធទន្លេកម្ពុជា ក៏បានចំណាយពេលសំរាប់ធ្វើការពង្រាងរបាយការណ៍នេះផងដែរ។ របាយការណ៍ចុងក្រោយត្រូវបានបញ្ចប់នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០។

### ១.៣.១ ការជ្រើសរើសភូមិគោលដៅសម្រាប់ធ្វើការសំភាសន៍

ការជ្រើសរើសទីតាំងសិក្សាស្រាវជ្រាវត្រូវបានកំនត់ និងជ្រើសរើស ដោយមានការប្រឹក្សាជាមួយនឹងសម្ពន្ធ័ទន្លេកម្ពុជា និងអាស្រ័យទៅលើបណ្តាភូមិដែលនឹងទទួលរងនូវផលប៉ះពាល់ដោយគំរោងទំនប់វារីអគ្គីសនីស្រុកសំបូរ។ បណ្តាភូមិដែលបានជ្រើសរើសមានដូចជា ភូមិយាវសំភិន និងកោះផ្តៅដែលស្ថិតនៅ ឃុំកំពង់ចាម និង ភូមិកោះសំ ក្នុងឃុំសំបូរ ភូមិដំរៃ ក្នុងឃុំបឹងចារ និងភូមិខ្សាច់លាវក្នុងឃុំអូរគ្រៀង។

ភូមិខ្សាច់លាវ ជាភូមិដែលស្ថិតនៅភាគខាងលើចំងាយប្រហែល១១៤គីឡូម៉ែត្រ ពីទីរួមស្រុកសំបូរ។ ដូច្នេះយោងទៅតាមពេលវេលា និងចំងាយផ្លូវ ក្រុមការងារមិនអាចចុះទៅធ្វើការសិក្សាស្រាវជ្រាវបានទេ ដោយគ្រាន់តែអញ្ជើញប្រជាពលរដ្ឋចំនួន៣នាក់មកស្រុកសំបូរ ដើម្បីធ្វើការសម្ភាសន៍ដែលក្នុងនោះរួមមានប្រធានភូមិ និងសមាជិកគ្រួសាររបស់គាត់ ២នាក់ ផងដែរ។

អ្នកដែលត្រូវបានជ្រើសរើសសម្រាប់ធ្វើការសម្ភាសន៍ភាគច្រើនជាប្រធានភូមិ សមាជិកគណៈម្មាការអភិវឌ្ឍន៍ភូមិ សមាជិកគណៈកម្មាការរបស់ក្រុមតូចៗ ដែលមាននៅក្នុងភូមិ ប្រធានសមាជិកក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ។ ដោយមានការគាំទ្រពីអង្គការអុកស្វាមអូស្ត្រាលី ពួកគាត់ត្រូវបានអញ្ជើញពីបណ្ដាភូមិនានាដែលត្រូវបានជ្រើសរើសដើម្បីធ្វើការសំភាសន៍ជាក្រុម ដែលជាធម្មតាត្រូវចំណាយពេលពេញមួយព្រឹក។ នៅពេលរសៀលការសម្ភាសន៍ត្រូវបានរៀបចំជាលក្ខណៈគ្រួសារ ជ្រើសរើសដោយចៃដន្យ និងកំនត់ទៅតាមអ្នកដែលរស់នៅក្នុងភូមិក្នុងកំឡុងពេលធ្វើការសិក្សាស្រាវជ្រាវ។ សំរាប់ការសំភាសន៍នីមួយៗត្រូវចំណាយពេល១ម៉ោងកន្លះ ដោយរាប់បញ្ចូលទាំងការបកប្រែផងដែរ។ ប្រជាជនសរុប១១៥នាក់ ត្រូវបានសំភាសន៍ដោយក្នុងនោះមានស្ត្រីចំនួន ៥០% ។

### ១.៣.២ ការសិក្សាឯកសារ

ឯកសារភាគច្រើនដែលយកមកសិក្សាសំរាប់ការស្រាវជ្រាវនេះ ត្រូវបានយកមកពីស្ថាប័នសង្គមស៊ីវិល និងអង្គការអន្តរជាតិជាច្រើន។ ឯកសារទាំងនេះយកមកវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា អង្គការអុកស្វាមអូស្ត្រាលី អង្គការទន្លេអន្តរជាតិ មជ្ឈមណ្ឌលត្រីពិភពលោក និងអង្គការមូលនិធិសង្គ្រោះសត្វព្រៃសាកល។ តែទោះបីយ៉ាងក៏ដោយរាល់ឯកសារទាំងអស់ត្រូវបានត្រួតពិនិត្យឡើងវិញដោយអង្គការដៃគូពាក់ព័ន្ធ និងស្ថាប័នរដ្ឋាភិបាលជាច្រើន។ ឯកសារទាំងនេះ យកមកពីគណៈកម្មាការទន្លេមេគង្គ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ ព័តិមានបន្ថែម និងទិន្នន័យដែលបានត្រួតពិនិត្យរួចត្រូវបានប្រមូលយកពីប្រព័ន្ធវេបសាយ និងទំនាក់ទំនងតាមរយៈសារអេឡិចត្រូនិចជាមួយនឹងបុគ្គលដែលពាក់ព័ន្ធ។

### ១.៣.៣ ការបង្ហាញ និងសិក្ខាសាលាបញ្ជាក់ពីលទ្ធផលនៃការសិក្សាស្រាវជ្រាវ

បទបង្ហាញពីលទ្ធផលដំបូងត្រូវបានរៀបចំឡើង ដើម្បីចែករំលែកដល់សមាជិកសម្ព័ន្ធទន្លេកម្ពុជា ហើយការធ្វើបទបង្ហាញនេះគឺក្នុងគោលបំណងផ្ដល់ជាមតិដើម្បីកែតម្រូវ។ សកម្មភាពនេះធ្វើឡើងនៅ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១០ នៅឯការិយាល័យវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា។ ហើយសិក្ខាសាលាក៏ត្រូវបានគេ រៀបចំផងដែរនៅថ្ងៃទី ២០ ខែមករា ឆ្នាំ ២០១០។ សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងដើម្បីធ្វើការបញ្ជាក់ បន្ថែមទៅលើព័ត៌មានដែលបានប្រមូលរួច និងទិន្នន័យមួយចំនួនដែលខ្វះចន្លោះ។ ព្រឹត្តិការណ៍នេះត្រូវបានធ្វើឡើង នៅស្រុកសំបូរ ដោយមានអ្នកចូលរួម ៣៥នាក់ ជាប្រជាជនមកពីភូមិដែលជ្រើសរើសទាំង៦ និង សមាជិកសម្ព័ន្ធទន្លេកម្ពុជា។

## ១.៤ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំនៃការសិក្សាគឺយោងទៅលើពេលវេលា ថវិកា និងធនធានគំរោង ដែលមានសំរាប់ការងារតាមភូមិ សំយោគឯកសារ និងដំណាក់កាលវិភាគទិន្នន័យដើម្បីផលិតនូវរបាយការណ៍នៃការសិក្សាដ៏ស៊ីជំរៅមួយ។ ដើម្បីដោះស្រាយលើព្រំដែននៃការសិក្សាស្រាវជ្រាវ យើងបានពិគ្រោះយោបល់ដោយមិនបានរួមបញ្ចូលនូវឬសគល់នៃបញ្ហាជាច្រើន និងបានសំរេចចិត្ត ជ្រើសរើសដើមហេតុសំខាន់ៗ ដើម្បីឈានទៅដល់ការស្វែងយល់ស្ដីអំពីទិដ្ឋភាពនៃការរស់នៅរបស់ប្រជាជននៅក្នុងភូមិដែលកំពុងមានការព្រួយបារម្ភពីការគំរាមកំហែងនៃគំរោងសាងសង់ទំនប់វារីអគ្គិសនី។ រឿងរ៉ាវមួយចំនួនដែលមិនបានរាប់បញ្ចូលមានដូចជា ការនេសាទ និងព័ត៌មាន បច្ចេកទេសលំអិត សម្បទានដីលំអិត និងព្រៃឈើលំអិត។ វាត្រូវបានយល់ថាមានឯកសារជាច្រើនសម្រាប់ដកស្រង់ដែលមានការទាក់ទងទៅនឹងវិស័យទាំងអស់នេះដែលតម្រូវឱ្យមានពេលវេលា សម្រាប់បណ្ដុញដែលចាប់អារម្មណ៍ដើម្បីប្រៀបធៀបពីសារៈសំខាន់ និងព័ត៌មានដែលពាក់ព័ន្ធទាំងឡាយដែលត្រូវការ។

គំរោងសាងសង់ទំនប់វារីអគ្គិសនីស្រុកសំបូរ គឺជាការគំរាមកំហែងមួយដែលនឹងអាចកើតមានឡើង ប៉ុន្តែគម្រោងនេះនៅតែស្ថិតនៅក្នុងភាពមិនច្បាស់លាស់នៅឡើយ។ វាជាការពិបាកក្នុងការស្វែងរកព័ត៌មានអំពីផែនការសាងសង់ដែលផ្ទុយពីអ្វី ដែលគណៈកម្មការទន្លេមេគង្គ

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយជាច្រើនបានចេញផ្សាយ។ មន្ត្រីរដ្ឋាភិបាលហាក់បីដូចជាមានភាពស្ទាក់ស្ទើរក្នុងការឆ្លើយតបទៅនឹងសំនួរ និងមិនបានដឹងអ្វី ទាំងអស់។

ម្យ៉ាងវិញទៀតទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រ អ្នកស្រាវជ្រាវត្រូវការពេលវេលាយ៉ាងហោចណាស់ ចំនួន២-៣ថ្ងៃ ចំពោះការសិក្សាក្នុងភូមិនីមួយ ហើយវាកាន់តែប្រសើរប្រសិនបើអាចស្នាក់នៅទីនោះទៀត ប៉ុន្តែ ពេលវេលាគឺមិនគ្រប់គ្រាន់។ ហើយភាគច្រើនចំពោះអ្នកដែលផ្តល់ការសម្ភាសន៍ជាគ្រួសារដែលមានប្រាក់ចំនូលមធ្យមនៅក្នុងភូមិរបស់ពួកគាត់។ ទោះយ៉ាងណាក្រុមដែលផ្តល់បទសំភាសន៍នីមួយចាត់ទុកថាជាក្រុមដែលអាចជឿទុកចិត្តបាន ហើយព័តិមានដែលប្រមូលបានជាព័តិមានពិត និងអាចតំណាងឱ្យស្ថានភាពភូមិទាំងមូលបាន។

សរុបមក របាយការណ៍នេះមិនមែនជាការសិក្សាមានលក្ខណៈស៊ីជំរៅទៅលើការរស់នៅរបស់ប្រជាជន ក្នុងស្រុកសំបូរទេ ប៉ុន្តែវាអាចតំណាងអោយព័តិមានជាមូលដ្ឋាននៃជីវភាពរស់នៅ និងប្រភពប្រាក់ចំណូលរបស់ភូមិទាំង៦ ដែលបានសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយគំរោងសាងសង់ទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេគង្គ ក្នុងប្រទេសកម្ពុជាទំនងជារងផលប៉ះពាល់ច្រើនកន្លែង ជាពិសេសសហគមន៍ដែលពឹងអាស្រ័យទៅនឹងធនធាននៅតាមដងទន្លេ នៅផ្នែកខ្លះនៃប្រទេសឡាវ ប្រទេសថៃ និងប្រទេសវៀតណាម។ ផលប៉ះពាល់ទាំងនេះចាំបាច់អោយមានការសិក្សាអោយបានធំទូលាយ និងស៊ីជំរៅលើទំហំនៃឥទ្ធិពលប៉ះពាល់ដែលបណ្តាលមកពីការអភិវឌ្ឍន៍វារីអគ្គិសនី ជាពិសេសសហគមន៍ដែលពឹងអាស្រ័យលើធនធានទន្លេនៅក្នុងតំបន់នេះ។

## ២. សាវតា : បរិបទថ្នាក់ជាតិ និង តំបន់

នៅក៏រិតតំបន់មានការកើនឡើងនូវក៏រិតសេដ្ឋកិច្ចយ៉ាងរហ័ស នៅក្នុងរយៈពេល ៣-៤ ទសវត្សចុងក្រោយនេះ ឧទាហរណ៍ដូចជា កំនើនសេដ្ឋកិច្ចប្រទេសចិន និងថៃ ដែលបានទទួលជោគជ័យ (*IMF, World Economic Outlook,* ២០០៧) ។ ថ្វីបើនាពេលថ្មីៗនេះមានការធ្លាក់ចុះនៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងនៅតែបន្តធ្លាក់ចុះនៅ ប្រទេសជាច្រើនក៏ដោយ ក៏គេអាចឃើញមានកំនើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាដែរ ។ ជាក់ស្តែង ការវិនិយោគផ្នែកសេដ្ឋកិច្ចរបស់កម្ពុជាមានសន្ទុះកើនឡើងយ៉ាងលឿនរួមមានក្រុមហ៊ុនសម្បទានជាច្រើនគំរោងសាងសង់វារីអគ្គិសនី ផ្លូវការបណ្តាក់ទុនអាជីវកម្មធំៗ ។ល។ ការកើនឡើងនេះហាក់ដូចជាបានដាក់សម្ពាធយ៉ាងធ្ងន់ធ្ងរទៅលើធនធានធម្មជាតិ ដូចជាធនធានទន្លេមេគង្គ និង ព្រៃឈើដែលតែងតែត្រូវបានគេធ្វើអាជីវកម្មលើសកម្មភាពនៃការអភិវឌ្ឍន៍ ។

ទំនប់វារីអគ្គិសនីជាជំរើសមួយ ដែលមានប្រជាប្រិយភាពក្នុងការទាញយកថាមពលមកប្រើប្រាស់នៅតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនៅបណ្តាប្រទេសមួយចំនួន ដែលមានសេដ្ឋកិច្ចរីកចំរើន ដូចជាប្រទេសចិន ប្រទេសថៃ និង វៀតណាម ។ ការកើនឡើងនៃការប្រើប្រាស់ថាមពលវារីអគ្គិសនីនៃប្រទេសទាំងនោះ ចាំឱ្យមានផលប៉ះពាល់អគ្គិសនីទៅលើតំបន់ទន្លេមេគង្គ និងសហគមន៍ដែលមានជីវភាពពឹងអាស្រ័យនឹងធនធានទន្លេ ។ ផលប៉ះពាល់ទាំងនេះ បាននឹងកំពុងតែកើនឡើង និងកំពុងតែបន្តប៉ះពាល់ជាពិសេសទៅលើប្រជាជនក្រីក្រ និងសហគមន៍ដែលគ្មានឱកាស ហើយដែលជីវភាពរបស់ពួកគេពឹងផ្អែកទៅលើធនធានតាមដងទន្លេ ។ នាពេលបច្ចុប្បន្ននេះមានគំរោងសាងសង់ទំនប់វារីអគ្គិសនីចំនួន៨ នៅផ្នែក ខាងលើនៃតួទន្លេមេគង្គ និងមាន១១ទៀតនៅផ្នែកខាងក្រោមនៃអាងទន្លេមេគង្គ ដែលមាននៅក្នុង ប្រទេសថៃ ឡាវ កម្ពុជា និង វៀតណាម ។




(© TERRA)

*ផែនទី១: ផែនទីនេះបង្ហាញពីគំរោងសាសង់ទំនប់វារីអគ្គិសនីទាំង១១ កន្លែងនៅតាមអាងទន្លេមេគង្គក្រោម*

និន្នាការនៃការអភិវឌ្ឍន៏សេដ្ឋកិច្ចនាពេលថ្មីៗនេះ បង្ហាញថាបណ្តាប្រទេសតាមទន្លេមេគង្គ ដែលសេដ្ឋកិច្ចកំពុងរីកលូតលាស់យ៉ាងឆាប់រហ័សក្នុងពិភពលោក ក្នុងនោះប្រទេសកម្ពុជាមាន អត្រាកំនើនផលិតផលក្នុងស្រុក សរុបចំនួន ៧% វៀតណាម ៨% ឡាវ ៧,១% ចិន ១០% និង

ប្រទេសថៃ ៤.៥% ( *IMF, World Economic Outlook,* ២០០៧)។ កត្តាមួយចំនួនដែលជំរុញអោយមានកំណើនសេដ្ឋកិច្ចនេះ បណ្តាលមកពីការផ្សព្វផ្សាយនៃទំនាក់ទំនងផ្នែកសេដ្ឋកិច្ចយ៉ាងយកចិត្តទុកដាក់ និងការចែកចាយធនធានដែលមាននៅក្នុងអនុតំបន់។ ទស្សនៈទាននេះបានផ្សព្វផ្សាយដោយកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី។ នេះគឺជាការរួមចំណែកក្នុងការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដែលរួមមានគំរោងសាងសង់ទំនប់វារីអគ្គិសនី និងថាមពលអគ្គិសនីក្នុងមហាអនុតំបន់ទន្លេមេគង្គ ដើម្បីសម្រួលដល់ការលក់ និងទិញអគ្គិសនីនៅក្នុងតំបន់។

ស្របជាមួយនឹងកំណើននៃការអភិវឌ្ឍន៍នេះ បានបង្កើននូវសម្ពាធដល់ប្រទេសក្នុងតំបន់ក្នុងការដោះស្រាយចំពោះបញ្ហានៃការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែវាហាក់ដូចជាជំរុញលើកទឹកចិត្តដល់បណ្តារដ្ឋាភិបាលទន្លេមេគង្គ និងបណ្តាអ្នកប្រើប្រាស់ថាមពលអគ្គិសនីធំៗ មានដូចជាប្រទេសចិន ប្រទេសថៃ និងប្រទេសវៀតណាម ដែលធ្វើអាជីវកម្មលើប្រភពវារីអគ្គិសនីនេះទៅវិញ។ ហេតុនេះ ថាមពលវារីអគ្គិសនីត្រូវបានគេដឹងថាជាថាមពលដែលបរិសុទ្ធ និងជាធនធានដែល សមស្របសំរាប់បរិស្ថាន។ ទោះបីជាយ៉ាងនេះក៏ដោយ បញ្ហានេះកំពុងតែមានពិភាក្សាពិគ្រោះយោបល់ថាតើគំរោងសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំនេះ នឹងសមស្របដើម្បីឆ្លើយតបនឹងបំរែបំរួលបរិស្ថាន ឬអត់ដូចជាទីផ្សារកាបូន។ នេះគឺជាការពិតដែលត្រូវកង្វល់ព្រោះថា ការសាងសង់ទំនប់វារីអគ្គិសនីត្រូវការកាប់ឆ្ការព្រៃដែលមានទំហំធំ និងធ្វើអោយផ្លាស់ប្តូរនូវលំហូរនៃទន្លេ។ ហេតុនេះ វាធ្វើអោយផ្ទុះឡើងនូវឧស្ម័នមេតាន ជាពិសេសនៅតំបន់ត្រូពិច។

តួនាទីរបស់រដ្ឋាភិបាលទន្លេមេគង្គចំពោះការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីគឺ ដើម្បីធានាឱ្យបាននូវការផ្គត់ផ្គង់ថាមពលអគ្គិសនី ដែលមានតំលៃថោកគឺជាការព្រួយបារម្ភដ៏ចំបងមួយរបស់បណ្តាប្រទេសជាច្រើននៅក្នុងតំបន់ ជាពិសេសប្រទេសកម្ពុជា ដោយសារតែការពង្រីកនូវសេដ្ឋកិច្ចរបស់ខ្លួន។ តែទោះជាយ៉ាងណាក៏ដោយកម្ពុជា មានតំបន់ទាក់ទាញតិចតួចបើប្រៀបធៀបទៅនឹងប្រទេសជិតខាងមានន័យថាសក្តានុពលវារីអគ្គិសនីក្នុងតំបន់ពិតជាមានកំរិត ដែលទាមទារអោយរដ្ឋាភិបាលមានការគិតគូរអោយបានច្បាស់លាស់ចំពោះតំបន់ណាដែលនឹងធ្វើការអភិវឌ្ឍន៍នោះ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់អាទិភាពនូវការសាងសង់ទំនប់វារីអគ្គិសនីជាគោលនយោបាយមួយសំខាន់សំរាប់ធ្វើការអភិវឌ្ឍន៍វិស័យថាមពលរបស់ខ្លួន និងចាត់ទុកថាការសាងសង់

ទំនប់វារីអគ្គិសនីជាសមិទ្ធិផលដ៏ប្រសើរ *(inter Press Service, ២០០៨)*។ ការសាងសង់ទំនប់ គឺជាការរួមចំណែកក្នុងការបង្កើតការងារ និងការរកប្រាក់ចំណូលដែលបង្ហាញពីការគាំទ្រ ដ៏សំខាន់សំរាប់គោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រទេស។ ទោះជាយ៉ាងណាក៏ដោយមានការលើកឡើងនូវការព្រួយបារម្ភក្នុងចំណោមសង្គមស៊ីវិលដែលចោទសំនួរថា តើប្រភេទគំរោងទាំងនេះអាចធ្វើអោយសំរេចគោលដៅកាត់បន្ថយភាពក្រីក្រមែនដែរឬទេ។ ការសាងសង់ទំនប់វារីអគ្គិសនីនេះគេចាត់ទុកថា មានផលប៉ះពាល់ និងម្យ៉ាងទៀតធនធានមនុស្ស ផ្នែកសាងសង់ទំនប់វារីអគ្គិសនីប្រទេសយើងមានមានកំរិត។ ល័ក្ខខ័ណ្ឌនេះគឺកំនត់នូវសក្តានុពលតិចតួចចំពោះ ឱកាសការងាររបស់ប្រជាពលរដ្ឋកម្ពុជា។

គណៈកម្មការទន្លេមេគង្គ បានបង្កើតឡើងដោយក្រុមប្រទេសអាងទន្លេមេគង្គក្រោម។ នៅឆ្នាំ ១៩៩៥ កិច្ចព្រមព្រៀងរបស់គណៈកម្មាធិការនេះបានចុះហត្ថលេខាយល់ព្រមប្តេជ្ញាចិត្ត ដើម្បីសហការសម្របសម្រួលលើការអភិវឌ្ឍន៍ ការការពារបរិស្ថាន និងការគ្រប់គ្រងអាងទន្លេមេគង្គប្រកបដោយនិរន្តរភាពដល់អ្នកទទួលផលជាច្រើននៅតាមដងទន្លេ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មការទន្លេមេគង្គ ឥឡូវកំពង់តែរៀបចំទិសដៅសារជាថ្មីរបស់ខ្លួនដើម្បីឆ្ពោះទៅរកការផ្សព្វផ្សាយយ៉ាងសកម្មលើគម្រោងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំៗ ដូចដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រថ្មីរបស់គណៈកម្មការទន្លេមេគង្គ សម្រាប់ឆ្នាំ ២០០៦ ដល់ ២០១០ ។ ការអភិវឌ្ឍន៍វារីអគ្គិសនី គឺជាជំហាននៃការអភិវឌ្ឍន៍ដែលមានតាំងពីទសវត្សឆ្នាំ១៩៩០មកម្ល៉េះ ហើយបានផ្តល់នូវការចាប់អារម្មណ៍សារជាថ្មីលើតម្រូវការប្រើប្រាស់ថាមពលក្នុងតំបន់ *(MRC, ១៩៩៨)*។ វារីអគ្គិសនី គឺជារបៀបវារៈដំបូងគេដែលតែងតែលើកយកមកពិភាក្សានៅបណ្តាប្រទេសនានានៅតាមដងទន្លេ *(MRC, ១៩៩៨)* ហើយគណៈកម្មការទន្លេមេគង្គក៏បានពិចារណាផងដែរថា វារីអគ្គិសនីគឺជាធនធានថាមពលកកើតឡើងវិញ និងមានភាពស្អាត និងបានបង្ហាញថាវាមិនបណ្តាលឱ្យមានការបំពុលខ្យល់ និងការកើនឡើងកំដៅផែនដីឡើយ *(MRC, ១៩៩៨)*។

មានអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដូចជា អង្គការទន្លេអន្តរជាតិ សម្ព័ន្ធទន្លេកម្ពុជា អង្គការឆ្ពោះទៅកាន់ភាពប្រសើរឡើងវិញនៃប្រព័ន្ធអេកូឡូស៊ី និងសម្ព័ន្ធភាពនៃតំបន់ (TEERA) អភិរក្សសម្ព័ន្ធទន្លេមេគង្គ និងអង្គការលីវីងវ៉តធឺសៀម (Living Water Siem) ព្រមទាំងបណ្តាអង្គការជាច្រើនទៀត បានលើកឡើងពីកង្វល់ទាក់ទងទៅនឹងចំណាប់អារម្មណ៍សារជាថ្មីរបស់

គណៈកម្មការទន្លេមេគង្គ នៅក្នុងគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំនៅតាមដងទន្លេមេនៃទន្លេមេគង្គ ដែលនឹងនាំទៅដល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត នៅតាមតំបន់នានាដែលមានភាពចម្រូងចម្រាស់ និងរងផលប៉ះពាល់។

## ២.១ តម្រូវការប្រើប្រាស់ថាមពល

តម្រូវការប្រើប្រាស់ថាមពលអគ្គិសនីដ៏ច្រើននៅក្នុងតំបន់ បានធ្វើអោយមានការចាប់អារម្មណ៍ពីវិស័យឯកជនក្នុងការវិនិយោគវារីអគ្គិសនី។ ជាទូទៅការសាងសង់ទំនប់បានទទួលជំនួយពីវិស័យឯកជន និងការសាងសង់ស្ថិតនៅក្រោមប្រព័ន្ធកិច្ចព្រមព្រៀង "សាងសង់-ប្រតិបត្តិការ-ផ្ទេរ"។ ការរៀបចំនេះតែងតែតម្រូវអោយមាន ក្រុមហ៊ុនបរទេសនានា ដែលមានភាគហ៊ុនច្រើននៅក្នុងគម្រោង (*Menheere, Sebastiaan C.M., ed.,* ១៩៩៦) ។ បណ្ដាក្រុមហ៊ុនទាំងអស់នឹងធ្វើការសាងសង់ទំនប់ ដើម្បីទទួលបានផលចំណេញពីការលក់អគ្គិសនីច្រើនជាង ២៥ឆ្នាំ ហើយធ្វើការជួសជុលសម្រាប់ទាញយកផលចំណេញក្នុងរយៈពេល ២៥ឆ្នាំបន្តទៀត មុនពេលប្រគល់ទៅអោយរដ្ឋាភិបាលកាន់កាប់វិញ (*Huijbregts, 1996*) ។

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងកិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានប្រគល់សិទ្ធិកាន់កាប់ទៅអោយក្រុមហ៊ុន *នីផុន ខួយ ខនសាល់ធេន* (Nippon Koei Consulting Company) ក្នុងឆ្នាំ ២០០៧ ដើម្បីធ្វើការសិក្សាលើប្រធានបទស្តីពី *ការសិក្សាផែនការមេនៃការអភិវឌ្ឍន៍វារីអគ្គិសនីនៅកម្ពុជា*។ ក្រុមអ្នកសិក្សាស្រាវជ្រាវបានបង្ហាញថា គម្រោងសាងសង់ទំនប់នៅតាមដងទន្លេមេគង្គនឹងបង្កអោយទន្លេមេគង្គផ្នែកខាងក្រោមរីងស្ងួត ហើយបណ្តាលអោយប៉ះពាល់ដល់ការផ្លាស់ទីរបស់ត្រីក្នុងទន្លេមេគង្គចូលទៅបឹងទន្លេសាប ដែលគម្រោងនេះមានទំហំធំហួសពីតម្រូវការប្រើប្រាស់ថាមពលក្នុងប្រទេសកម្ពុជា ដូចជាគម្រោងសាងសង់ទំនប់នៅសំបូរដែលនឹងបង្កអោយមានផលប៉ះពាល់ដល់តំបន់ព្រៃឈើ និងតំបន់ការពារដ៏ធំធេង ដែលទាមទារឱ្យមានការពិចារណាទៅដល់ផ្នែកសេដ្ឋកិច្ច និងសង្គម ( *JICA,* ២០០៧) ។

រដ្ឋាភិបាលកម្ពុជាយល់ព្រមអោយមានការសិក្សា និងធ្វើការអភិវឌ្ឍន៍តំបន់សក្តានុពលទាំង៦ ក្នុងប្រទេស កម្ពុជាកាលពីឆ្នាំ ២០០៧ ។ ក្នុងនោះគម្រោងសាងសង់ទំនប់វារីអគ្គិសនីសំបូរជាតំបន់មួយដែលមានភាពចម្រូងចម្រាស់ខ្លាំងដែលក្រុមហ៊ុន ឆៃណា សៅធើន ផៅវ័រ ហ្គ្រីដ

(China Southern Power Grid) បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់ជាមួយរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងឧស្សាហកម្មរ៉ែ និងថាមពល នៅឯព្រឹត្តិការណ៍មួយនៅណានីង (Nan Ning) ដែលរៀបចំដោយមនហាអនុតំបន់ទន្លេមេគង្គកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៦ ។ អនុស្សារណៈនេះបានផ្តល់អោយក្រុមហ៊ុន ឆៃណា សៅធើន ផៅវ័រ ហ្គ្រីដ (China Southern Power Grid) នូវសិទ្ធិអំណាចដើម្បីធ្វើការសិក្សាមុនចាប់ផ្តើមគម្រោង *(Earthrights International,* ២០០៩) ។

ដំណើរការបង្កើតគំរោងទំនប់វារីអគ្គិសនី និងការយល់ព្រមលើការសាងសង់នេះ ត្រូវបានគេកត់សំគាល់ថា មានការខ្វះខាតនូវតម្លាភាព និងមានដែនកំនត់ក្នុងការពិគ្រោះយោបល់អោយបានទូទាំងតំបន់ចំពោះបញ្ហានេះ។ នេះគឺជាករណីមួយយ៉ាងពិតប្រាកដដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា អំពីព័ត៌មានគំរោងសាងសង់ទំនប់វារីអគ្គិសនី។ ជាក់ស្តែងគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅក្នុងស្រុកសំបូរដែលត្រូវបានគេចាត់ទុកថា វាជាប្រភេទព័ត៌មានដែលដឹងដោយកន្លែងៗ ហើយជាបញ្ហាដែលស្រួចស្រាវ និងមានការពិបាកក្នុងការស្វែងរកពិត័ថ្មីៗ។ គោលគំនិតនៃការព្រមព្រៀងដោយសេរីជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ (FPIC) នៅក្នុងបរិបទនេះអាចមិនត្រូវបានអនុវត្តពិតប្រាកដណាស់ ដែលថាកម្ពុជាជាប្រទេសមួយដែលមានប្រពៃណីខ្វះការចូលរួមពិភាក្សាជាសាធារណៈ ។

ទស្សនៈខាងលើនេះកំណត់នូវឱកាសសំរាប់ពិនិត្យមើលមជ្ឈដ្ឋានខាងក្រៅ និងការរិះគន់លើគម្រោងសាងសង់នៅតំណាក់កាលដំបូងនៃការអភិវឌ្ឍន៍របស់គម្រោង ដែលបន្សល់នូវភាពមិនច្បាស់លាស់ ជាពិសេសផ្តោតលើផលប៉ះពាល់ដល់សហគមន៍។ ម្យ៉ាងវិញទៀត ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងវិធានការបន្ធូរបន្ថយ ព្រមទាំងផែនការសំណង គឺមានលក្ខណៈតិចតួចសំរាប់កម្ពុជា និងបង្ហាញពីភាពខ្វះសមត្ថភាពរបស់រដ្ឋាភិបាលទៅលើការត្រួតពិនិត្យ និងជំរុញអោយមានការអនុវត្តន៍ច្បាប់ ព្រមទាំងគោលការណ៍ណែនាំនានាដែលមានស្រាប់ ។

ទោះជាយ៉ាងណាក៏ដោយ គម្រោងសាងសង់ទំនប់វារីអគ្គិសនីផ្តល់ផលប៉ះពាល់ដ៏ធំធេងទៅលើការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជន វាមិនត្រឹមតែធ្វើអោយមានការផ្លាស់ប្តូរទីលំនៅរបស់សហគមន៍ក្បែរៗនោះទេ តែការប្រែប្រួលលើកំរិតទឹកធ្វើអោយប៉ះពាល់ដល់ត្រី ចរាចរណ៍តាមផ្លូវទឹក វិស័យកសិកម្ម និងសុខភាពសាធារណៈ ដែលគ្របដណ្តប់តំបន់ធំៗជាច្រើនទៀត។ ផលប៉ះពាល់រយៈពេលវែងនៃការសាងសង់ទំបន់ និងដំណើរការនេះ ជាទូទៅតែងតែមិនត្រូវបាន

អើពើទាំងអ្នកអភិវឌ្ឍន៍ និងភ្នាក់ងាររដ្ឋាភិបាល។ ផលប៉ះពាល់នៃគម្រោងសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំទៅលើបរិស្ថាន និងសេដ្ឋកិច្ចសង្គម គឺមានភាពទាក់ទងគ្នាយ៉ាងស្អិតរមួតដែលការប៉ះពាល់ទាំងនេះ ជាប់ទាក់ទងទៅនឹងការប្រើប្រាស់ធនធានធម្មជាតិដូចជា ទឹក ដី និង ព្រៃឈើ ដូចគ្នាដែលសហគមន៍តាមដងទន្លេអាស្រ័យផលដើម្បីរកប្រាក់ចំណូល និងប្រកបរបរចិញ្ចឹមជីវិត។

## ២.២ សារៈសំខាន់របស់ទន្លេមេគង្គ

វារីអគ្គិសនីជាជំរើសមួយដែលពេញនិយមនៅតំបន់អាស៊ីអាគ្នេយ៍ ដោយសារតែវាកាត់បន្ថយការពឹងផ្អែកលើប្រេងឥន្ធនៈ និងការប្រើប្រាស់ធនធានក្នុងស្រុក។ ប៉ុន្តែនៅតាមបណ្តាប្រទេសមួយចំនួន ការអភិវឌ្ឍន៍ផ្នែកវារីអគ្គិសនីវាមិនមែនជាជំរើសអាទិភាព រឺមានស្នេហភាពទៀតឡើយ ពីព្រោះវាត្រូវបានគេដឹងថា បណ្តាលអោយប៉ះពាល់ដល់ជីវសាស្ត្រ និងបរិស្ថាន។ ជាក់ស្តែងនៅសហរដ្ឋអាមេរិចកំពុងតែធ្វើការលុបចោលនូវគម្រោងសាងសង់ជាច្រើន ដោយសារតែភាពអន្តរាយរបស់វា។ ហើយក៏មានផងដែរនៅអឺរ៉ុប រីអូ ហ្គ្រាន (Rio Grande) ដែលគ្មានការវិនិយោគលើការសាងសង់ទំនប់ឡើយដោយសារតែមានផលប៉ះពាល់ជាអវិជ្ជមានធំជាងផលជាវិជ្ជមាននោះ (http://www.unep.org/dams/documents)។ នៅប្រទេសកម្ពុជាតាមការសិក្សាបង្ហាញថាមានសក្តានុពលថាមពលវារីអគ្គិសនីចំនួន ១០.០០០មេកាវ៉ាត់ (*Martonova , ed.,* ២០០៨; *MIME and CNMC,* ២០០៣; *Phan.* ២០០៩)។ តាមការប៉ាន់ប្រមាណគេអាចទាញយកថាមពលអគ្គិសនីប្រហែល ៥០ភាគរយ ពីគម្រោងសាងសង់ទំនប់នៅតាមដងទន្លេមេគង្គ (*MIME and CNMC,* ២០០៣;*Phan,* ២០០៩) ។

នៅប្រទេសកម្ពុជា គម្រោងសាងសង់ទំនប់វារីអគ្គិសនីត្រូវបានគេធ្វើឡើងសំរាប់ជាអាងស្តុកទឹក និងជាប្រព័ន្ធស្រោចស្រពក្នុងគោលបំណងគាំទ្រដល់ការពង្រីកវិស័យកសិឧស្សាហកម្មដែលរដ្ឋាភិបាលផ្តល់ដីទំហំជាង ៩៤៣.០៦៨ ហិកតា តាមតំបន់ជនបទទៅអោយក្រុមហ៊ុនឯកជនជាដីសម្បទានសេដ្ឋកិច្ចសំរាប់ធ្វើការអភិវឌ្ឍន៍ លើចំការឈើដាំជាលក្ខណៈកសិឧស្សាហកម្មក្នុងឆ្នាំ ២០០៧ (*UN Special Representative of Secretary-General for Human Rights in Cambodia in* ២០០៧)។ ដូចនេះតំរូវអោយមានការផ្លាស់ប្តូរដីព្រៃឈើទៅជាដីកសិកម្ម។ ការបាត់បង់ព្រៃឈើដ៏សំខាន់សំរាប់ធ្វើចំការជាលក្ខណៈធំៗនេះ នឹងធ្វើឱ្យមានផលប៉ះពាល់តំបន់

ដោយភាពរាំងស្ងួត ដូច្នេះគេតម្រូវឱ្យមានប្រព័ន្ធធារាសាស្ត្រនៅក្នុងតំបន់នេះ។ ការធ្វើបែបនេះមិនទំនងជាផ្តល់ផលប្រយោជន៍ដល់កសិករតូចតាចដែលរស់នៅជិតតំបន់នោះឡើយ។

## ២.៣ វិស័យជលផល : ប្រាក់ចំណូល និងប្រភពអាហារ

នៅតំបន់ទន្លេមេគង្គ ការធ្វើអាជីវកម្មត្រីផ្គត់ផ្គង់នូវផ្នែកមួយដ៏សំខាន់នៃប្រាក់ចំណូលរបស់សហគមន៍ដែលពឹងអាស្រ័យតាមដងទន្លេ ហើយក៏សម្រាប់ប្រជាពលរដ្ឋទូទៅផងដែរ។ យោងទៅលើការសិក្សាបានបង្ហាញថា ការសាងសង់ទំនប់វារីអគ្គិសនី បានផ្តល់ផលជាអវិជ្ជមានទៅដល់ការធ្វើអាជីវកម្មត្រីរបស់ប្រជាពលរដ្ឋដោយកត្តាមួយចំនួន។ ប្រសិនបើកំរិតទឹកធ្លាក់ចុះដល់កំរិតទាបបំផុតជាងសព្វមួយដង ហើយនៅពេលដែលអាងទន្លេទាំងនេះត្រូវបានចាក់បំពេញដោយដីវិញនោះ ប្រភេទធនធានផ្សេងៗដែលរស់នៅក្នុងទឹកពិតជាមិនអាចរស់នៅបានឡើយ។ ការប្រែប្រួលយ៉ាងឆាប់រហ័សនៃកំរិតទឹក ក្នុងកំឡុងពេលដំណើរការសាងសង់ធ្វើឱ្យផ្លាស់ប្តូរនូវលំហូរទឹកទន្លេមេគង្គ ដែលជាហេតុធ្វើអោយប៉ះពាល់ដល់ជំរករបស់ប្រភេទត្រីមួយចំនួន។ ហើយវាក៏គ្មាននូវរដូវទឹកតំឡើងសំរាប់ធ្វើឱ្យមានការបែកសាយនៃហ្វូងត្រីសំរាប់ធ្វើការពងកូនដែរ និងប្រភេទត្រីមួយចំនួន ត្រូវបានគេរំពឹងថានឹងផុតពូជក្នុងពេលឆាប់ៗពីប្រព័ន្ធទន្លេទាំងមូលតែម្តង *(MRC,* ២០០៤) ។

ការផ្លាស់ប្តូរនូវរដូវលំហូរនៃទឹកទន្លេ និងការគ្រប់គ្រងនូវទឹកជំនន់ដែលបណ្តាលមកពីការសាងសង់ទំនប់វារីអគ្គិសនីផ្តល់ផលប៉ះពាល់ដល់ការធ្វើកសិកម្មតាមតំបន់ដងទន្លេ ហើយវានឹងកាត់បន្ថយនូវជីវជាតិរបស់ដីនៅតាមតំបន់ពាមច្រាំងទន្លេដែលប្រជាពលរដ្ឋធ្វើកសិកម្ម នៅរដូវប្រាំងនោះ។ ទាំងនេះក៏ប៉ះពាល់ផងដែរដល់សកម្មភាពធ្វើចរាចរណ៍របស់សហគមន៍ដែលពឹងអាស្រ័យតាមដងទន្លនេះ ដោយសារតែការរាំងស្ទះដ៏ធំសំបើមដែលបណ្តាលមកពីទំនប់សាងសង់នៅតាមទន្លេ។ ការប្រែប្រួលនៃបរិមាណទឹក និងគុណភាពទឹកទំនងជាអាចប៉ះពាល់ដល់សុខភាពសាធារណៈ ហើយការសិក្សានេះបានបង្ហាញថាប្រព័ន្ធទឹករបស់ ស្រុកសំបូរ គឺអាស្រ័យលើទន្លេមេគង្គ និងវាជាការពិតសំរាប់ខេត្តក្រចេះទាំងមូលផងដែរ។ ពពួកស្លែ និង ពួកមីក្រូសរីរាង្គនៅអាងខាងលើទន្លេមេគង្គអាចប៉ះពាល់ដល់សុខភាពសាធារណៈដែលមានទំហំដ៏ធំធេង។ ហើយជានិច្ចកាលកង្វល់អំពីបញ្ហានេះ តែងតែបង្ហាញក្នុងការសិក្សាស្រាវជ្រាវទៅលើផ្នែកបរិស្ថាន

និងតំលៃសេដ្ឋកិច្ច ដែលជារឿយៗមិនបានស៊ីជំរៅទៅលើតំលៃនៃការអភិវឌ្ឍន៍ដែលសាធារណៈជនបានលើកឡើងនោះឡើយ ។

អាងទន្លេមេគង្គមានសារៈសំខាន់ចំពោះប្រទេសកម្ពុជា ដែលគ្របដណ្តប់ជាង៨៤% នៃទឹកដីប្រទេសកម្ពុជា *(J Kristensen, ២០០១)* ។ ទន្លេនេះបង្កើតអោយមានភាពសំបូរបែបដែលជាផ្នែកមួយយ៉ាងសំខាន់សំរាប់ការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា ។ ប្រជាជនភាគច្រើនផ្សារភ្ជាប់ខ្លួនទៅលើទាំងធនធានវប្បធម៌ និងធនធានសេដ្ឋកិច្ច *(World Fish Centre, undated)* ។ ជនជាតិខ្មែរ និងជនជាតិដើមភាគតិចបានពឹងអាស្រ័យដូចគ្នាទៅលើធនធានតាមដងទន្លេជាច្រើនពាន់ឆ្នាំ និងបានបន្តរហូតដល់សព្វថ្ងៃនេះ ហើយយ៉ាងហោចណាស់មាន ១/៣ នៃប្រជាពលរដ្ឋធ្វើការពាក់ពន្ធ័ទៅនឹងការនេសាទ និងការលក់ត្រី ។ ជាការពិតការនេសាទត្រីនៅកម្ពុជា គឺមានទំហំធំជាងគេបំផុតនៅក្នុងពិភពលោក *(MRC, ២០០៤)* ។

វិស័យជលផលបានរួមចំណែក ១២% នៃផលទុនជាតិសរុបក្នុងស្រុក *(MRC, ២០០៤; Catch and Culture, ២០០៨)* ។ ដោយយោងទៅលើគណៈកម្មការទន្លេមេគង្គឆ្នាំ ២០០៤ បានបង្ហាញថា ទោះបីជាការបាត់បង់ត្រីចំនួនតិចតួចក្តីវាតំណាងអោយការបាត់បង់ត្រីរាប់ពាន់តោន និងការបាត់បង់នូវប្រាក់រាប់លានដុល្លា ។ នៅប្រទេសកម្ពុជាប្រហែលជា ១០-២០% នៃប្រជា-ពលរដ្ឋតាមអាងទន្លេរស់នៅតាមតំបន់ដែលសំបូរទៅដោយជីជាតិសំរាប់ធ្វើការដាំដុះ ដែលរួមបញ្ចូលទាំងតំបន់ទន្លេមេគង្គក្រោម និងតំបន់វាលទំនាបទន្លេសាប *(MRC, ២០០៤)* ។

មានការសិក្សាស្រាវជាច្រើនដែលធ្វើឡើងដោយពហុភាគីដូចជា គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង អ្នកវិទ្យាសាស្ត្រជាច្រើនទៀតដែលបានធ្វើការបង្ហាញថា គម្រោងសាងសង់ទំនប់វារីអគ្គិសនី ដូចជាគម្រោងនៅស្រុកសំបូរ នឹងបណ្តាលអោយខូចប្រយោជន៍ទៅដល់ជីវចំរុះរបស់ទន្លេមេគង្គដែលលាតសន្ធឹងចាប់ពីភាគខាងត្បូងប្រទេសឡាវ ទន្លេសាប រហូតទៅដល់ដីសណ្តរនៅក្នុងប្រទេសវៀតណាម ។

ជាក់ស្តែងគណៈកម្មាធិការទន្លេមេគង្គបង្ហាញថា “ទោះបីជាការបាត់បង់ត្រីចំនួនតិចតួចក្តីវាតំណាងអោយការបាត់បង់ត្រីរាប់ពាន់តោន និង ការបាត់បង់នូវប្រាក់រាប់លានដុល្លា... នេះបញ្ជាក់អោយឃើញថា ទំនប់វារីអគ្គិសនីពិតជាមានការគំរាមគំហែងយ៉ាងខ្លាំងនាអនាគតរបស់ពូជត្រី និងការនេសាទត្រី ។” លើសពីនេះទៅទៀត របាយការណ៍ក៏បានបន្ថែមដែរថា “រហូត

មកដល់ពេលនេះ គ្មានចំណុចនៃឧទាហរណ៍ណាមួយដែលអាចមានប្រសិទ្ធិភាពសំរាប់ធ្វើការវាស់វែងនៅក្នុងតំបន់សំរាប់កាត់បន្ថយនូវផលប៉ះពាល់ជាអវិជ្ជមានពីទំនប់ទៅលើការនេសាទត្រី ខណៈដែលទំបន់ទាំងនោះបង្ខាំងនូវការផ្លាស់ទីដើម្បីរកចំណី និងការស្វែងរកទីកន្លែងសំរាប់ពងកូនរបស់ត្រី ហើយនឹងប៉ះពាល់ទៅដល់ផ្នែកខាងលើទន្លេមេគង្គរហូតដល់ភាគខាងត្បូងប្រទេស ឡាវ ប៉ាក់សេ និងការនេសាទត្រីតាម ដងទន្លេសាប"(*MRC, ១៩៩៤* និង *MRC, ២០០២*) ។

លើសពីនេះទៅទៀត គណៈកម្មការទន្លេមេគង្គបានកំណត់យ៉ាងច្បាស់ថាទំនប់នៅតាមដងទន្លេមេគង្គ នៅក្នុងខេត្តក្រចេះរបស់ប្រទេសកម្ពុជា ប្រហែលជាធ្វើអោយអន្តរាយដល់ត្រី ហើយទីតាំងទំនប់វារីអគ្គិសនី ស្រុកសំបូរ ពិតជាទីតាំងដែលប៉ះពាល់ធំបំផុតសំរាប់ធ្វើការសាងសង់ទំនប់ (Technical Symposium on Mekong Fisheries, Vientiane, Laos, ២០០៣) ។

ច្រើនជាងនេះទៅទៀត សហព័ន្ធអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) លើកឡើងថា ការកំណត់យកស្រុកសំបូរជាទីតាំងសំរាប់ធ្វើការសាងសង់ទំនប់វារីអគ្គិសនីគឺជាការគំរាមគំហែងមួយដ៏ធ្ងន់ធ្ងរទៅដល់ទីជំរករបស់សត្វផ្សោតទឹកសាប (Inter-Press Service,www.ipsnews.net) ។ ទន្លេមេគង្គលាតសន្ធឹងនៅចន្លោះខេត្តក្រចេះ នៃប្រទេសកម្ពុជា និងប្រទេសឡាវ មានអន្លង់ជ្រៅៗដែលជាជំរកដ៏សំខាន់ ហើយជាកន្លែងសំរាប់ធ្វើការផ្លាស់ទីរបស់សត្វផ្សោតនៅកំឡុងពេលរដូវប្រាំង ។

គណៈកម្មការទន្លេមេគង្គ ១៩៩៤ បានចេញរបាយការណ៍ថា មានមនុស្សប្រហែល ៥.១២០នាក់ ដែលនឹងត្រូវធ្វើការផ្លាស់ប្តូរទីលំនៅដោយសារតែគម្រោងសាង់សង់ទំនប់វារីអគ្គិសនីស្រុកសំបូរ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តាមការប៉ាន់ស្មានពេលថ្មីៗនេះ មានមនុស្សជាង ១៩.០៣៤នាក់នឹងត្រូវធ្វើការផ្លាស់ទីលំនៅ (*MRC SEA vol.11, ២០០៩*) ។ ហើយរបាយការណ៍នេះក៏បានបង្ហាញផងដែរថា ការប្រែប្រួលនូវចំនួនប្រជាពលរដ្ឋ គឺដោយសារតែការកើនឡើង និងបែបផែនក្នុងការរស់នៅរបស់ប្រជាជនក្នុងរយៈពេល ១៥ឆ្នាំ ដោយគិតចាប់ពី ឆ្នាំ១៩៩៤ ដល់ ឆ្នាំ ២០០៩ ។

## ៣. ទិន្នន័យ

### ៣.១. ខេត្តក្រចេះ




*ផែនទី២: ផែនទីនេះបង្ហាញពីខេត្តក្រចេះ*

ខេត្តក្រចេះគឺជាខេត្ត មួយក្នុងចំណោមខេត្តទាំង២៤ របស់ប្រទេសកម្ពុជា ដែលមានទីតាំងឋិតនៅ ភាគឦសាននៃរាជធានីភ្នំពេញ ចំងាយ ៣៤៨ គីឡូម៉ែត្រ ។ វាឋិតនៅភាគឦសាននៃប្រទេសកម្ពុជា និងមានព្រំប្រទល់ខាងជើង ជាប់ខេត្តស្ទឹងត្រែង ខាងកើតជាប់ខេត្តមណ្ឌលគីរី ខាងលិចជាប់ខេត្តកំពង់ធំ និងខាងត្បូងជាប់នឹងខេត្តកំពង់ចាម ។ វាមានផ្ទៃដីសរុបចំនួន ១១.០៩៤ គីឡូម៉ែត្រការ៉េ និង ៨៣% នៃផ្ទៃដីរបស់ខេត្តនេះ គ្របដណ្តប់ដោយព្រៃឈើ (*MAFF* ២០០៤) ។ ទន្លេមេគង្គ បានហូរកាត់ខេត្តក្រចេះមានប្រវែង ១៤០ គីឡូម៉ែត្រ ។

ខេត្តក្រចេះមានប្រជាជនសរុប ចំនួន ៣១៩ .២១៧នាក់ ជាប់ចំណាត់ថ្នាក់លេខរៀងទី ១៥ ជាខេត្តមានប្រជាជនច្រើនជាងគេក្នុងប្រទេសកម្ពុជា ដែលក្នុងនោះ ១៦០.០៧១ នាក់ ជាស្ត្រី ហើយ ១៥៩.១៤៦នាក ជាបុរសនេះ បង្ហាញអោយឃើញថា ខេត្តក្រចេះ មានចំនួនស្ត្រីច្រើនជាងបុរស ។ ខេត្តក្រចេះមានស្រុកចំនួន ៥ និង ៤៦ ឃុំដែលស្មើ និង ២៥០ភូមិ (*NIS,* ២០០៩) ។ ប្រជាជនក្នុងខេត្តក្រចេះភាគច្រើនប្រកបរបរនេសាទត្រី ធ្វើស្រែចំការ ដើម្បីចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃ ហើយ ៧៨% នៃប្រជាជនសរុបជា អ្នកនេសាទ កសិករ និងជាកម្មករ

ស៊ីឈ្នួលធ្វើកសិកម្ម (http://ipsnews.net)។ ប្រជាជនប្រមាណជា ៨៧% នៃប្រជាជនសរុបក្នុងខេត្តមានដីជាកម្មសិទ្ធិ តិចជាងមួយ ហិកតា ហើយ ៩% ទៀតពុំមានដីដែលជាកម្មសិទ្ធិទេ (*MAFF* ២០០៤)។

អត្រាប្រជាជនទាំងពីរភេទក្នុងខេត្តដែលចេះអាន និងសរសេរកើនឡើងដល់ ៧៣,៥១% បើប្រៀបធៀប ទៅឆ្នាំ១៩៩៨ ដែលមានតែ ៦១,៦១%ប៉ុណ្ណោះ។ អត្រាស្ត្រីដែលចេះអាន និងសរសេរគឺ ៦៩,០១% (១៩៩៨ មានអត្រា ៦៧,៦៨%) ខណៈដែលអត្រាចេះអាន និងសរសេររបស់បុរសកើនឡើងហូតដល់ទៅ ៧៨,០៧% (១៩៩៨ មានតែ៦៧,៦៨%)។ តួលេខនេះបង្ហាញអោយឃើញថា ស្ត្រីមានអត្រាចេះអាន និងសរសេរតិចជាងបុរស។ បច្ចុប្បន្នបានបង្ហាញអោយឃើញច្បាស់ថាអត្រានៃប្រជាជនដែលចេះអាន និងសរសេរមានការកើនឡើង បើប្រៀបធៀបទៅនឹងតួលេខដែលបានបង្ហាញក្នុងឆ្នាំ១៩៩៨។ ភាពចេះអាន និងសរសេររបស់កុមារចន្លោះអាយុ ៦-១៤ឆ្នាំ គឺ ៧២,៩៨% ដែលអត្រាចេះអាន និងសរសេររបស់កុមារីមាន ៧៣,៦៧% គឺខ្ពស់ជាងអត្រារបស់កុមារាបន្តិចបន្តួចដែលមានត្រឹមតែ ៧២,៣០% (*NIS*, ២០០៩)។

ប្រជាជនប្រមាណជា២៣% នៃចំនួនប្រជាជនសរុបក្នុងខេត្តក្រចេះបានពឹងផ្អែកទៅលើទឹកទន្លេជាប្រភពទឹកសំរាប់ផឹកដ៏សំខាន់សំរាប់ពួកគេ។ តួលេខនេះគឺ ទាបជាងបន្តិចចំពោះចំនួនប្រជាជនដែលបានប្រើប្រាស់អណ្តូងដែលគ្មានអនាម័យ និងគ្មានការថែទាំចំនួន ២៣,៣៧% (*NIS*, ២០០៩)។ ប្រជាជន ៤៨,៨៤% នៃប្រជាជនសរុប ក្នុងខេត្តក្រចេះទាំងអស់បានប្រើចង្កៀងប្រេងកាត ៣៦% ប្រើអាគុយ ០,៦៤% ប្រើប្រាស់ថាមពលអគ្គិសនីទាញដោយម៉ាស៊ីនភ្លើងដើម្បីបំភ្លឺនាពេលយប់។ វាបានបង្ហាញអោយឃើញផងដែរថា ប្រជាជន ៧៣,៩៣% មានផ្ទះដែលមានបង្គន់អនាម័យក្នុងផ្ទះ និង ១៤,២៥% នៃចំនួនប្រជាជនសរុបប្រើបង្គន់អនាម័យ ដែលមានអាងស្តុងទឹកសំអុយ ហើយ ៦,៥% ប្រើបង្គន់រណ្តៅធម្មតា (*NIS*, ២០០៩)។

ការនេសាទត្រីក្នុងខេត្តក្រចេះមួយចំនែកត្រូវទាញចេញពីទន្លេមេគង្គ ដែលទន្លេមេគង្គនេះមានសារៈសំខាន់ដល់ការចរាចររបស់ត្រីជាច្រើនប្រភេទ និងរបរនេសាទត្រីដើម្បីចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងខេត្ត។ ជាការពិតណាស់ប្រជាជន៧០% នៃប្រជាជនក្នុងខេត្ត គឺរស់នៅតាមដងទន្លេមេគង្គ *(IWGIA, Indigenous World,* ២០០៧) ខេត្តក្រចេះ ក៏ជាតំបន់

មួយដែលមានសារៈសំខាន់ និងជាទីជម្រកដល់សត្វស្លាប និងសត្វផ្សោតទឹកសាប ដែលកំពុងទទួលរងនូវការគំរាមកំហែងផងដែរ ។

ទន្លេមេគង្គ និងតំបន់វាលលិចទឹកបានផ្គត់ផ្គង់ដល់តំរូវការសំរាប់ប្រជាជន ៧៥.០០០នាក់ និងភូមិចំនួន ៨០ភូមិ ចន្លោះពីខេត្តក្រចេះ ទៅខេត្តស្ទឹងត្រែង។ ការសិក្សាស្រាវជ្រាវរបស់មូលនិធិសង្គ្រោះសត្វព្រៃសាកល ក្នុងឆ្នាំ ២០០៨ បានបញ្ជាក់អោយឃើញថា ចំនួនត្រីដ៏ច្រើនក្រៃលែងក្នុងទឹកដីខេត្តនេះ បានក្លាយជាធនធានដ៏មានសារៈសំខាន់សំរាប់សេដ្ឋកិច្ចក្នុងខេត្តក្រចេះ និងសំរាប់ប្រទេសកម្ពុជាទាំងមូល (*WWF,* ២០០៨)។ វាបានផ្តល់ជាប្រភពចំណូលមួយដ៏មានសារៈសំខាន់សំរាប់សហគមន៍ជាច្រើនក្នុងតំបន់។ ការសិក្សានេះ ក៏បានបញ្ជាក់បន្ថែមដែរ អំពីប្រភេទជីវៈចំរុះដែលមានក្នុងផ្នែកនេះនៃតំបន់អាងទន្លេមេគង្គ គឺមានតម្លៃខ្ពស់ជាងតំបន់ផ្សេងៗ ហើយក៏ជាតំបន់ដែលមានធនធានធម្មជាតិដ៏សំបូរបែបនៃប្រទេសផងដែរ។ ជាការពិតណាស់វាគឺមានលក្ខណៈពិសេសដែលមានតែមួយ បើប្រៀបធៀបទៅនឹងផ្នែកផ្សេងទៀតនៃអាងទន្លេមេគង្គ ដែលឋិតនៅក្បែរៗនោះ ព្រោះវាជាតំបន់ការពារចុងក្រោយនូវព្រៃឈើដែលបន្សល់តាមដងទន្លេមេគង្គនេះ ។

ម្យ៉ាងទៀត ខេត្តក្រចេះក៏ជាបណ្តុំនៃជនជាតិដើមភាគតិចចំនួនប្រាំពីរក្រុមប្រមាណជា ៨% នៃចំនួនប្រជាជនសរុបក្នុងខេត្តទាំងមូល។ ក្រុមទាំងនោះមានជនជាតិភ្នង គួយ មិល ក្រោល ស្ទៀង និងថ្មូន *(IWGIA, Indigenous World,* ២០០៧*)* ។

### ៣.១.១. សម្ពាធនៃការអភិវឌ្ឍន៍

ថ្មីៗនេះ ធនធានទន្លេមេគង្គបានទទួលរងពីការកើនឡើងនូវសម្ពាធនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាអទិភាពរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា (RGC)។ ការបន្តអោយមានការសាងសង់ទំនប់វារីអគ្គិសនីខ្នាតធំ ក្នុងតំបន់ទន្លេមេគង្គផ្នែកខាងក្រោមដោយក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និង ក្រុមហ៊ុនចិនខាងត្បូង ផាវវើគ្រិត (Power Grid) បានចុះហត្ថលេខាលើកិច្ចសន្យាមួយដើម្បីធ្វើការសិក្សាពីសក្តានុពល និងភាពដែលអាចធ្វើបានរបស់ផែនការសាងសង់ទំនប់វារីអគ្គិសនីសំបូរលើអាងទន្លេមេគង្គ នៅណាននីង កាលពីខែតុលា ឆ្នាំ២០០៦ *(TERRA,* ២០០៧*)* ។

### ៣.២. ស្រុកសំបូរ

ស្រុកសំបូរគឺឋិតនៅភាគខាងជើងចំងាយ ៣៥ គីឡូម៉ែត្រ ពីទីរួមខេត្តក្រចេះ និងមានព្រំប្រទល់ខាងជើង ជាប់ខេត្តស្ទឹងត្រែង ខាងត្បូងជាប់នឹងស្រុកព្រែកប្រសព្វ ខាងលិចទល់នឹងខេត្តកំពង់ធំ និងខាងកើតទល់នឹងខេត្តមណ្ឌលគិរី។ ស្រុកសំបូរត្រូវបានទទួលស្គាល់ថា ជាតំបន់ទេសចរណ៍មួយដ៏មានភាពទាក់ទាញរួមបញ្ចូលទាំងការទស្សនាសត្វផ្សោត វត្តសសរ១០០ និងទេសភាពរបស់ទន្លេមេគង្គផងដែរ។ ស្រុកសំបូរមានឃុំចំនួន១០ឃុំ និង ៥២ ភូមិ ជាមួយនឹងចំនួនប្រជាជនសរុប ៥៥.៧០២នាក់ ហើយ ៣០% ជាជនជាតិដើមភាគតិចមាន ភ្នង គួយ មិល ក្រោល និង ធ្នូន។ ប្រជាជនក្នុងស្រុកជាស្ត្រីមានចំនួន ២៧.៨៩៦នាក់ ច្រើនជាងបុរសដែលមានត្រឹមតែ ២៧.៨០៦ នាក់។ ចំនួនផ្ទះសរុបក្នុងស្រុកបានកើនឡើងដល់ ១.៧៨០ខ្នង (*NIS*, ២០០៩)។

**ខាងក្រោមនេះជាតារាងបង្ហាញអំពីចំនួនប្រជាជនលំអិតតាមឃុំនីមួយៗ :**

**តារាងទី១ : ចំនួនប្រជាជនតាមឃុំ**

| ឃុំ | ចំនួនប្រជាជនសរុប | ចំនួនផ្ទះសរុប | ស្ត្រី | បុរស |
|---|---|---|---|---|
| បឹងចារ | ៣.១០៥ | ៦០៣ | ១.៥៥៣ | ១.៥៥២ |
| កំពង់ចាម | ៨.៨៦២ | ១.៨១០ | ៤.៥២២ | ៤.៣៤០ |
| ក្បាលដំរី | ៤.៩៣០ | ៩៨២ | ២.៤៤២ | ២.៤៨៨ |
| កោះខ្ញែរ | ៤.៣១៧ | ៨៦៩ | ២.១៩៣ | ២.១២៤ |
| អូរគ្រៀង | ៦.៧៦៤ | ១.២៤៥ | ៣.២១០ | ៣.៥៥៤ |
| រលោះមានជ័យ | ៦.៦៤៦ | ៧៦០ | ២.២២៤ | ២.២១១ |
| សំបូរ | ៨.២០៣ | ១.៧៨០ | ៤.២៣០ | ៣.៩៧៣ |
| សណ្តាន់ | ៧.០០៧ | ១.៤៤២ | ៣.៥៤២ | ៣.៤៦៥ |
| ស្រែជិះ | ៤.១៩៥ | ៧០៨ | ២.០៩៨ | ២.០៩៧ |
| វ៉ាឡូនុះ | ៣.៨៧៨ | ៧៧០ | ១.៨៨០ | ១.៩៩៨ |

*ប្រភព : NIS, ២០០៩*

ភូមិភាគច្រើនក្នុងស្រុកសំបូរ គឺឋិតនៅតាមវាលលិចទឹកតាមដងទន្លេមេគង្គ និងពឹងផ្អែកលើលំហូរទឹក ទន្លេតាមរដូវកាលសំរាប់អនុវត្តសកម្មភាពធ្វើស្រែចំការ និងវារីជាតិ សំរាប់ធ្វើជាអាហារ និងរកប្រាក់ចំណូលប្រចាំថ្ងៃ។ ប្រជាជនគ្រប់ផ្ទះទាំងអស់ក្នុង ស្រុកសំបូរ ពឹងពាក់លើស្រូវ និងត្រីសំរាប់របបអាហារប្រចាំថ្ងៃរបស់ពួកគេ។ ប្រជាជនភាគច្រើនជឿលើព្រះពុទ្ធសាសនា និងជឿមុតមាំលើអារក្សអ្នកតា *(La, ២០០៧)*។ អារក្សទឹក គឺជាអារក្សមួយ ដែលមានសារៈសំខាន់ក្នុងចំណោមអារក្សសំខាន់ៗផ្សេងទៀត ព្រោះថាអារក្សទឹកនេះបានធ្វើអោយមនុស្សក្នុងស្រុកមានសុខភាពល្អ និងមានភាពចុះសំរុងគ្នា *(La, ២០០៧)*។ ជំនឿលើអារក្សមួយទៀតដែលមានសារៈសំខាន់នោះគឺ វាលបញ្ចុះសព ឬវាលកប់ខ្មោច ដែលជាផ្នែកមួយនៃទំនៀមទំលាប់ប្រពៃណីរបស់ពួកគេ។

ការសិក្សានេះ ក៏បានរកឃើញថា មានសាលាបឋមសិក្សាចំនួន៩៤ ក្នុងស្រុកសំបូរនេះផងដែរ ដែលមាន សិស្សសរុបចំនួន ១២.២៦៨ នាក់ ក្នុងនោះមានសិស្សស្រីចំនួន ៥.៨៩៩ នាក់ *(La, ២០០៧)* និងក្នុងឃុំខ្លះ ឃើញមានអនុវិទ្យាល័យមួយចំនួនផងដែរ។ ស្រុកសំបូរនៅមានកំរិតទៅលើការផ្តល់សេវាថែទាំសុខភាព ដោយមណ្ឌលសុខភាពមានចំនួន ៣ និងប៉ុស្តិ៍សុខភាពចំនួន៤ ប៉ុណ្ណោះក្នុងទឹរួមស្រុកនេះ។ គួរបញ្ជាក់ផងដែរថាក្នុងឃុំនីមួយៗមានមណ្ឌលសុខភាពមួយដែលដំណើរការដោយមន្ត្រីរាជរដ្ឋាភិបាល។

ស្រុកសំបូរមានផ្ទៃដីសរុប ៣៧៣៨គីឡូម៉ែត្រការ៉េ ដែលមានទំហំប្រមាណជា ៣០% នៃផ្ទៃដីសរុបរបស់ ខេត្តក្រចេះទាំងមូល។ ផ្ទៃដីកសិកម្មបានកើនឡើងដល់ទៅ ១០.៧២៥ហិកតា និងផ្ទៃដីស្ងួតហួតហែងមានទំហំ ៩៦៤ ហិកតា។ បច្ចុប្បន្ននេះ ស្រុកសំបូរមានផ្ទៃដី ដែលជាប្រភេទដីតំបន់សម្បទានចំនួន ៧៧.៤៦៤ហិកតា ដែលភាគច្រើនសំរាប់ដាំដើមឈើម៉ៃសាក់ ដំណាំកៅស៊ូ និងដំឡូង។ សម្បទានិកភាគច្រើនជាក្រុមហ៊ុនចិន និងក្រុមហ៊ុនអាមេរិក (http://cambodia.ohchr.org)។ តារាងខាងក្រោមនេះជាព័ត៌មានមួយចំនួនជុំវិញសកម្មភាពសម្បទានក្នុងស្រុកសំបូរ។

**តារាងទី២: ព័ត៌មានជុំវិញដីសម្បទាន**

| ហិកតាសរុប | ក្រុមហ៊ុន | ខេត្ត | ស្រុក | ស្រុក | កាលបរិច្ឆេទផ្តល់ សម្បទាន | សញ្ជាតិ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ដីសម្បទានបែបដាំដំណាំផ្សេងៗ | | | | | | |
| ៩.៨០០ | គ្លូបល អាគ្រិខាល់ឆ័រ ឌីវើលុបមិន (កម្ពុជា) ខូអិលធីឌី Global Agricultural Development (Cambodia)Co. Ltd. | ក្រចេះ | ស្រុក សំបូរ | ក្បាលដំរី | ១៥/៣/២០០៦ | អាមេរិច |
| ១០.០០០ | អេស៊ា វើល អាគ្រិខាល់ ឆ័រ ឌីវើលុបមិន (កម្ពុជា) ខូអិលធីឌី Asia World Agricultural Development (Cambodia) Co. Ltd. | ក្រចេះ | ស្រុក សំបូរ | ក្បាលដំរី, អូរគ្រៀង | ១៥/៣/២០០៦ | ចិន |
| ៩.៥៨៣ | គ្រីន អាលិន អាគ្រិខាល់ ឆ័រ ឌីវើលុបមិន (កម្ពុជា) ខូអិលធីឌី Green Island Agricultural Development (Cambodia) Co. Ltd | ក្រចេះ | ស្រុក សំបូរ | ក្បាលដំរី, រលោះមាន ជ័យ | ១៥/៣/២០០៦ | អាមេរិច |
| ៩.២១៤ | ផ្លែនថេសិន អាគ្រិខាល់ឆ័រ ឌីវើលុបមិន | ក្រចេះ | ស្រុក សំបូរ | រលោះមាន ជ័យ | ១១/៨/២០០៦ | អាមេរិច |

| | | | | | | |
|---|---|---|---|---|---|---|
| | (កម្ពុជា) ខូអិលធីឌី Plantation Agricultural Development (Cambodia) Co. Ltd. | | | | | |
| ៩.២៣១ | គ្រេត វុនឌើ អាគ្រិខាល់ ឆ័រ ឌីវើលុបមិន (កម្ពុជា) ខូអិលធីឌី Great Wonder Agricultural Development (Cambodia) Co. Ltd. | ក្រចេះ | ស្រុកសំបូរ | អូរគ្រៀង, រលោះមានជ័យ | ១១/៨/២០០៦ | ចិន |
| ១៥.៦៦៦ | សំបូរ ផ្លេនថេសិន ស្ដេសិន អែហ្វអេ Sambor Plantation Station FA | ក្រចេះ | ស្រុក សំបូរ | បឹងចារ, កំពង់ចាម | ១៣/៧/២០០៦ | ខ្មែរ |
| ៨.៩៨៥ | គ្រេត អាសិត អាគ្រិខាល់ ឆ័រ ឌីវើលុបមិន (កម្ពុជា)ខូអិលធីឌី Great Asset Agricultural Development (Cambodia) Ltd. | ក្រចេះ | ស្រុក សំបូរ | អូរគ្រៀង | ១១/៨/២០០៦ | ចិន |
| | ឈុង ហុង រ៉ាប់ប៊ើ Chhoung Hong Rubber | ក្រចេះ | ស្រុក សំបូរ | បឹងចារ | | វៀត ណាម/ កម្ពុជា |
| សម្បទានរុករករ៉ែមាស | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤.៩៨៥ | ឈុងហុង កូឈានពាន ខូអិលធីឌី ទឹកសុទ្ធ និងរុករករ៉ែមាស Chhong Kor Chhean Pean Co. Ltd. – Mineral resource exploration – gold mining | ក្រចេះ | ស្រុក សំបូរ | កោះខ្ញែរ, កោះខ្នែរ | ១៤/០១/២០០៥ | |
| | សាវធើន ហ្គោល អិលធីឌី Southern Gold Ltd. | ក្រចេះ | ស្រុក សំបូរ | ក្បាលដំរី, រលោះ មានជ័យ- ភ្នំខ្នុង | | អូស្ត្រាលី |
| | ស៊ីអាអិមជី- រុករករ៉ែមាស CIMG – Gold mining | ក្រចេះ | ស្រុក សំបូរ | បឹងចារ | | ចិន/ខ្មែរ គាំទ្រមូលនិធិ ដោយ ធនាគារ បារាំង |

*ប្រភព : http://www.elc.maff.gov.kh/overview.html ; http://cambodia.ohchr.org*

ស្រុកសំបូរ គឺប្រឈមនឹងបញ្ហាកាប់ឈើខុសច្បាប់ ហើយជាក់ស្តែងណាស់ ស្រុកនេះកំពុងតែទទួលរងផលប៉ះពាល់ដែលបណ្តាលមកពីគំរោងអភិវឌ្ឍន៍ថ្មី ដូចជាការវិនិយោគទុនបរទេសលើដីសម្បទានជាដើម ។ សហគមន៍ជនជាតិដើមភាគតិចទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីសកម្មភាពទាំងនេះ ។ ការអភិវឌ្ឍន៍នេះធ្វើអោយមានការរំខានយ៉ាងខ្លាំងដល់តំបន់បញ្ចុះសពអារក្សព្រៃរបស់ពួកគាត់ ហើយប៉ះពាល់ដល់តំបន់រស់នៅរបស់សត្វ តំបន់រកថ្នាំបុរាណ ការប្រមូលអនុផលព្រៃឈើដែលជាប្រភពនៃប្រាក់ចំណូល និងសកម្មភាពធ្វើចំការក្នុងព្រៃរបស់ពួកគាត់ ។

ការទទួលស្គាល់តម្លៃស្ត្រីក្នុងស្រុកសំបូរ គឺមិនមានទំហំស្មើគ្នាទៅនឹងបុរសនោះទេ។ ស្ត្រីជាទូទៅធ្វើការងារក្នុងផ្ទះដែលជាការងារគ្មានទទួលបានប្រាក់កំរៃ រីឯបុរសធ្វើការងារទាំងឡាយណាដែលទទួលបានប្រាក់កំរៃ ហើយចូលរួម ឬប្រឡូកក្នុងការងារសង្គមខាងក្រៅច្រើនជាងស្ត្រី។ នៅក្នុងគ្រួសារ បុរសទទួលបានការទុកចិត្ត និងគោរពជាងស្ត្រី ហើយក៏ដូចគ្នាក្នុងការងាររបស់សហគមន៍ទាំងមូលផងដែរ។ ភាពខុសគ្នាក្នុងផ្នែកយេនឌ័រនេះជាទូទៅជាផ្នែកមួយនៃបទដ្ឋានវប្បធម៌ និងការអនុវត្តន៍ក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។ យ៉ាងណាក៏ដោយក៏មានការខិតខំប្រឹងប្រែងពីក្រសួងកិច្ចការនារីក្នុងការបង្ហាញ និងផ្សព្វផ្សាយពីផលប៉ះពាល់អវិជ្ជមានជាច្រើនទាក់ទងនឹងភាពខុសគ្នារវាងបុរស និងស្ត្រី។ យ៉ាងណាមិញ ក្រសួងកិច្ចការនារី ក៏បានបង្កើតនូវច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងច្បាប់ស្តីពីសង្គមគ្រួសារ សំរាប់ប្រទេស ដែលបានយល់ព្រមអនុម័តដោយសន្និបាតថ្នាក់ជាតិ *(La,* ២០០៧*)*។ តែទោះជាយ៉ាងណាក៏ដោយរហូតមកដល់ពេលបច្ចុប្បន្ននេះការអនុវត្ត និងប្រតិបត្តិទៅលើច្បាប់នេះគឺនៅមានកំរិតនៅឡើយ។

## ៣.៣. ផែនការគំរោងសាងសង់ទំនប់វារីអគ្គិសនីសំបូរ

ស្រុកសំបូរ ត្រូវបានកំណត់ក្នុងផែនការជាទីតាំងរបស់គំរោងការសាងសង់ទំនប់វារីអគ្គិសនីសំបូរ ដែលមកទល់បច្ចុប្បន្ននេះ ព័ត៌មានដែលបានចែកចាយជាសាធារណៈជនទាក់ទងនឹងគំរោងនេះ គឺនៅមានកំរិត និងតិចតួចបំផុត។ យោងតាមក្រុមមេធាវីសិទ្ធ និងលិខិតរបស់វិទ្យាស្ថានតស៊ូមតិផ្នែកច្បាប់ទន្លេមេគង្គ ដែលបានដាក់ជូនគណៈកម្មាធិការទន្លេមេគង្គ កាលពីខែ ធ្នូ ឆ្នាំ ២០០៩ បានអោយដឹងថាការសិក្សាសក្តានុពលសេដ្ឋកិច្ចដំបូងដែលអាចធ្វើទៅបាននោះបានបញ្ចប់ និងដាក់បញ្ជូនទៅក្រសួង រីឯការសិក្សាហេតុប៉ះពាល់បរិស្ថានហៅកាត់ថា អ៊ី អាយ អេ (EIA) គឺកំពុងដំណើរការ។

មានទំរង់ពីរស្តីពីផែនការគំរោងសាងសង់ទំនប់វារីអគ្គិសនីសំបូរនេះ។ យោងតាមផែនការគណៈកម្មាធិការទន្លេមេគង្គក្នុងឆ្នាំ ២០០៤ បានអោយដឹងថា ដំបូងគំរោងនេះបានបំផុសគ្រោងនឹងផលិតកំលាំងថាមពលអោយបាន ៣.៣០០ម៉េកាវ៉ាត់ រីឯផែនការគំរោងសាងសង់ទំនប់វារីអគ្គិសនីបច្ចុប្បន្ននេះមានកំលាំងថាមពល ២.៦០០ម៉េកាវ៉ាត់ ហើយកំលាំងថាមពលថេរមាន ៤៦៥ម៉េកាវ៉ាត់។ មកដល់សព្វថ្ងៃនេះ នៅតែមិនច្បាស់នៅឡើយថា តើផែនការគំរោងមួយណាដែល

នឹងត្រូវដំណើការ ។ ទោះជាយ៉ាងណាក៏ដោយ យើងជឿជាក់ថាអាជ្ញាធរមូលដ្ឋានបានបង្ហាញពីការព្រួយបារម្ភរបស់ពួកគេជាច្រើនលើគំរោងដែលបានបំផុសនេះ ថានឹងផលិតថាមពលអគ្គិសនី ៣.៣០០ ម៉េកាវ៉ាត់ ហើយពួកគេក៏បានបង្ហាញពីជំរើសរបស់ខ្លួនដែលជ្រើសយកផែនការទីពីរដែលមានកំលាំងថាមពលអគ្គិសនីត្រឹម ២.៦០០ ម៉េកាវ៉ាត់ ។

ខាងក្រោមនេះ ជាតារាងបង្ហាញពីគំរោងទំនប់វ៉ារីអគ្គិសនីសំបូរដែលប្រៀបធៀបទៅនឹងគំរោងទំនប់វ៉ារីអគ្គិសនីសំបូរ ឆ្នាំ ២០០៤ របស់គណៈកម្មាធិការទន្លេមេគង្គ ។

**តារាងទី៣: គំរោងទំនប់វ៉ារីអគ្គិសនីសំបូរ**

| ការពិពណ៌នាពីគំរោង | គំនូសប្លង់បច្ចុប្បន្ន | ទិន្នន័យរបស់ MRC (១៩៩៤) |
|---|---|---|
| ឈ្មោះទំនប់ | សំបូរកម្ពុជា | |
| តំបន់ទីតាំងគំរោង<br>រយៈទទឹង ( ទីតាំងគំរោងទី២)<br>រយៈបណ្តោយ | ១២ ៤៧' N<br>១០៥ ៥៧' E | ១២៣ ៦,៥' N<br>១០៦ ១,0' E |
| ទិន្នន័យស្ថិតិរបស់ទំនប់ | | |
| កំពស់ | ៥៦ ម៉ែត្រ | ៣៥ ម៉ែត្រ |
| ប្រវែង | ១៨.០០២ម៉ែត្រ | ៣០.៦៦៤ម៉ែត្រ |
| ប្រភេទសំណង់ដែលត្រូវសាងសង់: ប៉េតុងស៊ីម៉ង់ និងចាក់ក្រួស | | |
| ភាពខុសគ្នារវាងច្រកទឹកហូរចូលពីអាងស្តុក និងច្រកបង្ហៀរទឹកចេញទៅក្រៅ | ១៦,៩ (២២,៩ – ៩,៥ ម៉ែត្រ អតិបរិមា និងអប្បបរិមា) | ៣២,៩ |
| បរិមាណទឹកដែលអាចបង្ហៀរចេញក្រៅ | ៤៤១,៧ x ៤០ = ១៧.៦៦៨ ម៉ែត្រគូប/វិនាទី | ១៩.១៦៣ |
| ចំនួនឯកតា ( តួប៊ីន) | ៤០ | |
| កំលាំងថាមពលសរុប ( តួប៊ិនទាំងអស់) | ៦៥ មេកាវ៉ាត់ x ៤០= ២.៦០០ | ៣.៣០០ |

| | | |
|---|---|---|
| | មេកាវ៉ាត់ | |
| ក្រុមហ៊ុន និងការផលិតថាមពលប្រចាំឆ្នាំ | | |
| ថាមពលប្រចាំឆ្នាំជាមធ្យម | ១១.៧៤០ Gwh | ១៤.៧៨០ |
| **របៀបនៃប្រតិបត្តិការ** | | |
| លក្ខណៈបន្ត និងផ្ទុក (បើករហូត ឬ បើកតាមតំរូវថការថាមពល) | បន្ត | |
| បើផ្ទុក (បើកតាមតំរូវការថាមពល), ចំនួនម៉ោងនៃប្រតិបត្តិការក្នុងមួយថ្ងៃ | ប្រចាំឆ្នាំមធ្យម ៤.៥១៥ម៉ោង = ១២,៣៧ ម៉ោង/ថ្ងៃ | |
| លំហូរលក្ខណៈធម្មជាតិ (លំហូរតាមធម្មជាតិ ទឹកហូរកាត់ទំនប់) | បន្ត | |
| ការរចនាផ្លូវបង្ហូរៈ បើកចំហរផ្លូវបង្ហូរ | | |
| ទឹកអតិបរិមាហូរចេញពីបំពង់បង្ហៀរ | | ១៤៩.៣០០ម៉ែត្រគូប/វិនាទី |
| បរិមាណទឹកខ្ពស់បំផុត ដែលអាចហូរចាក់ចូលបំពង់បង្ហូរ | | ១៦១.០០០ម៉ែត្រគូប វិនាទី |
| ប៉ាន់ប្រមាណពីកករក្នុងមួយឆ្នាំ | | |
| យន្តការក្នុងការសំអាតកករ, តើត្រូវមានយន្តការបែប ណាក្នុងសំអាកករនេះ | | |
| ខ្នាតទំហំនៃផ្ទៃបាតក្រោមសំរាប់បំពង់ បង្ហៀរ | | |
| ការរចនាប្រពន្ធ័ សំរាប់គ្រប់គ្រងលំហូរទឹកឆ្លងកាត់ | | |
| • ការសំអាតកករ | បង្ហូរចេញតាមទ្វារបង្ហូរទឹក ៣៧ម៉ែត្រគូប/វិនាទី | |
| • ការរចនាខ្នាតទ្វាបង្ហូរទឹក | កំពស់:១៥ម x ២០ម | |

| | | |
|---|---|---|
| | ១៥៩ម៉ែត្រគូប/វិនាទី=៥.៨៨៣ ម៉ែត្រគូប/វិនាទី | |
| គោលបំណង | | |
| ដើម្បីតំរូវការទឹកផ្សារថាមពលអគ្គិសនី | | |
| ក្នុងប្រទេស | ៣០% | |
| នាំចេញក្រៅប្រទេស | ៧០% | |
| ការពិចារណាលើការប្រើប្រាស់ផ្សេងៗ | ថាមពល, គ្រប់គ្រងទឹកជំនន់ និងនាវាចរណ៍ | |
| លំអិតពីការបញ្ជូលទឹកសំរាប់ការប្រើប្រាស់, ប្រសិនបើត្រូវពិចារណា (ម៉ែត្រគូប/វិនាទី ឬតំបន់នៃការបញ្ជូលទឹក) | | |
| អាងស្តុកទឹក | | |
| កំរិតអាងស្តុកទឹកពេញ | ៤០ masl | ៤០ |
| កំរិតអាងស្តុកទឹកទាប | ៣៩ masl | ៣៨ |
| តំបន់ដែលត្រូវលិចទឹកក្នុងអាងស្តុកទឹកពេញ | ៦២០ គីឡូម៉ែត្រការេ | |
| តួលេខនៃការស្តុកទឹកក្នុងអាងស្តុក | ៤៦៥ លានម៉ែត្រគូប | ២.០០០ |
| មេគុណអាងស្តុក | ០.១០៨% | |
| បរិមាណអាងស្តុកទឹក និងតំបន់ជុំវិញសំរាប់ស្តុកទឹក | ៣.៩៧៤ លានម៉ែត្រគូប | |
| ជម្រៅចុះក្រោម Draw down | ១ម៉ែត្រ | |
| បំរែបំរួលកំរិតទឹកក្នុងអាងស្តុកដែលអាចកើតមាន | ការធ្វើអោយទឹកក្នុងអាងមានលំនឹងគ្រប់ពេល | |
| ប្រវែងអាងស្តុកទឹក | | |
| ការសាងសង់ | | |

| | | |
|---|---|---|
| រយៈពេលសាងសង់ | ៨៧ ខែ | |
| តំរូវការផ្លូវចូល | | |
| ខ្សែបណ្តាញចែកចាយថាមពល | ៣x ២៦០ គីឡូម៉ែត្រ, ៥០០ kv to HCMC | |
| កំលាំងកម្មករសំរាប់សាងសង់ ( កម្មករជំនាញៈ គោលនយោបាយសំរាប់កម្មករក្នុងស្រុក) | មធ្យម ២.៧៩៩<br>អតិបរិមា ៣.០០០ | |
| ច្រកសំរាប់សំរួល ដល់ទូកឆ្លងកាត់ទំនប់ | ១០០ តោន - ប្រវែង ៤៨១ម៉ែត្រ, ទំហំ ៨ម៉ែត្រ ពី ៤០ masl -១៦ masl | |
| ទំហំជណ្តើរសំរាប់ត្រីឆ្លងកាត់ (fish pass) ចុះឡើង ( បញ្ចូលអោយមានកន្លែងចិញ្ចឹមផ្សោត) | ៣.៣៦៩.៨ ម៉ែត្រ | |
| **ផលប៉ះពាល់** | | |
| សរុបផ្ទៃកសិកម្មដែលត្រូវលិចទឹក ( តំបន់បញ្ចូលទឹក កសិកម្មផ្ទែកលើទឹកភ្លៀង ចំការដំណាំធំៗ) | ៣.៣៦៩ ហិកតា | |
| សរុបតំបន់ព្រៃឈើ | ១៣.១៤៣ ហិកតា | |
| ចំនួនសហគមន៏, ផ្ទះ និងចំនួនមនុស្សត្រូវតាំងទីលំនៅថ្មី | ១៩.០៣៤ | ៥.១២០ |
| ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវលិចទឹកក្នុងអាងស្តុកទឹក ( តំបន់លំនៅឋាន, ផ្លូវថ្នល់ និងផ្លូវលំ, អគារ រដ្ឋាភិបាល, មន្ទីរពេទ្រ, សាលារៀន និងវត្តអារាម ជាដើម ។ល ។) | ២៤.៣៥១ គីឡូម៉ែត្រការ៉េ | |
| **តម្លៃ** | | |
| តម្លៃប៉ាន់ប្រមាណសំរាប់សង់ទំនប់ | ៤.៩៤៧ លានដុល្លា | |

| | | |
|---|---|---|
| បណ្ដាញចែកចាញថាមពល | ៣១២.៩ លានដុល្លា | |
| ប៉ាន់ប្រមាណតម្លៃលើផលប៉ះពាល់បរិស្ថាន និងសង្គម | | |
| សង្គមរួមបញ្ចូលទាំងការតាំងទីលំនៅថ្មី | ៨០,៣៣ លានដុល្លា សំរាប់ មនុស្ស ១០.០០០ នាក់ត្រូវ តាំង ទីលំនៅថ្មី ឬ ប្រហែលជាច្រើន ជាងនេះទ្វេរដង | |
| ពរិស្ថាន | ២១,២៤លានដុល្លា | |
| តម្លៃក្នុងមួយគីឡូវ៉ាត់ | ១.៦៨៥/គីឡូវ៉ាត់ | |
| តម្លៃគីឡូវ៉ាត់ក្នុងមួយម៉ោង | ០,៣៧៣-០,៣៩៨ដុល្លា/ គីឡូវ៉ាត់ | |
| តម្លៃថាមពលក្នុងមួយម៉ោង | ៧,២៣-៧,៩៧សេន/គីឡូវ៉ាត់ | |
| ភាគរយនៃសក្តានុពលសេដ្ឋកិច្ច (IRR, Internal Rate of Return) | ១៣,០% | |
| រយៈពេលនៃកិច្ចព្រមព្រៀងកំចី | ២៥ ឆ្នាំ | |

*ប្រភព : CNMC, ២០០៩*

# ៤. ការស្ទង់មតិ




*ផែនទី៣: ផែនទីស្រុកសំបូរបង្ហាញភូមិចំនួន៦ក្នុងការសិក្សាស្រាវជ្រាវ*

លទ្ធផលដែលរកឃើញពីការស្ទង់មតិ បានបង្ហាញអោយពីព័តិមានស្តីពីជីវភាពរស់នៅក្នុងភូមិគោលដៅធំៗ។ ការរៀបរាប់ពីលទ្ធផលរកឃើញនេះ មើលទៅមិនសូវជា បានទូលំទូលាយប៉ុន្មានទេ តែទោះជាយ៉ាងណាក៏ដោយ គឺវាមានន័យគ្រប់គ្រាន់ នឹងអាចយល់បានពីស្ថានភាពនៃភូមិគោលដៅនីមួយៗ ដែលបានសិក្សា។ ការរៀបរាប់ទាំងនេះមានដូចជា ព័តិមានខាងប្រជា-សាស្ត្ររបស់ភូមិនីមួយៗ ប្រភពនៃប្រាក់ចំណូល និងជីវភាពសេវាកម្មសង្គមមូលដ្ឋានសកម្ម-ភាពរបស់ស្ត្រី ព្រៃឈើ និងធនធានរបស់វាការប្រើប្រាស់គំរោងអភិវឌ្ឍន៍ក្នុងស្រុក និងថាមពលអគ្គិសនី។

## ៤.១. ព័ត៌មានប្រជាសាស្ត្រក្នុងភូមិគោលដៅទាំង៦

ព័តិមានប្រជាសាស្ត្រនៃភូមិគោលដៅនីមួយៗត្រូវបានបង្ហាញ និងលើកឡើងពីចំនួនប្រជាជន ដី រួមបញ្ចូលទាំងតំបន់ដីស្រែ សួនដំណាំតាមច្រាំងទន្លេ ដែលជារបរសំខាន់សំរាប់

ប្រជាជនក្នុងស្រុក និងដីជាកម្មសិទ្ធិ។ ជាងនេះទៅទៀត ក៏មានព័ត៌មានបង្ហាញពីចំងាយផ្លូវពីភូមិនីមួយៗមកកាន់ទីរួមស្រុកសំបូរនិងទៅទីរួមខេត្តក្រចេះផងដែរ។ ព័ត៌មានទាំងអស់នេះត្រូវបានរៀបចំសង្ខេបក្នុងតារាងខាងក្រោមនេះ។ ផ្នែកតទៅនឹងមានរៀបរាប់សង្ខេបអំពីប្រវត្តិ និងព័ត៌មានសំខាន់ៗជាមូលដ្ឋាននៃភូមិនីមួយៗ។

**តារាងទី៤: ព័ត៌មានប្រជាសាស្ត្រនៃភូមិទាំង៦**

| ឈ្មោះភូមិ | យារ | កោះសំ | សំភិន | កោះផ្ដៅ | ដីរ | ខ្សាច់លាវ |
|---|---|---|---|---|---|---|
| ចំនួនប្រជាជនសរុប | ១.៥២១ | ៧៧១ | ១.២១៧ | ៨៥៦ | ៣៥១ | ៣៣៦ |
| ចំនួនស្ត្រីសរុប | ៨១៨ | ៣៩៤ | ៦៤៧ | ៤២៣ | ១៨១ | ១៨៤ |
| ចំនួនបុរសសរុប | ៧០៣ | ៣៧៧ | ៥៧០ | ៤៣៣ | ១៧០ | ១៥២ |
| ចំនួនផ្ទះសរុប | ៣០៥ | ១៦៩ | ២៥៥ | ១៦៣ | ៦៣ | ៧១ |
| ផ្ទៃដីសរុប | គ្មានទិន្នន័យ | បណ្ដោយ ៤.៧០០ ម៉ែត្រ | បណ្ដោយ ៥.៥ គីឡូម៉ែត្រ ទទឹង= ១ គីឡូម៉ែត្រ | គ្មានទិន្នន័យ | ៨៦ ហិកតា | ១.៨៦៣ ហិកតា |
| ដីស្រែសរុប | ១៦១ ហិកតា | ២០៩ ហិកតា | ១៥៧ ហិកតា | ៧១,៣៣ ហិកតា | ៧៥ ហិកតា | ៥៩ ហិកតា |
| ដីសួនដំណាំសរុប | ១០ ហិកតា | ៦ ហិកតា | ១២ ហិកតា | ៧,៧៨ ហិកតា | ៥ ហិកតា | ៥ ហិកតា |
| តំបន់លំនៅឋានសរុប | ១៧៤ ហិកតា | គ្មានទិន្នន័យ | គ្មានទិន្នន័យ | ៨,៩២ ហិកតា | ៤ ហិកតា | បណ្ដោយ ៦០ម៉ែត្រ ទទឹង ២០ម៉ែត្រ |
| តំបន់ព្រៃសរុប | គ្មានទិន្នន័យ | គ្មានទិន្នន័យ | គ្មាន | គ្មាន | គ្មានទិន្នន័យ | ១.៧៥៤ ហិកតា |
| តំបន់សម្បទានសរុប | គ្មានទិន្នន័យ | មិនច្បាស់ | គ្មាន –កោះ | គ្មាន- កោះ | គ្មាន | គ្មានទិន្នន័យ |

| | | | | | | |
|---|---|---|---|---|---|---|
| ក្រុមហ៊ុនសម្បទាន | គ្មានទិន្នន័យ | គ្មានទិន្នន័យ | គ្មាន | គ្មាន | គ្មាន | គ្មានទិន្នន័យ |
| ចំងាយផ្លូវទៅស្រុកសំបូរ | ៣គីឡូម៉ែត្រ | ៤គីឡូម៉ែត្រ | ៥គីឡូម៉ែត្រ | ១០ គីឡូម៉ែត្រ | ៩ គីឡូម៉ែត្រ | ១១៤ គីឡូម៉ែត្រ |
| ចំងាយផ្លូវទៅខេត្តក្រចេះ | ៣០ គីឡូម៉ែត្រ | ៣៩ គីឡូម៉ែត្រ | ៣១ គីឡូម៉ែត្រ | ៤៦ គីឡូម៉ែត្រ | ៤៥ គីឡូម៉ែត្រ | ១០៤ គីឡូម៉ែត្រ |
| ដីជាកម្មសិទ្ធិឯកជន | ដីជាកម្មសិទ្ធិ តែគ្មានប័ណ្ណកម្មសិទ្ធិ | ដីជាកម្មសិទ្ធិ តែគ្មានប័ណ្ណកម្មសិទ្ធិ | ដីជាកម្មសិទ្ធិ តែគ្មានប័ណ្ណកម្មសិទ្ធិ | ដីជាកម្មសិទ្ធិ តែគ្មានប័ណ្ណកម្មសិទ្ធិ | ដីជាកម្មសិទ្ធិ តែគ្មានប័ណ្ណកម្មសិទ្ធិ | ដីជាកម្មសិទ្ធិ តែគ្មានប័ណ្ណកម្មសិទ្ធិ |

*ប្រភព: ការសិក្សានេះ ឆ្នាំ ២០១០*

### ៤.១.១. ភូមិយារ

ភូមិយារ គឺជាភូមិមួយដែលឋិតនៅក្នុងឃុំកំពង់ចាម មានចំងាយពីស្រុកសំបូរ ៣ គីឡូម៉ែត្រ។ កាលពីមុនភូមិនេះ ត្រូវបានគេហៅថា **ភូមិអូរយារ** និងបានប្តូរឈ្មោះមកជាភូមិយារក្នុងសម័យរបបខ្មែរក្រហម។ ឈ្មោះភូមិយារនេះ ត្រូវបានដាក់ឈ្មោះតាមប្រឡាយមួយក្នុងភូមិ។ បើយោងតាមសំដីនៃការសាកសួរព័ត៌មានពីបុរសចំណាស់អាយុ៦០ឆ្នាំ ម្នាក់ក្នុងភូមិបានអោយដឹងថា ប្រជាជនភាគច្រើនក្នុងភូមិយារនេះ ជាអ្នកដែលមានកំណើតក្នុងភូមិនេះតែម្តង។ តែទោះជាយ៉ាងណាក៏ដោយកាលពីពីរ ឬបីឆ្នាំមុននេះ ក៏មានជនចំណូលស្រុកមករស់នៅក្នុងភូមិនេះ ក្នុងគោលបំណងមកកសាងជីវភាពដ៏ប្រសើរមួយសំរាប់ជីវិតរបស់ពួកគេដែរ។

ប្រជាជនប្រមាណជា៨០%នៃប្រជាជនសរុបទាំងអស់ក្នុងភូមិយារនេះ គឺពឹងអាស្រ័យលើសកម្មភាពពីរធំៗរួមបញ្ចូលគ្នា ដូចជាការកាប់ឈើក្នុងព្រៃ និងធ្វើការជាកម្មករស៊ីឈ្នួលអោយក្រុមហ៊ុនរុករករ៉ែដែលហៅថា ខេមបូឌា អ៊ិនធើណាសុនណាល់ម៉ាញ៉ីងគ្រុប,ស៊ី អាយ អឹម ជី (Cambodia International Mining Group, CIMG) ឬផ្សងព្រេងរុករករ៉ែមាស ដោយខ្លួនឯងនៅភ្នំជី និងស៊ីឈ្នួលដាំដំណាំអោយគេ ដើម្បីធ្វើជាប្រភពរកប្រាក់ចំណូលគ្រួសារ។ ក្នុងកំឡុងពេលសាកសួរព័ត៌មានដែលប្រមូលបាននោះមិនសូវជាច្បាស់ប៉ុន្មានទេ ដោយសារតែប្រជាជនភាគច្រើនបានទៅស៊ីឈ្នួលកាត់ ឬរំលំដើមឈើអោយក្រុមហ៊ុនសម្បទានក្នុងព្រៃដើម្បី

ធ្វើការដាំដុះដំណាំ។ ទោះជាយ៉ាងណាក៏ដោយ ក៏មានការឆ្លើយតបមួយចំនួនបានចង្អុលបង្ហាញថា ពួកគេបានចំណាយប្រាក់ ៥០ដុល្លា បង់ជូនដល់ អាជ្ញាធរមូលដ្ឋាន ដើម្បីសុំការអនុញ្ញាតអោយបានកាប់ឈើក្នុងព្រៃដែលជាសកម្មភាពកាប់ឈើខុសច្បាប់។

ភាគច្រើន អ្នកភូមិក្នុងភូមិយាវនេះ មិនបានពឹងផ្អែកលើរបរធ្វើស្រែចំការ និងការនេសាទត្រីធ្វើជាប្រភពរកប្រាក់ចំណូលដ៏ចំបងរបស់ពួកគេនោះទេ ប៉ុន្តែយើងឃើញថាអ្នកភូមិមានស្រែ និងចំការស្ទើរតែគ្រប់ផ្ទះ និងមានការចូលរួមសកម្មភាពនេសាទត្រីផងដែរ។ ក្នុងមួយគ្រួសារជាមធ្យមមានដីចំការជាកម្មសិទ្ធិ ០,៥ ហិកតា ថ្វីបើយ៉ាងនេះក្តី ក៏មានអ្នកភូមិ ពីរ ឬបីគ្រួសារមានដីស្រែជាកម្មសិទ្ធិ ១,៥-៣ ហិកតាដែរ។ ផលស្រូវដែលប្រមូលបានភាគច្រើន សំរាប់ផ្គត់ផ្គង់តំរូវការក្នុងគ្រួសារប៉ុណ្ណោះតែក៏មានគ្រួសារមួយចំនួនបានលក់អោយទីផ្សារដែរ ពិសេសនៅពេលដែលមានសមាជិកគ្រួសារណាម្នាក់ឈឺ។



*រូបភាពទី១: ដីស្រែរបស់កសិករ*

### ៤.១.២. ភូមិកោះសំ

ភូមិកោះសំ គឺជាភូមិមួយដែលមានទីតាំងនៅក្នុងឃុំសំបូរ។ យោងតាមព័ត៌មានដែលទទួលបានពេលសាកសួរជាមួយបុរសចំណាស់អាយុ៦៦ឆ្នាំម្នាក់ក្នុងភូមិបានអោយដឹងថា អ្នកភូមិភាគច្រើនក្នុងភូមិនេះគឺជាមនុស្ស ដែលមានដើមកំណើតនៅក្នុងភូមិនេះផ្ទាល់តែម្តង។ ភូមិកោះសំមានទីតាំងឋិតនៅក្បែរភូមិយាវ និងមានចំងាយប្រមាណជា ៤គីឡូម៉ែត្រ ពីស្រុកសំបូរដោយធ្វើ

ដំណើរដោយទូកតាមទន្លេមេគង្គ។ ប្រជាជនមួយចំនួនធំប្រកបរបរធ្វើស្រែចំការ នេសាទត្រី ដាំបន្លែតាមច្រាំងទន្លេ និងចិញ្ចឹមសត្វផ្សេងៗសំរាប់គាំទ្រដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

ប្រជាជនបានរាយការណ៍ថា ពួកគេទៅនេសាទត្រីជារៀងរាល់ថ្ងៃ និងរកបានត្រីពី ១-២ គីឡូក្រាមប៉ុណ្ណោះក្នុងមួយថ្ងៃ។ អ្នកភូមិមានដីស្រែជាមធ្យម១ហិកតា និងមានពីរ ឬបីគ្រួសារមានដីស្រែ ១,៨ហិកតា។ ផលស្រូវដែលប្រមូលបានគឺសំរាប់ផ្គត់ផ្គង់តំរូវការក្នុងគ្រួសារប៉ុណ្ណោះ។ មានប្រជាជនចំនួន ២០គ្រួសារក្នុងភូមិបានពឹងផ្អែកលើរបរនេសាទត្រីធ្វើជាប្រភពរកប្រាក់ចំណូលគ្រួសារដ៏ចំបងបំផុតរបស់ពួកគេ។ ពួកគេធ្វើការនេសាទជាក្រុមដែលធ្វើដំណើរទៅនេសាទប្រមាណជា១០គីឡូម៉ែត្រ ឆ្ងាយពីភូមិ ហើយទៅនេសាទម្តងមានរយះពេល១០ថ្ងៃទើប ត្រឡប់មកវិញជាមួយនឹងផលត្រីដែលចាប់បានពី ៣០-៤០គីឡូក្រាមក្នុងមួយលើកៗ។ ប៉ុន្តែក៏នៅមានអ្នកភូមិមួយចំនួនបានទៅស្វែងរកការងារនៅខាងក្រៅធ្វើជាកម្មករស៊ីឈ្នួលក្នុងការដាំដំណាំផ្សេងៗ ដើម្បីរកប្រាក់ចំណូលបន្ថែមសំរាប់គ្រួសារផងដែរ។ ទោះជាយ៉ាងណាក៏ដោយមានអ្នកភូមិជាច្រើនបានបង្ហាញប្រាប់អោយដឹងថា ពួកគេបានចូលកាប់ឈើក្នុងព្រៃ និងបរបាញ់សត្វ ដើម្បីលក់ប្តូរយកប្រាក់ផងដែរ ហើយសត្វដែលពួកគេបរបាញ់នោះភាគច្រើនជាសត្វជ្រូកព្រៃ ទន្សាយ និងឈ្លូសជាដើម។ អ្នកភូមិបានបញ្ជាក់ទៀតថា សត្វព្រៃដូចជាពពួកជ្រូកព្រៃ និងទន្សាយនេះ បានបំផ្លាញដំណាំស្រូវរបស់ពួកគេ ពិសេសដំណាំស្រូវទុំរៀបនឹងច្រូតកាត់ ហើយពួកគេចាប់យកសត្វទាំងនេះធ្វើជាអាហារ និងលក់ប្តូរយកប្រាក់។ យ៉ាងណាមិញ សព្វថ្ងៃនេះ មានកម្មវិធីអភិរក្សលើសត្វព្រៃនៅក្នុងស្រុក តែការអនុវត្តន៏លើការងារទប់ស្កាត់នោះនៅមានចន្លោះ និងទន់ខ្សោយនៅឡើយទេ។



*រូបភាពទី២: សកម្មភាពនេសាទរបស់អ្នកភូមិ*

### ៤.១.៣. ភូមិសំភិន

ភូមិសំភិននេះ កាលពីដើមឡើយត្រូវបានគេហៅថា **ភូមិវាលខ្ទង** តែក្រោយមកបានប្តូរឈ្មោះភូមិនេះមកជា **ភូមិសំភិន** នៅក្នុងរបបខ្មែរក្រហម ហើយឈ្មោះភូមិសំភិននេះត្រូវបានដាក់តាមឈ្មោះប្រឡាយមួយដែលឋិតនៅក្នុងភូមិសំភិននេះតែម្តង។ ភូមិសំភិនមានចំងាយ ៥គីឡូម៉ែត្រពីទីរួមស្រុកសំបូរ និងមានទីតាំងឋិតនៅលើកោះមួយ។ កោះនេះ ឋិតនៅចំកណ្តាលទន្លេមេគង្គ និងបានបំបែកទន្លេមេគង្គអោយបែកចេញជាពីរនៅចំកន្លែងកោះនេះ។ ភូមិសំភិន ជាភូមិមួយក្នុងចំណោមភូមិនានាក្នុងឃុំកំពង់ចាម។ ការសិក្សាស្រាវជ្រាវនេះបានបញ្ជាក់អោយឃើញថាមានវត្តមាន ជនជាតិដើមភាគតិចរស់នៅក្នុងភូមិនេះ ដូចជាក្រុមភ្នង គួយ និងក្រោលជាដើម តែទោះជា យ៉ាងណាក៏ដោយអ្នកភូមិទាំងអស់នាពេលបច្ចុប្បន្ននេះ ត្រូវបានទទួលស្គាល់ថា ជនជាតិខ្មែរទៅហើយ។

សកម្មភាពចំបងសំរាប់ទ្រទ្រង់ជីវភាពរស់នៅរបស់អ្នកភូមិសំភិននេះ មានដូចជាសកម្មភាពធ្វើស្រែចំការ ការនេសាទត្រី ដាំបន្លែក្នុងសួនបន្លែតាមច្រាំងទន្លេ និងចិញ្ចឹមសត្វផ្សេងៗ ដូចជាគោក្របី ជ្រូក មាន់ ទា ជាដើម។ អ្នកភូមិទៅនេសាទត្រីជារៀងរាល់ថ្ងៃ និងអាចចាប់ត្រីបានពី ១-២ គីឡូក្រាមក្នុងមួយថ្ងៃ។ ក្នុងមួយគ្រួសារមានដីស្រែចំការជាមធ្យម ១ហិកតា ហើយផលស្រូវដែលប្រមូលបានគឺសំរាប់ផ្គត់ផ្គង់ក្នុងគ្រួសារ និងយកទៅលក់ឱ្យទីផ្សារ ប្រសិនបើមានសមាជិកណាម្នាក់ឈឺនោះ។ ប្រភពប្រាក់ចំណូលមួយទៀតសំរាប់អ្នកភូមិសំភិននេះ គឺការស្វែងរកការងារជាកម្មករស៊ីឈ្នួលដាំស្រូវ ឬដំណាំផ្សេងៗអោយអ្នកនៅក្នុងភូមិនេះផ្ទាល់ ឬអ្នកភូមិជិតខាង។



*រូបភាពទី៣: សកម្មភាពកសិកម្មរបស់ស្ត្រីនៅក្បែរភូមិ*

អ្នកភូមិជាច្រើនក្នុងភូមិសំភិននេះ បានចូលរួមក្នុងសកម្មភាពរបស់គំរោងអេកូទេសចរណ៍សហគមន៍របស់អង្គការក្នុងស្រុកមួយដែលមានឈ្មោះថា អង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា ដែលប្រចាំការក្នុងខេត្តក្រចេះនេះ។ អ្នកភូមិបានរាយការណ៍ថា ជាញឹកញាប់ពួកគេធ្វើការអភិរក្សលើសត្វផ្សោតទឹកសាបនៅជុំវិញបរិវេណ និងតំបន់ក្បែរៗភូមិ។ ភូមិនេះ ត្រូវបានកំណត់ និងចាត់ទុកថាជាតំបន់អភិរក្សសត្វផ្សោត ហើយសព្វថ្ងៃនេះមានគំរោងមួយ ដែលគាំទ្រដោយមូលនិធិសង្គ្រោះសត្វព្រៃសាកល (WWF) សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការងារអភិរក្សសត្វផ្សោតក្នុងតំបន់នេះ។ អ្នកភូមិខ្លះត្អូញត្អែរពីការឆាឆៅ ឬយាយីពីគំរោងអភិរក្សថ្មីនេះ មកលើសកម្មភាពនៃការនេសាទត្រីបែបប្រពៃណីរបស់ពួកគេដែលធ្លាប់អនុវត្តតាំងពីដើមមក និង បានធ្វើការហាមឃាត់លើសកម្មភាព នេសាទត្រីមួយចំនួន។

### ៤.១.៤. ភូមិកោះផ្តៅ

ឈ្មោះ **ភូមិកោះផ្តៅ** ត្រូវបានគេដាក់ដោយយកតាមឈ្មោះកោះមួយដែលអ្នកភូមិតែងទៅរកផ្តៅ និងឋិតនៅមិនឆ្ងាយពីភូមិកោះផ្តៅនេះប៉ុន្មាននោះទេ។ ភូមិកោះផ្តៅឋិតនៅលើកោះមួយបន្ទាប់ពីភូមិសំភិនទៅប្រមាណជា១០គីឡូម៉ែត្រ ពីទីរួមស្រុកសំបូរ។ គំរោងអេកូទេសចរណ៍សហគមន៍របស់អង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា ក៏មានអនុវត្តក្នុងភូមិនេះផងដែរ។

អ្នកភូមិជាច្រើនបានរាយការណ៍អោយដឹងថា ភូមិនេះសម្បូរណ៍អន្លង់ជ្រៅៗ និងទឹកជួរជាច្រើន ហើយពួកគេធ្វើការអភិរក្សលើសត្វផ្សោតក្នុងទន្លេមេគង្គដែលនៅក្បែរបរិវេណភូមិ។ ភូមិកោះផ្តៅ ក៏បានកំណត់ថាជាតំបន់ អភិរក្សសត្វផ្សោតរបស់គំរោងដែលគាំទ្រដោយ WWF និង WCS សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការអភិរក្សសត្វផ្សោតក្នុងតំបន់នេះ។ អ្នកភូមិកោះផ្តៅបានលើកឡើងពីការត្អូញត្អែរមួយចំនួនស្រដៀងគ្នាទៅនឹងការត្អូញត្អែររបស់អ្នកភូមិសំភិនដែរ ពីការឆាឆៅ ឬយាយីលើសកម្មភាពនេសាទត្រីលក្ខណៈប្រពៃណីរបស់ពួកគេពីវិធានការណ៍នៃការអភិរក្ស ដែលបានធ្វើការហាមឃាត់លើការនេសាទមួយចំនួនធ្វើអោយប៉ះពាល់ដល់ការរកប្រាក់ចំណូលរបស់ពួកគេ។

សកម្មភាពចំបងសំរាប់គាំទ្រជីវភាពរស់នៅរបស់ពួកគេមាន ដូចជាការប្រកបរបរធ្វើស្រែចំការ ការនេសាទត្រី ការចិញ្ចឹមសត្វផ្សេងៗ ធ្វើសួនដាំបន្លែតាមច្រាំងទន្លេ និងស្វែងរកការងារ

ជាកម្មករស៊ីឈ្នួលគេនៅក្រៅភូមិជាដើម។ អ្នកភូមិជាច្រើនទៅនេសាទត្រីជារៀងរាល់ថ្ងៃ និងអាចរកត្រីបានពី ១-២គីឡូក្រាម ក្នុងមួយថ្ងៃ។ អ្នកភូមិមានដីស្រែចំការជាមធ្យម ០,៧ ហិកតា ហើយផលស្រូវដែលប្រមូលបានគឺប្រើប្រាស់សំរាប់ផ្គត់ផ្គង់ក្នុងគ្រួសារ ប៉ុន្តែមានកត្តាមួយចំនួនបានជំរុញអោយអ្នកភូមិលក់ផលស្រូវខ្លះរបស់ពួកគេដែរ ពិសេសនៅពេលដែលមានសមាជិកគ្រួសារណាម្នាក់ឈឺ។

### ៤.១.៥. ភូមិដីរ

ឈ្មោះ**ភូមិដីរ**នេះត្រូវបានគេហៅតាមដីរចំណាស់មួយក្បាលក្នុងភូមិ ដែលអ្នកភូមិទាំងអស់បានប្រើប្រាស់ដីរ មួយក្បាលនេះដើម្បីរស់នៅ។ អ្នកភូមិបានផ្លាស់ប្តូរមករស់នៅក្នុងភូមិដីរថ្មីក្នុងឆ្នាំ ១៩៨០ បន្ទាប់ពីសម័យរបបខ្មែរក្រហម។ ភូមិនេះ ជាភូមិមួយឋិតនៅក្នុងឃុំបឹងចារ និងមានចំងាយប្រមាណជា ៩គីឡូម៉ែត្រពីទីរួមស្រុកសំបូរ។ ប្រជាជនក្នុងភូមិ មានចំនួន ៦៣គ្រួសារ ដែលសុទ្ធតែជាជនជាតិកួយ ប៉ុន្តែឥឡូវនេះពួគេគឺជាជនជាតិខ្មែរ តែទោះជាយ៉ាងណាក៏ដោយ អ្នកភូមិទាំងនេះ នៅតែរក្សាបាននូវពិធីបុណ្យសែនព្រេនអារក្សអ្នកតារបស់ពួកគេដដែល និងប្រតិបត្តិបានយ៉ាងខ្ជាប់ខ្ជួន។

សកម្មភាពចំបងសំរាប់គាំទ្រជីវភាពរស់នៅរបស់អ្នកភូមិមានដូចជាការប្រកបរបរ ធ្វើស្រែចំការ ការនេសាទត្រី ធ្វើសួនដំាបន្លែតាមច្រាំងទន្លេមេគង្គ ការចិញ្ចឹមសត្វផ្សេងៗដូចជាគោ ក្របី ជ្រូក មាន់ ទា ការកាប់ឈើក្នុងព្រៃ ដើម្បីលក់ប្តូរយកប្រាក់ និងធ្វើជាកម្មករស៊ីឈ្នួលធ្វើការអោយអ្នកដទៃផងដែរ។ ជាងនេះទៅទៀតអ្នកភូមិខ្លះបានរកប្រាក់ចំណូលតាមរយៈការបរបាញ់សត្វព្រៃ និងដងជ័រទឹកលក់។ ប្រជាជន៧០%នៃប្រជាជនសរុបក្នុងភូមិ បានទៅនេសាទត្រីជារៀងរាល់ថ្ងៃ ដែលអាចរកត្រីជាមធ្យមពី ១-២គីឡូក្រាមក្នុងមួយថ្ងៃ។ អ្នកភូមិភាគច្រើន មានដីស្រែចំការជាកម្មសិទ្ធិជាមធ្យម ០,៧ហិកតា។ ទោះជាយ៉ាងណាក៏ដោយមានអ្នកភូមិចំនួន ១០ គ្រួសារមានដីស្រែចំការជាកម្មសិទ្ធិ ០,២ហិកតា និង៣០គ្រួសារទៀតមានដីស្រែជាកម្មសិទ្ធិ ០,៣ហិកតា។ យើងរកឃើញថា មានប្រជាជន ១០% នៃប្រជាជនសរុបក្នុងភូមិ បានធ្វើសួនដំាបន្លែតាមច្រាំងទន្លេ។



*រូបភាពទី៨: សកម្មភាពអ្នកភូមិស្រោចសួនដាំបន្លែតាមច្រាំងទន្លេ*

### ៤.១.៦. ភូមិខ្សាច់លាវ

ភូមិខ្សាច់លាវបានកើតឡើងតាំងពីសម័យអាណានិគមនិយមបារាំងមកម្លេះ។ អាណានិគមជនជាតិបារាំង បានហៅភូមិនេះថា **ភូមិខ្សាច់លាវ** ដោយសារតែកាលនោះ មានជនជាតិលាវមកនេសាទត្រីនៅបរិវេណភូមិនេះ ហើយបានដេកសំរាកលើវាលខ្សាច់ក្នុងទន្លេទើបហៅភូមិនេះថា ភូមិខ្សាច់លាវរហូតដល់សព្វថ្ងៃ។ ភូមិខ្សាច់លាវ មានប្រជាជនរស់នៅតិចជាងគេបំផុតក្នុងចំណោមភូមិគោលដៅទាំងប្រាំមួយ តែភូមិនេះមានទំហំដីដ៏ធំធេង (១.៨៦៣ហិកតា) បើប្រៀបធៀបទៅនឹងភូមិផ្សេងៗទៀតដែលបានចុះទៅសិក្សាធ្វើការស្ទង់មតិ។ ភូមិខ្សាច់លាវ ជាភូមិមួយឋិតនៅក្នុងឃុំអូរគ្រៀង មានចំងាយប្រមាណជា ១១៤ គីឡូម៉ែត្រពីទីរួមស្រុកសំបូរ។ ភូមិនេះមានប្រជាជន ៧១គ្រួសារដែលជាជនជាតិគួយ តែឥឡូវនេះពួកគេគឺជាខ្មែរ។ ប្រជាជនភូមិខ្សាច់លាវបានបន្តថែរក្សានូវទំនៀមទំលាប់ប្រពៃណីរបស់ពួកគេរហូតតរៀងមក និងមានប្រារព្ធពិធីបុណ្យសែនព្រេនអារក្សអ្នកតាផ្សេងៗ ដូចជាអារក្សព្រៃ ពិធីកប់ខ្មោច ការសែនចំការក្នុងព្រៃដែលពួកគេតែងតែផ្លាស់ប្តូរចំការរៀងរាល់៣ឆ្នាំម្តង។ តាមការសាកសួរពីអ្នកភូមិចំនួនបីលើកយើងនៅតែរកមិនឃើញពីទំហំនៃផ្ទៃដីចំការរបស់អ្នកភូមិក្នុងភូមិខ្សាច់លាវនេះ។

ភូមិខ្សាច់លាវមានទីតាំងឋិតនៅក្បែរតំបន់ព្រៃធំមួយប្រមាណជា ៦គីឡូម៉ែត្រ ឆ្ងាយពីតំបន់ព្រៃធំនោះ ហើយប្រជាជនភាគច្រើនបានមកធ្វើចំការជាលក្ខណៈចំការវិលជុំនៅក្នុងតំបន់ព្រៃធំនេះ។ អ្នកភូមិជាច្រើនបានកាប់ឈើក្នុងព្រៃដើម្បីចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

ទោះជាយ៉ាងណាក៏ដោយ ក៏មានការបញ្ជាក់មួយបានបង្ហាញអោយដឹងថា មានប្រជាជនមួយចំនួនធ្វើការអោយក្រុមហ៊ុនសម្បទាន ធ្វើជាអ្នកកាប់រំលំឈើដើម្បីយកដីធ្វើជាចំការដាំដំណាំអោយក្រុមហ៊ុនសម្បទាននោះ។ ការសិក្សានេះ ក៏បានរកឃើញផងដែរថាមានវត្តមានសកម្មភាពបរបាញ់សត្វលក់ធ្វើជាប្រភពប្រាក់ចំណូលគ្រួសារ ហើយសត្វដែលគេចាប់នោះមានដូចជា អណ្តើក ត្រកួត ពស់ ឈ្លូស និងសត្វស្វា (ពណ៌ខ្មៅ និងពណ៌ស)ដែលសត្វទាំងនោះ ត្រូវបានប្រមូលទិញដោយឈ្មួញមកពី ខាងក្រៅ តែមិនមែនជាមនុស្សដែលមកពីភូមិក្បែរនោះទេ។

យើងបានរកឃើញថា អ្នកភូមិទាំងអស់មានប្រកបរបរធ្វើស្រែចំការ ដាំដំណាំស្រូវទាំងនៅក្នុងភូមិ និងនៅក្នុងព្រៃ ហើយមានវត្តមានសកម្មភាពនេសាទត្រី ព្រមទាំងការចិញ្ចឹមសត្វផ្សេងៗដូចជា គោ ក្របី ជ្រូក មាន់ និង ទា ជាដើម។ មួយគ្រួសារមានដីស្រែកម្មសិទ្ធិជាមធ្យម ១,៥ ហិកតា (មួយហិកតាកន្លះ)។ ប្រជាជនស្ទើរតែគ្រប់គ្រួសារនៅក្នុងភូមិបានប្រកបរបរនេសាទត្រី ប៉ុន្តែប្រជាជន ៤០គ្រួសារបានបង្ហាញឱ្យយើងដឹងថា ការនេសាទត្រីនេះ គឺជាសកម្មភាពចំបងសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ អ្នកភូមិខ្សាច់លាវទាំងអស់បានចិញ្ចឹមសត្វផ្សេងៗក្នុងគោលបំណងដើម្បីទាញយកប្រាក់ចំណូលពីសកម្មភាពទាំងនោះ។ អ្នកភូមិខ្លះមានចិញ្ចឹមគោរហូតដល់ទៅ ២០ក្បាល ហើយអាចរកប្រាក់ចំណូលបាន ១.០០០ដុល្លាសហរដ្ឋអាមេរិចក្នុងមួយឆ្នាំ។ ការសិក្សានេះក៏បានរកឃើញផងដែរថាមានអ្នកភូមិខ្សាច់លាវចំនួន ៣គ្រួសារប៉ុណ្ណោះដែលប្រកបរបរដាំបន្លែក្នុងសួនតាមច្រាំងទន្លេផងដែរ។

ទូកនេសាទត្រីខ្នាតធំជាច្រើនត្រូវបានរាយការណ៍ការអោយដឹងថា បានមកធ្វើសកម្មភាពនេសាទត្រីក្នុងតំបន់ក្បែរភូមិខ្សាច់លាវនេះ ដែលមនុស្សម្នាក្នុងភូមិសង្ស័យថា ក្រុមទាំងនោះកំពុងធ្វើសកម្មភាពនេសាទត្រីខុសច្បាប់។ អ្នកនេសាទត្រីខ្នាតធំទាំងនោះ គឺមិនមែនជាមនុស្សរស់នៅក្នុងភូមិរបស់ពួកគេនោះទេ។ យើងរកឃើញថា មិនមានការរាយការណ៍ណាមួយបានលើកឡើងពីផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជនក្នុងភូមិនោះទេ តែមានការយល់ឃើញមួយលើការនេសាទត្រីខុសច្បាប់ ដែលសកម្មភាពនេះនឹងអាចក្លាយជាផលប៉ះពាល់មួយក្នុងរយៈពេលវែងសំរាប់ពួកគេ។ ភូមិខ្សាច់លាវ ក៏ជាភូមិមួយដែលឋិតក្នុងគំរោងអភិរក្សរបស់មូលនិធិសង្គ្រោះសត្វព្រៃសាកល (WWF) ដែរ ដែលឋិតក្នុងបទដ្ឋានការងារសហការ និងសម្របសម្រួល

ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការងារអភិរក្សក្នុងតំបន់នេះ។ អ្នកភូមិជាច្រើនបានបញ្ជាក់អោយដឹងថា ពួកគេធ្វើការអភិរក្សសត្វផ្សោតដែលរស់នៅជុំវិញបរិវេណភូមិខ្សាច់លាវនេះ។

### ៤.២. ការចិញ្ចឹមជីវិត និងប្រាក់ចំណូល

ការសិក្សាស្រាវជ្រាវនេះបានបញ្ជាក់អោយដឹងថា អ្នកភូមិស្ទើរតែទាំងអស់នៅក្នុងភូមិគោលដៅ បានចាត់ទុកការប្រកបរបរធ្វើស្រែចំការ ការនេសាទត្រី ការងារចិញ្ចឹមសត្វ ការដាំបន្លែក្នុងសួនតាមច្រាំងទន្លេ និងការធ្វើជាកម្មករស៊ីឈ្នួលអោយអ្នកដទៃថាជាសកម្មភាពសំរាប់ការចិញ្ចឹមជីវិត និងជាប្រភពប្រាក់ចំណូលដ៏ចំបងសំរាប់ពួកគេ។ គ្រប់សកម្មភាពដើម្បីចិញ្ចឹមជីវិតរស់នៅរបស់ពួកគេ គឺមានទំនាក់ទំនងយ៉ាងធំធេងទៅនឹងលំហូរទឹកតាមរដូវកាលនៃទន្លេមេគង្គ។

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា មនុស្សក្នុងភូមិគោលដៅទាំងអស់បានកំណត់ច្បាស់លាស់ពីភាពដ៏សំខាន់នូវធនធានសំរាប់ការចិញ្ចឹមជីវិតប្រចាំថ្ងៃផ្អែកលើពេលវេលា ហើយជាញឹកញាប់ឃើញថា ពួកគេបានចំណាយពេលធ្វើសកម្មភាព ហើយពិតជាទទួលបានប្រាក់ចំណូលពីសកម្មភាពនេះ។ ដូច្នេះ ចំពោះសកម្មភាពដទៃទៀតដែលអនុវត្តយូរៗម្តងនោះមិនត្រូវបានរាប់បញ្ចូលជាសកម្មភាពសំរាប់គាំទ្រការចិញ្ចឹមជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេនោះទេ។ ទោះជាយ៉ាងណាក៏ដោយសកម្មភាពទាំងនេះ នឹងក្លាយទៅជាប្រាក់កំរៃដែលមានតម្លៃយ៉ាងសំខាន់ប្រសិនបើយើងគណនាវាធៀបទៅជារូបិយវត្ថុ។

#### ការប្រកបរបរធ្វើស្រែ

កសិករស្ទើរគ្រប់គ្នា គឺមានការពឹងផ្អែកទាំងស្រុងលើលំហូរទឹកតាមរដូវកាលរបស់ទន្លេមេគង្គ ដែលលំហូរ ទឹកតាមរដូវកាលនេះជាគន្លឹះ និងជាជីបចរមួយដ៏មានតម្លៃដើម្បីជួយបញ្ចូលទឹកចូលក្នុងវាលស្រែរបស់ពួកគេ ដើម្បីឱ្យស្ទូងស្រូវបាន។ ជាទូទៅការធ្វើស្រែបានកើតមានឡើងក្នុងរយៈពេលប្រហែលជាប្រាំខែក្នុងមួយឆ្នាំដែលចាប់ផ្តើម នៅរៀងរាល់ដើម ខែឧសភាសំរាប់សកម្មភាពរៀបចំដីស្រែ ហើយបន្តរហូតដល់រដូវប្រមូលផលនៅក្នុងខែតុលា និង ខែវិច្ឆិកា រៀងរាល់ឆ្នាំ។

ការសិក្សានេះក៏បានបង្ហាញដែរថា ប្រជាជនក្នុងភូមិគោលដៅស្ទើរតែទាំងអស់មានដីស្រែជាមធ្យមចាប់ពី ០,៥-១,៥ ហិកតា។ ផលស្រូវជាមធ្យមដែលទទួលបានក្នុងវាលស្រែមួយហិកតាគឺ ១,៥តោន ជាមួយការងារបង្កបង្កើនផលម្តងក្នុងមួយឆ្នាំ។ ប្រជាជនក្នុងភូមិគោលដៅដែលបានចុះសិក្សាស្ទង់មតិទាំងនេះ បានយកផលស្រូវដែលប្រមូលបានប្រើប្រាស់សំរាប់ផ្គត់ផ្គង់ក្នុងគ្រួសាររបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ស្ថិតិចំនួនប្រជាជនក្នុងឆ្នាំ ២០០៩ បានបញ្ជាក់អោយឃើញថា ក្នុងខេត្តក្រចេះតាមធម្មតាក្នុងមួយគ្រួសារមានសមាជិកជាមធ្យមប្រាំនាក់។ ម្យ៉ាងវិញទៀត ផលស្រូវដែលប្រមូលបាននោះត្រូវបានយកទៅលក់ដើម្បីប្តូរយកប្រាក់មកទិញឱសថនៅពេល ដែលសមាជិកគ្រួសារណាម្នាក់មានជំងឺ។ ប៉ុន្តែសំរាប់គ្រួសារតូច និងមានសមាជិកគ្រួសារតិចជាងនេះ ពួកគេអាច លក់ស្រូវដែលប្រមូលនោះប្តូរយកប្រាក់ផ្គត់ផ្គង់ដល់ការចាយវាយ ផ្សេងៗក្នុងគ្រួសាររបស់ពួកគេបាន។

ម្យ៉ាងវិញទៀត មានភូមិចំនួនបី ក្នុងចំណោមភូមិគោលដៅទាំង៦ ដែលបានចុះទៅសិក្សាប្រមូលព័ត៌មាន និងស្ទង់មតិ បានអោយដឹងថាមានប្រជាជនប្រមាណជាពីរ ឬបីគ្រួសារ មានដីស្រែជាកម្មសិទ្ធិ ០,២-០,៣ហិកតា ប៉ុណ្ណោះ។ របាយការណ៍ស្រង់តម្លៃស្រូវនៅទីផ្សារ មានតម្លៃចន្លោះពី ៨០០-១.០០០រៀល ក្នុងមួយគីឡូក្រាម ដែលមានតម្លៃសមមូលទៅនឹង ០,២០-០,២៥ សេនដុល្លាសហរដ្ឋអាមេរិច។ ក៏នៅមានប្រជាជនជាច្រើនគ្រួសារ ក្នុងភូមិខ្សាច់លាវ បានធ្វើចំការលក្ខណៈជាប្រព័ន្ធ ហើយធ្វើការផ្លាស់ប្តូរចំការរបស់ពួកគេរៀងរាល់បីឆ្នាំម្តង។


*រូបភាពទី៥: សកម្មភាពធ្វើស្រែក្នុងភូមិ*

### ការប្រើប្រាស់ស្រូវ/អង្ករក្នុងមួយគ្រួសារ

ក្នុងមួយគ្រួសារប្រើអង្ករអស់ជាមធ្យមបីគីឡូក្រាមក្នុងមួយថ្ងៃ។ ការសិក្សាស្រាវជ្រាវនេះបានបញ្ជាក់ឱ្យដឹងថា ក្នុងរបបអាហារមួយពេលមនុស្សម្នាក់បរិភោគបាយអស់មួយកំប៉ុង (គិតជាអង្ករ ប្រហែលជា ៤កំប៉ុងស្មើនឹង ១ គីឡូក្រាម)។ ប៉ុន្តែសំរាប់គ្រួសារមួយដែលមានសមាជិកប្រាំពីរនាក់ជាមធ្យមចំណាយអង្ករអស់បីកំប៉ុងសំរាប់អាហារពេលព្រឹក ប្រាំកំប៉ុងសំរាប់អាហារថ្ងៃត្រង់ និងប្រាំមួយកំប៉ុងសំរាប់អាហារពេលល្ងាច។ នេះបញ្ជាក់ឱ្យឃើញ ថាក្នុងមួយគ្រួសារត្រូវចំណាយអង្ករអស់ដប់បួនកំប៉ុង ឬស្មើនឹងបីគីឡូក្រាមអង្ករក្នុងមួយថ្ងៃ។

## ៤.២.១. សកម្មភាពនេសាទ

តាមចម្ងាអ្នកភូមិនេសាទត្រីក្នុងទន្លេមេគង្គ តាមដងអូរនៃដៃទន្លេមេគង្គ និងតាមវាលស្រែជាដើម។ ការសិក្សារនេះបានបញ្ជាក់អោយដឹងថា ស្ទើរតែគ្រប់គ្រួសារក្នុងភូមិគោលដៅដែលបានចុះសិក្សា និងសម្ភាសន៍មតិបាននេសាទត្រីតាមដងទន្លេមេគង្គជារៀងរាល់ថ្ងៃ នៅក្នុងរដូវទឹកស្រកប្រហែលជាមានរយៈពេលប្រាំពីរខែក្នុងមួយឆ្នាំ ចាប់ពីខែតុលា ដល់ខែមេសា។ ជាងនេះទៅទៀតអ្នកភូមិជាច្រើនបានរាយការណ៍អោយដឹងផងដែរថា មានតំបន់ដែលអាចនេសាទត្រីបានក្នុងរដូវទឹកស្រក និងរដូវទឹកឡើងធំ (ប្រាំង និងវស្សា) ដែលរាប់បញ្ចូលទាំងដៃទន្លេ និងវាលស្រែ។

### ការនេសាទត្រីតាមដងទន្លេមេគង្គ

រៀងរាល់ថ្ងៃក្នុងរយៈពេលប្រាំពីរខែក្នុងមួយឆ្នាំ អ្នកភូមិបានចំណាយពេលដើម្បីនេសាទត្រីក្នុងដងទន្លេមេគង្គយ៉ាងតិចបំផុត ២-៣ម៉ោង ក្នុងមួយថ្ងៃជាមួយនឹងផលត្រីចាប់បានជាមធ្យមពី ១-២គីឡូក្រាម។ ជាទូទៅ ត្រីដែលពួកគាត់នេសាទបាននោះត្រូវបានយកទៅលក់ខ្លះ និងខ្លះទៀតសំរាប់ហូបក្នុងគ្រួសារ។ ផលត្រីដែលនេសាទបានមានទំហំពីមធ្យមឡើងទៅអាចលក់បានក្នុងតម្លៃពី ៦.០០០-៨.០០០រៀល ក្នុងមួយគីឡូក្រាម សមមូលនឹងប្រាក់ ១,៥០-២ ដុល្លាសហរដ្ឋអាមេរិកអាស្រ័យទៅតាមប្រភេទត្រី។ ក្នុងខណៈពេលនោះដែរ យើងឃើញថាមានប្រជាជន ២-៣ គ្រួសារក្នុងភូមិគោលដៅបាននេសាទត្រីសំរាប់តែផ្គត់ផ្គង់ការហូបចុកក្នុងគ្រួសាររបស់ពួកគេប៉ុណ្ណោះ។ ក្នុងមួយគ្រួសារ ពួកគេបរិភោគត្រីអស់ជាមធ្យមមួយគីឡូក្រាមក្នុងមួយថ្ងៃ ហើយជាងនេះទៀត

យើងឃើញថា ក្នុងមួយគ្រួសារបរិភោគត្រីពីរពេលក្នុងមួយថ្ងៃ គឺសំរាប់អាហារថ្ងៃត្រង់ និងអាហារពេលល្ងាច។ សកម្មភាពនេសាទត្រី ជាទូទៅត្រូវបានអនុវត្តដោយបុរស ប៉ុន្តែជួនកាលក៏មានការចូលរួមជួយពីស្ត្រី និងក្មេងៗផងដែរ។

ក្នុងភូមិគោលដៅចំនួនពីរភូមិ បានរាយការណ៍អោយដឹងថា មានអ្នកភូមិមួយចំនួនបានធ្វើការនេសាទត្រី លក្ខណៈជាក្រុមដែលមានគ្នាបី ទៅបួននាក់ ហើយចេញទៅនេសាទប្រហែលជា ១០គីឡូម៉ែត្រឆ្ងាយពីភូមិរបស់ពួកគេ ហើយស្នាក់នៅទីនោះរហូតដល់ដប់ថ្ងៃទើបត្រលប់មកវិញម្តងជាមួយនឹងផលត្រីពី ៣០-៤០គីឡូក្រាមក្នុងមួយលើកៗ។ អ្នកភូមិបានរាយការណ៍អោយដឹងទៀតថា ប្រភេទឧបករណ៍ដែលពួកគេប្រើក្នុងពេលនេសាទត្រី នោះជាឧបករណ៍បែបទំនើប និងជឿនលឿន ហើយការនេសាទរបស់ពួកគេមានលក្ខណៈជាការធ្វើជំនួញ។ ផលត្រី ដែលពួកគេនេសាទបានមួយភាគធំគឺសំរាប់លក់។

**ការនេសាទត្រីតាមព្រែកជីក/អូរដៃទន្លេ និងវាលស្រែ**

ក្នុងកំឡុងពេលទឹកទន្លេមេគង្គឡើងធំ ទឹកទន្លេបានហូរចាក់ចូលតាមអូរ ព្រែក និងវាលស្រែ។ លំហូរបែបនេះមានរយៈពេលប្រហែលជាបីខែក្នុងមួយឆ្នាំចាប់ពីខែសីហា ដល់ខែតុលា រៀងរាល់ឆ្នាំ ដែលជាទូទៅទឹកឡើងខ្លាំង បំផុតក្នុងខែកញ្ញា ហើយប្រជាជនអាចនេសាទត្រីតាមអូរ និងព្រែកដែលជាដៃទន្លេមេគង្គបានយ៉ាងរីករាយ។ ប្រជាជនក្នុងមួយគ្រួសារអាចនេសាទត្រីបានជាមធ្យមពី ១៥-២០គីឡូក្រាមក្នុងមួយឆ្នាំ ហើយភាគច្រើន គឺសំរាប់ការផ្គត់ផ្គង់ដល់ការបរិភោគក្នុងគ្រួសារ។ ហើយក្នុងរយៈពេល៤៥ថ្ងៃ រៀងរាល់ឆ្នាំឃើញថា អ្នកភូមិអាចនេសាទត្រីតាមវាលស្រែបាន។ ការនេសាទត្រីតាមវាលស្រែនេះ អ្នកភូមិអាចចាប់ត្រីបានជាមធ្យមប្រាំគីឡូក្រាមក្នុងមួយគ្រួសារសំរាប់រយៈពេល៤៥ថ្ងៃនេះ ហើយផលត្រីដែលនេសាទបានគឺសំរាប់បរិភោគក្នុងគ្រួសារប៉ុណ្ណោះ។

### ៤.២.២. ការដាំបន្លែតាមច្រាំងទន្លេ

ប្រភពចំណូលគ្រួសារប្រចាំឆ្នាំរបស់អ្នកភូមិ មួយចំណែកត្រូវបានទាញចេញពីការដាំបន្លែក្នុងសួនតាមច្រាំងទន្លេ ដែលទាញយកប្រាក់ចំណូលប្រមាណជា ៥.០០០ដុល្លាសហរដ្ឋអាមេរិច។

ប្រជាជនក្នុងភូមិអាចប្រកបរបរដាំបន្លែតាមច្រាំងទន្លេបានក្នុងរយៈពេលប្រមាណជាប្រាំពីរខែក្នុង មួយឆ្នាំ ហើយភាគច្រើនពួកគេដាំបន្លែនៅរដូវទឹកស្រក។ ក្នុងមួយគ្រួសារអាចរកប្រាក់ចំណូល បានពីរការលក់បន្លែយ៉ាងតិច ១០០.០០០-២០០.០០០រៀល ក្នុង មួយឆ្នាំ សមមូលនឹង ២៥-៥០ ដុល្លាសហរដ្ឋអាមេរិច ហើយបន្លែសល់ពីការលក់ត្រូវបានប្រើប្រាស់សំរាប់បរិភោគក្នុងគ្រួសារ។ ជាទូទៅបន្លែដែលអ្នកភូមិដាំនោះមានដូចជា ស្ពៃតឿ ថ្នាំជក់ ល្ពៅ អំពៅ ដំឡូងមី ដំឡូងជ្វា ឃ្លោក និងដំណាំក្នុងស្រុក ដូចជាពោត ឪឡឹក ត្រប់ ត្រសក់ ជី និងដំណាំផ្សេងៗទៀតជាច្រើន។ ការដាំ បន្លែតាមច្រាំងទន្លេ ភាគច្រើនត្រូវបានអនុវត្តដោយស្ត្រី និងជួនកាលក៏មានការចូលរួមជួយពីបុរស និងក្មេងៗក្នុងគ្រួសារដែរ។

### ៤.២.៣. ប្រាក់ចំណូលពីការចិញ្ចឹមសត្វ

ការសិក្សាស្រាវជ្រាវនេះបានបញ្ជាក់អោយឃើញថា មានវត្តមានសកម្មភាពចិញ្ចឹមសត្វនៅក្នុង ភូមិគោលដៅ ដែលបានចុះស្ទង់មតិ។ សត្វដែលអ្នកភូមិចិញ្ចឹមមានដូចជាសត្វគោ ក្របី មាន់ និង ជ្រូកជាដើម។ ប្រាក់ចំណូលដែលរកបានពីការលក់សត្វចិញ្ចឹម ពិសេសសត្វគោ គឺសំរាប់ការចំណាយ ធំៗ ដូចជាការសង់ផ្ទះ ទិញម៉ូតូ ក៏ដូចជាការចំណាយសំរាប់តំរូវការបន្ទាន់ពិសេសទៅលើការទិញ ថ្នាំពេទ្យដើម្បីព្យាបាលជំងឺ។ ចំណូលដែលបានពីការលក់សត្វ ចិញ្ចឹមផ្សេងទៀតត្រូវបានចំណាយ លើការទិញសំលៀកបំពាក់ ការអប់រំ និងតំរូវការផ្សេងៗនៅក្នុងគ្រួសារ។

អ្នកភូមិភាគច្រើនបានបញ្ជាក់ថា សត្វចិញ្ចឹមមិនបានពឹងផ្អែកលើទន្លេមេគង្គទេ ប៉ុន្តែតាម ការអង្កេតក្នុងភូមិ ឃើញថា សត្វទាំងនោះបានងូត និងផឹកទឹក ព្រមទាំងស៊ីស្មៅដែលដុះតាមច្រាំង ទន្លេនៅរដូវទឹកស្រក។

#### ការចិញ្ចឹមក្របី

ប្រជាជនភាគច្រើនបានចិញ្ចឹមសត្វក្របីដើម្បីធ្វើជាកំលាំងអូសទាញ ដើម្បីជួយសំរួលដល់ ការងារធ្វើស្រែ និង ដឹកជញ្ជូនដោយប្រើរទេះសំរាប់ដឹកកសិផលជាដើម។ ជាឧទាហរណ៍ជាក់ស្តែង ប្រជាជន៨០%ក្នុងចំណោមប្រជាជន សរុបក្នុងភូមិដីរបានចិញ្ចឹមក្របីជាកំលាំងអូសទាញ ដើម្បីជួយ

សំរួលដល់ការងារកសិកម្ម។ សត្វក្របីត្រូវបានអ្នកភូមិ ចាត់ទុកថា ជាសត្វមានសារៈសំខាន់សំរាប់ពួកគេ។



*រូបភាពទី៦: ស្ត្រីជាមួយនឹងក្របីរបស់គាត់នៅវាលស្រែ*

## ការចិញ្ចឹមគោ

សត្វគោត្រូវបានចិញ្ចឹមសំរាប់គោលបំណងទាញយកប្រាក់ចំណូល និងជាទីពេញនិយមសំរាប់ប្រជាជនគ្រប់ក្រុមគ្រួសារក្នុងភូមិគោលដៅ។ សត្វគោត្រូវបានលក់ប្តូរយកប្រាក់សំរាប់គាំទ្រដល់ការចំណាយធំៗ ដូចជាការសង់ផ្ទះថ្មី ទិញម៉ូតូថ្មី សំរាប់តំរូវការបន្ទាន់ និងសំរាប់ការសំរាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យជាដើម។ គ្រួសារភាគច្រើន បានលក់សត្វគោដើម្បីទាញយកប្រាក់ចំណូលគ្រួសារ ប៉ុន្តែក៏មានគ្រួសារផ្សេងទៀតដែលលក់សត្វគោសំរាប់តែនៅពេលណាដែលពួកគេមានតំរូវការប្រាក់កាក់ប៉ុណ្ណោះ។ មានប្រជាជនប្រមាណជាពីរ ឬបីគ្រួសារក្នុងភូមិសំភិន ភូមិកោះសម និងភូមិខ្សាច់លាវចិញ្ចឹមសត្វគោ យ៉ាងតិចបំផុត២០ក្បាលក្នុងមួយគ្រួសារ និងអាចរកប្រាក់ចំណូល បានពីការលក់សត្វ ទាំងនេះ១.០០០ដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំ។

## ការចិញ្ចឹមមាន់

សត្វមាន់ ត្រូវបានចិញ្ចឹមស្ទើរគ្រប់គ្រួសារក្នុងភូមិគោលដៅដែលបានចុះស្ទង់មតិ។ ប្រាក់ចំណូលដែលទាញបានពីការចិញ្ចឹមសត្វមាន់ត្រូវបានអ្នកភូមិរាយការណ៍អោយដឹងថា ទទួលបាន

ច្រើនជាងការចិញ្ចឹមសត្វជ្រូក។ សំរាប់ប្រជាជនក្នុងភូមិភាគច្រើនអាចលក់មាន់បានពីរទៅបីដង ក្នុងមួយឆ្នាំ ហើយក្នុងមួយគ្រួសាររកប្រាក់ចំណូលបានពី ១០០.០០០-៤០០.០០០ រៀលក្នុង មួយឆ្នាំ ដែលស្មើនឹង ២៥ដុល្លា ទៅ ១០០ដុល្លា។ មានគ្រួសារខ្លះ ក្នុងមួយឆ្នាំៗ អាចលក់មាន់បាន ៥០ក្បាលក្នុងតំលៃ១២.០០០រៀលក្នុងមួយគីឡូក្រាម ដែលស្មើនឹងបីដុល្លា។ ជាទូទៅ ប្រាក់ចំណូល ដែលទាញបានពីការលក់មាន់ចិញ្ចឹម ត្រូវបានចំណាយលើការទិញសំលៀកបំពាក់ ការសិក្សា និង ទិញម្ហូបអាហារ។ ម្យ៉ាងទៀត សត្វមាន់ក៏ត្រូវបានចិញ្ចឹមសំរាប់តំរូវការកម្មវិធីពិសេសមួយចំនួនដែរ ដូចជាការរៀបការ និងពិធីបុណ្យប្រពៃណីផ្សេងៗ។



*រូបភាពទី៧: ស្ត្រីឱ្យចំណីទៅមាន់របស់គាត់*

### ការចិញ្ចឹមជ្រូក

សត្វជ្រូកត្រូវបានចិញ្ចឹមនៅគ្រប់ភូមិគោលដៅដែលបានចុះសិក្សា ប៉ុន្តែក្នុងភូមិនីមួយៗ មាន ប្រជាជនមិនច្រើនគ្រួសារទេដែលចិញ្ចឹមជ្រូកនោះ។ ការចិញ្ចឹមជ្រូកអាចរកប្រាក់ចំណូលបានពី ១៥០.០០០-៥០០.០០០រៀលក្នុងមួយឆ្នាំ ដែលមានតម្លៃស្មើនឹង ៣៧-១២៥ដុល្លាសហរដ្ឋ អាមេរិក។ សត្វជ្រូកដែលចិញ្ចឹមធំត្រូវបានលក់ជូនឈ្មួញដែលចូលមកទិញក្នុងភូមិ។ សត្វជ្រូក តូចអាចលក់បាន ១៥០.០០០-២០០.០០០រៀល ស្មើនឹង ៣៧-៥០ ដុល្លាសហរដ្ឋអាមេរិច រីឯសត្វ ជ្រូកធំវិញអាចលក់បានពី ៣០០.០០០-៥០០.០០០រៀល ដែលស្មើនឹង៧៥-១២៥ដុល្លាសហរដ្ឋ អាមេរិច។ តម្លៃជ្រូកមួយក្បាលត្រូវបានកំណត់ជាតម្លៃប៉ាន់ស្មានដោយឈ្មួញជាអ្នកទិញ។ ប្រាក់

ចំណូល ដែលទាញបានពីការចិញ្ចឹមជ្រូកត្រូវបានយកមកប្រើប្រាស់សំរាប់ផ្គត់ផ្គង់ការចាយវាយក្នុងគ្រួសារ។



*រូបភាពទី៨: ស្ត្រីឱ្យចំណីទៅជ្រូករបស់គាត់*

### ៤.២.៤.ប្រាក់ចំណូលពីការងារជាកម្មករស៊ីឈ្នួលតាមរដូវកាល និងប្រាក់ចំណូលពីប្រភពផ្សេងៗ

មានភូមិចំនួនប្រាំ ក្នុងចំណោមភូមិគោលដៅទាំងប្រាំមួយបានបង្ហាញអោយដឹងថា មានអ្នកភូមិមួយចំនួន ធ្វើការជាកម្មករស៊ីឈ្នួលធ្វើការអោយគេនៅក្នុងព្រៃ ដែលភាគច្រើនទៅធ្វើការនៅក្នុងតំបន់ដីសម្បទានរបស់ ក្រុមហ៊ុនភាពភីមិច (Pheapimex) ដែលជាក្រុមហ៊ុនផលិតក្រដាស ដាំដើមម៉ៃសាក់ កៅស៊ូ និងដំឡូងមី ហើយអ្នកភូមិមួយចំនួនទៀត បានធ្វើការអោយក្រុមហ៊ុនរុករករ៉ែមាស។ មានអ្នកភូមិមួយចំនួនធ្វើជាកម្មករស៊ីឈ្នួលនៅក្នុងផ្សារ និងកំពង់ផែជាពិសេសក្នុងស្រុកសំបូរ និងក្រុងក្រចេះ។ ម្យ៉ាងទៀត ក៏មានអ្នកភូមិមួយចំនួនតូចបានធ្វើដំណើរផ្សងព្រេងទៅធ្វើជាកម្មករស៊ីឈ្នួលនៅក្រៅប្រទេសផងដែរ ហើយការងារទាំងនោះមានដូចជាអ្នកថែទាំ និងបោសសំអាតផ្ទះនៅប្រទេសម៉ាឡេស៊ី និងកូរ៉េខាងត្បូងជាដើម។

ប្រភពរកប្រាក់ចំណូលផ្សេងទៀត ត្រូវបានរួមបញ្ចូលទាំងការរកប្រាក់ចំណូលពីការលក់ផ្លែឈើ ដូចជាផ្លែស្វាយ អម្ពិល ដែលប្រើសំរាប់ដាំស្ល ផ្លែឪឡឹក (ឪឡឹកមួយផ្លែអាចលក់បានតម្លៃ១ដុល្លាសហរដ្ឋអាមេរិច) ផ្លែខ្នុរ ម្នាស់ និងក្រូច ពោធិសាត់ជាដើម។ ប្រភពប្រាក់ចំណូលមួយ

ទៀតនោះ គឺការកាប់ឈើ និងបរបាញ់សត្វព្រៃដើម្បីលក់ប្តូរយកប្រាក់។ ជាទូទៅ សត្វព្រៃដែលអ្នកភូមិបរបាញ់មានដូចជា សត្វជ្រូកព្រៃ ទន្សាយ ពស់ ស្វា អណ្តើក ឈ្លូស និងត្រកួតជាដើម ហើយសត្វដែលពួកគេបរបាញ់បាននោះត្រូវបានយកមកធ្វើជាអាហារសំរាប់ហូបផង និងលក់ប្តូរយកប្រាក់ផង។

មានប្រជាជនពីរ ឬបីគ្រួសារបានរកប្រាក់ចំណូលសំរាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃពីការបើកតូបលក់ដូរ គ្រឿងទេសខ្នាតតូច ហើយអ្នកភូមិដែលមានតូបលក់គ្រឿងទេសនោះ គឺជាគ្រូបង្រៀន មន្ត្រីរាជការ ដូចជាក្រុមប្រឹក្សាឃុំ មេភូមិ គ្រូពេទ្យ គិលានុបដ្ឋាយិកាភូមិ និងទាហានជាដើម។ ប៉ុន្តែក៏មានប្រជាជនពីរ ឬបីគ្រួសារដែល ទទួលបានការផ្គត់ផ្គង់ជាប្រាក់ឧបត្ថម្ភពីកូន១របស់ពួកគេដែលធ្វើការនៅក្រៅភូមិផ្ញើមកឱ្យផងដែរ។

## ៤.៣. ការផ្តល់សេវាកម្មសង្គមមូលដ្ឋាន

ការសិក្សាបានរកឃើញថា មានសាលារៀនកំរិតបឋមសិក្សានៅភូមិគោលដៅទាំងប្រាំមួយ ប៉ុន្តែសាលារៀន ទាំងនេះភាគច្រើនមិនមានថ្នាក់គ្រប់កំរិតទេ ដែលកំរិតខ្ពស់បំផុតមានត្រឹមតែថ្នាក់ទីប្រាំប៉ុណ្ណោះ។ យើងឃើញមាន សាលាអនុវិទ្យាល័យមួយដែលមិនទាន់សាងសង់រួចរាល់នៅឡើយនោះ នៅក្នុងភូមិមួយក្នុងចំណោមភូមិគោលដៅទាំងអស់។ អ្នកភូមិបានរាយការណ៍អោយបានដឹងថា នៅក្នុងភូមិរបស់ពួកគេមានកង្វះខាតបន្ទប់រៀន និងគ្រូបង្រៀន ក្នុងសាលារៀនជាឧទាហរណ៍ជាក់ស្តែង គ្រូបង្រៀនម្នាក់ទទួលបន្ទុកបង្រៀនពី ២-៣ ថ្នាក់ក្នុងមួយថ្ងៃ ឬក្នុងពេលតែមួយ។

មានកុមារគ្រប់អាយុចូលរៀនជាច្រើនក្នុងភូមិ ប៉ុន្តែពួកគេបោះបង់ការរៀនសូត្រ ដើម្បីជួយការងារឪពុក ម្តាយរបស់ពួកគេ*(មិនមានទិន្នន័យបញ្ជាក់ទេ)*។ កង្វះខាតសាលាថ្នាក់អនុវិទ្យាល័យនៅក្បែរភូមិ គឺជាកត្តារារាំងដ៏ធំមួយដល់សិស្សដែលរៀនចប់ថ្នាក់បឋមសិក្សាធ្វើអោយពួកគេមិនអាចបន្តទៅរៀននៅថ្នាក់ខ្ពស់បាន។ ឧទាហរណ៍ ជាក់ស្តែងមួយបានបង្ហាញអោយឃើញថា មានសិស្សសាលាដែលរៀនចប់ថ្នាក់បឋមសិក្សានៅភូមិខ្សាច់លាវ ដែលពួកគេមានបំណងរៀនបន្តទៅថ្នាក់អនុវិទ្យាល័យ ពួកគេត្រូវតែធ្វើដំណើរទៅរៀននៅសាលាក្នុងឃុំអូរគ្រៀងដែលជាសាលាថ្នាក់អនុវិទ្យាល័យជិតជាងគេបំផុតជាមួយនឹងចំងាយផ្លូវ ២៨គីឡូម៉ែត្រ ឆ្ងាយពីភូមិរបស់ពួកគេ។

ក្រៅពីនេះ ពួកគេក៏អាចធ្វើដំណើរទៅរៀននៅសាលាអនុវិទ្យាល័យក្នុងស្រុកសំបូរផ្ទាល់ក៏បាន ជាមួយនឹងចំងាយ ផ្លូវ ១១៤ គីឡូម៉ែត្រ ឆ្ងាយពីភូមិខ្សាច់លាវ ។

ការសិក្សានេះមិនបានរកឃើញមណ្ឌលសុខភាពនៅក្នុងភូមិគោលដៅទាំងប្រាំមួយដែលបានចុះសិក្សានោះទេ តែទោះជាយ៉ាងណាក៏ដោយយ៉ាងហោចណាស់មានបុគ្គលិកពេទ្យ និងពេទ្យបុរាណម្នាក់ដែរ "គិលានុបដ្ឋាយិការ( *មិនបានឆ្លងកាត់វគ្គបណ្តុះបណ្តាលច្បាស់លាស់*) "ដែលគ្រូពេទ្យទាំងនេះ អាចចូលរួមក្នុងការជួយសង្គ្រោះបឋម និងសម្រាលកូនបាន។ ការសិក្សានេះ មិនបានរកឃើញទិន្នន័យណាមួយបញ្ជាក់ច្បាស់ពីអត្រាមរណៈភាពរបស់ទារកក្នុងភូមិនីមួយនោះទេ តែទោះជាយ៉ាងណាក៏ដោយ ទិន្នន័យស្ថិតិប្រជាជនឆ្នាំ២០០៩ បានបញ្ជាក់ពីអត្រាមរណៈភាពរបស់ទារកក្នុងខេត្តក្រចេះទាំងមូលដែរ។ ជាងនេះទៀត នៅក្នុងភូមិពីរ ដូចជាភូមិភូមិខ្សាច់លាវ និងភូមិកោះផ្ដៅ ឃើញមានវត្តមានមន្ត្រីពេទ្យជំនាញជំងឺគ្រុនចាញ់ប្រចាំការក្នុងភូមិ និងឱសថសំរាប់ផ្គត់ផ្គង់ដល់អ្នកភូមិ។ សំរាប់ប្រជាជនដែលមានជំងឺធ្ងន់ធ្ងរក្នុងភូមិភាគច្រើន ពួកគេបានស្វែងរកការព្យាបាលនៅស្រុកសំបូរ។

ជំងឺគ្រុនចាញ់ គ្រុនឈាម ផ្តាសាយ រាគ និងសត្វល្អិតក្នុងថ្លើមច្រើនកើតមានចំពោះក្មេងៗ និងជាប្រភេទជំងឺធម្មតាតែងតែកើតមាន និងត្រូវបានអ្នកភូមិរាយការណ៍ជូនក្រុមសិក្សាអោយបានដឹង ប៉ុន្តែក៏អាចនៅមានជំងឺមួយចំនួនទៀតដែលមិនរាយការណ៍អោយដឹង។ ជាក់ស្តែងនៅក្នុងឯកសារវាយតម្លៃដោយមានការចូលរួមរបស់ អុកស្វាមអូស្ត្រាលី ឆ្នាំ២០០៧ បានបញ្ជាក់ថាមានវត្តមានជំងឺក្រពះ និង ពោះវៀន។ ជាងនេះទៀត អ្នកភូមិ ជាច្រើនបានរាយការណ៍ថាប្រហែលជាបីទៅប្រាំឆ្នាំមុន មានមនុស្សក្នុងភូមិយ៉ាងហោចណាស់ក៏២-៣នាក់ដែរ ដែលស្លាប់ដោយសារកើតជំងឺស៊ីស្តូ (Schistosoma)។ មានអ្នកភូមិម្នាក់បានស្លាប់ដោយសារតែជំងឺប្រភេទនេះ ក្នុងកំឡុងពេលក្រុមសិក្សាយើងចុះទៅដល់ភូមិកោះផ្ដៅ ហើយមានមនុស្សម្នាក់ទៀតស្លាប់ដោយសារជំងឺនេះនៅ ៣ថ្ងៃ មុខពេលដែលក្រុមសិក្សាបានមកដល់ ហើយករណីនេះ គឺកើតឡើងនៅក្នុងភូមិដដែលនេះដែរ។

ការសិក្សានេះបានរកឃើញថា មានតែនៅថ្នាក់ឃុំប៉ុណ្ណោះដែលមានមណ្ឌលសុខភាព។ ស្រុកសំបូរមានឃុំចំនួន១០ ដែលគួរតែមានមណ្ឌលសុខភាពចំនួន១០ដែរ ដើម្បីសំរួលដល់ការព្យាបាលជំងឺប្រជាជន តែជាក់ស្តែងយើងឃើញមានមណ្ឌលសុខភាពចំនួនបី និងប៉ុស្តិ៍សុខភាពតែបួន

ប៉ុណ្ណោះនៅក្នុងស្រុកសំបូរនេះ (*Oxfam Australia* ២០០៧)។ មណ្ឌលសុខភាពទាំងនេះបានជួយសំរួលដល់ការផ្ដល់សេវាកម្មទៅដល់ភូមិចំនួន៥២ក្នុងស្រុកសំបូរទាំងមូល ឬបម្រើសេវាព្យាបាលជំងឺទៅដល់អ្នកភូមិចំនួន ៥៥.៧០២នាក់។ គ្រប់មណ្ឌលសុខភាពទាំងអស់មានកង្វះខាតបុគ្គលិកទទួលបន្ទុកខាងចុះឈ្មោះអ្នកជំងឺ និងគ្រូពេទ្យជំនាញ ហើយតាមធម្មតាបំរើការងារដោយមន្ត្រីពេទ្យរបស់រដ្ឋ។ គ្រប់អ្នកជំងឺ ដែលមានអាការៈធ្ងន់ធ្ងរក្នុងភូមិត្រូវស្វែងរកសេវាព្យាបាលជំងឺនៅទីរួមស្រុកសំបូរ ឬមកព្យាបាលនៅក្រុងក្រចេះតែម្ដង។ ក្រៅពីនេះ សំរាប់អ្នកជំងឺស្រាលៗត្រូវបានព្យាបាលដោយពេទ្យក្នុងភូមិ។

### ៤.៤. សកម្មភាពរបស់ស្ត្រី

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា ប្រជាជនដែលជាស្ត្រីមានចំនួនច្រើនជាងបុរសនៅក្នុងភូមិគោលដៅចំនួនប្រាំ ក្នុងចំណោមភូមិគោលដៅទាំងអស់។ តាមធម្មតា ស្ត្រីត្រូវរ៉ាប់រងការងារក្នុងផ្ទះទាំងអស់ ដូចជាចំអិនអាហារ បោសសំអាតផ្ទះ បោកគក់ រែកទឹកពីទន្លេ មើលថែកូន និងអោយចំណីសត្វជាដើម។ ស្ត្រីក៏បានចូលរួម ធ្វើការងារក្នុងវាលស្រែផងដែរ ពិសេសក្នុងរដូវដាំដុះ និងច្រូតកាត់។ មានស្ត្រីមួយចំនួនបានជួយប្ដីរបស់ពួកគេក្នុងការនេសាទត្រី ឬជួនកាលមានស្ត្រីខ្លះនេសាទត្រីជាមួយកូនៗរបស់ពួកគេ នេះក៏ដូចគ្នាទៅនឹងការចូលរួមជួយក្នុងការដាំបន្លែក្នុងសួនតាមច្រាំងទន្លេផងដែរ។

មានស្ត្រីមួយចំនួន បានចូលរួមក្នុងសកម្មភាពប្រជុំនានាក្នុងសហគមន៍ហើយពួកគេជាសមាជិកគណៈកម្មការសហគមន៍ និងក្រុមការងារគំរោងដែលស្ត្រីខ្លះបានដើរតួនាទីជាអ្នកដឹកនាំទៀតផង។ យើងរកឃើញថា នៅក្នុងភូមិគោលដៅដែលបានចុះសិក្សាទាំងអស់មានស្ត្រីមួយរូបមានតួនាទីជាអ្នកដឹកនាំគំរោងមួយដែលគាំទ្រដោយអុកស្វាមអូស្ត្រាលី។ ក៏នៅមានស្ត្រីជាច្រើនបានចូលរួមជាសមាជិកក្រុមប្រឹក្សាឃុំ និងជាគណៈកម្មការអភិវឌ្ឍន៍ភូមិផងដែរ។ ជាទូទៅស្ត្រីទាំងនោះបានទទួលបន្ទុកការងាររដ្ឋបាលរៀបចំសកម្មភាពសហគមន៍ និងរៀបចំរបាយការណ៍ទាំងសកម្មភាព និងថវិកា។

ជាទូទៅស្ត្រីត្រូវទទួលបានការជឿទុកចិត្តតិចជាងបុរស ហើយនៅក្នុងសង្គមវិញស្ត្រីមិនត្រូវបានជំរុញ និងបង្កអោយមានភាពងាយស្រួលដល់ពួកគេក្នុងការចូលរួមសកម្មភាពនៅក្រៅផ្ទះ

នោះទេ។ ស្ត្រីភាគច្រើនត្រូវបានកំណត់អោយធ្វើការងារប្រចាំថ្ងៃក្នុងផ្ទះ និងជួយទំនុកបំរុងដល់ស្វាមី ឬឪពុកម្តាយរបស់ពួកគេ។

### ៤.៥. ធនធានព្រៃឈើ

ការសិក្សាស្រាវជ្រាវនេះបានបញ្ជាក់អោយដឹងថា ធនធានព្រៃឈើ ដូចជាដើមឈើ សត្វព្រៃ និងអនុផលព្រៃឈើនានា បានជួយគាំទ្រ និងផ្គត់ផ្គង់ដល់ជីវភាពរស់នៅយ៉ាងច្រើនលើសលប់ និងមានសារៈសំខាន់យ៉ាងខ្លាំង សំរាប់អ្នកភូមិ។ អ្នកភូមិភាគច្រើនដែលត្រូវបានសួរយោបល់មតិបានបញ្ជាក់ថា ព្រៃឈើ គឺជាផ្នែកមួយនៃជីវិតរបស់ពួកគេ ហើយបានក្លាយប្រភពរកប្រាក់ចំណូលដ៏សំខាន់។ អ្នកភូមិជាច្រើនបានបញ្ជាក់ទៀតថា សត្វព្រៃ ដូចជាជ្រូកព្រៃ ឈ្លូស ត្រកួត ពស់ទន្សាយ និងសត្វស្លាជាដើមនោះត្រូវបានរកឃើញនៅក្នុងព្រៃក្នុងភូមិ។ ជាទូទៅអ្នកភូមិបានបរបាញ់សត្វព្រៃដើម្បីធ្វើជាម្ហូបបរិភោគក្នុងគ្រួសារ ហើយមានម្តងម្កាលអ្នកភូមិ ក៏បានយកសត្វដែលពួកគេបរបាញ់ បាននោះទៅលក់ដើម្បីប្តូរយកប្រាក់ជាចំណូលគ្រួសារផងដែរ។

តាមសំដីអ្នកភូមិបានអោយដឹងថា មានសកម្មភាពប្រមូលជ័រទឹកនៅក្នុងព្រៃ ប៉ុន្តែការប្រមូលជ័រទឹកនេះ គឺសំរាប់តែការប្រើប្រាស់ក្នុងគ្រួសារប៉ុណ្ណោះ។ ការប្រមូលធនធានផ្សេងទៀតនៃអនុផលព្រៃឈើមិនត្រូវបានបញ្ជាក់ នៅក្នុងចំលើយនៃការសំភាសន៍នោះទេ។ ជាមួយគ្នានេះការកើនឡើងនូវដីសម្បទានសំរាប់ដាំដំណាំកសិកម្មក្នុងស្រុកសំបូរ បានជំរុញអោយអ្នកភូមិមួយចំនួនចូលខ្លួនស្វែងរកការងារជាកម្មករស៊ីឈ្នួលធ្វើការអោយគេក្នុងតំបន់សម្បទាននោះ។

មានការរាយការណ៍មួយពីសកម្មភាពសម្បទានដី បានកើតឡើងក្នុងផ្នែកមួយនៃព្រៃឈើដែលបានកាប់រំលំដើមឈើរានយកដីដើម្បីធ្វើការដាំដំណាំកៅស៊ូ ដើមម៉ៃសាក់ និងដំឡូងមីជាដើមហើយក៏មានសកម្មភាពរុករករ៉ែមាសពីក្រុមហ៊ុនស៊ីអាយអឹមជី (CIMG) ប៉ុន្តែអ្នកភូមិជាច្រើនមានការស្ទាក់ស្ទើរក្នុងចិត្តក្នុងការផ្តល់ព័ត៌មានលំអិតអំពីសកម្មភាពទាំងនេះ។ ក្នុងឆ្នាំ២០០៦ មានផ្ទៃដីសម្បទានចំនួន ៧៧.៤៦៤ហិកតា ត្រូវបានអនុញ្ញាតអោយដំណើរការក្នុងស្រុកសំបូរ (http://www.elc.maff.gov.kh/overview.html)។ ទោះជាយ៉ាងណាក៏ដោយរបាយការណ៍ថ្មីមួយ (www.sithi.org) បានបញ្ជាក់អោយដឹងថា មានតំបន់ដីសម្បទានថ្មីៗជាច្រើនក្នុងស្រុកសំបូរ ត្រូវបានសំរេចផ្តល់អោយទៅក្រុមហ៊ុនវៀតណាម ក្រុមហ៊ុនចិន និងក្រុមហ៊ុនកូរ៉េ។

## ៤.៦. ការប្រើប្រាស់ទន្លេមេគង្គ

រាល់ថ្ងៃទឹកទន្លេមេគង្គត្រូវបានប្រើប្រាស់ដោយអ្នកភូមិដើម្បីយកទឹកចំអិនអាហារ បោកគក់សំលៀកបំពាក់ លាងចាន ស្រោចដំណាំ និងនាវាចរណ៍ ក៏ដូចជាជាប្រភពទឹកសំរាប់ផឹកដល់មនុស្ស និងសត្វ។ អ្នកភូមិជាច្រើនបានរាយការណ៍ថា រាល់ថ្ងៃពួកគេបានប្រើប្រាស់ទឹកទន្លេមេគង្គសំរាប់ផឹកដោយគ្រាន់តែយកទឹកនោះមកដាំអោយពុះ ឬប្រើធុងចំរោះសំរាប់ច្រោះរំងាប់មេរោគសិនមុនពេលផឹក។ ការប្រើប្រាស់ទឹកអណ្តូង មិនត្រូវបានរកឃើញនៅក្នុងភូមិគោលដៅដែលបានចុះសិក្សានោះទេ តែទោះជាយ៉ាងណាក៏ដោយការអង្កេត និងស្វែងរកពីការប្រើប្រាស់ទឹកអណ្តូងនេះ ក៏មិនប្រាកដប្រជាដែរ។ យោងតាមទិន្នន័យស្ថិតិឆ្នាំ២០០៩ ឃើញថា ប្រជាជន ២៣,០៨%នៃប្រជាជនសរុបខេត្តក្រចេះបានប្រើប្រាស់ទឹកទន្លេសំរាប់ជាប្រភពទឹកដើម្បីផឹកដ៏សំខាន់របស់ពួកគេ។

ទន្លេមេគង្គ គឺជាផ្នែកមួយសំខាន់ដល់ការប្រតិបត្តិខាងជំនឿលើការសែនព្រេនអារក្សរបស់អ្នកភូមិ។ ជាក់ស្តែងអារក្សទឹក គឺជាអារក្សមួយក្នុងចំណោមអារក្សសំខាន់ៗផ្សេងទៀត ដែលត្រូវបានជឿ និងមានជំនឿថា អារក្សទឹកនេះបានផ្តល់ភាពសុខសាន្ត និងសុខភាពល្អដល់អ្នកភូមិព្រមទាំងមានការប្រារព្ធពិធីសែនអារក្សជារៀងរាល់ឆ្នាំទៀតផង។ ក៏មានធនធានដទៃទៀតក្នុងទន្លេមេគង្គ ដែលអ្នកភូមិប្រមូលបានយកមកប្រើប្រាស់បាន ដូចជាខ្សាច់ និងថ្ម (គ្រួស) ដើម្បីសង់ផ្ទះ សាងសង់សាលារៀន និងសាងសង់ជាទីលានដែលអាចប្រើប្រាស់បានច្រើនយ៉ាងអាចជាទីលានលេងបាល់ទាត់ ទីលានសំរាប់ប្រជុំភូមិ និងអាចប្រើប្រាស់បានច្រើនជាងនេះទៀត។ ស្ត្រី និងក្មេងៗក្នុងភូមិ ក៏អាចប្រមូលខ្យងខ្ចៅ ដែលមានតាមដងទន្លេដើម្បីធ្វើជាម្ហូបអាហារក្នុងគ្រួសារបានដែរ។

### ៤.៦.១. លំហូរទឹកតាមរដូវកាល

រដូវទឹកដែលទន្លេឡើងធំក្នុងមួយឆ្នាំមានរយៈពេលប្រមាណជាប្រាំខែ ចាប់ផ្តើមពីចុងខែឧសភា ឬដើមខែមិថុនា និងបន្តឡើងរហូតដល់ខែតុលាដែលកំរិតទឹកឡើងខ្ពស់បំផុតនោះ គឺនៅក្នុងខែសីហា និងខែកញ្ញា។ ក្នុងកំឡុងពេលរដូវទឹកឡើងខ្ពស់នេះ ទឹកទន្លេបានឡើងហៀរទន្លេ ហើយហូរចាក់ចូលក្នុងវាលស្រែ និងបានបន្សល់ទុកទឹកក្នុង អូរ ព្រែក ឬប្រឡាយដែរ។ រដូវទឹកឡើងធំនេះក៏ជារដូវបង្កបង្កើនផលដែរ។

រដូវទឹកសម្រកមានរយៈពេលប្រមាណជាប្រាំពីរខែក្នុងមួយឆ្នាំ ចាប់ផ្តើមពីចុងខែកញ្ញា ឬដើមខែតុលា ហើយបន្តស្រកចុះរហូតដល់ខែមីនា និងខែមេសា ដែលខែមេសានេះ ក៏ជាខែដែលករិតទឹកទន្លេស្រក និងរាក់បំផុតដែរ ។ ក្នុងកំឡុងពេលរដូវទឹកស្រកនេះ ប្រជាជនគ្រប់ក្រុមគ្រួសារក្នុងភូមិបានចេញទៅនេសាទត្រីជារៀងរាល់ថ្ងៃ ហើយវាក៏ជារដូវដែលមានអំណោយផលដល់ការដាំបន្លែក្នុងសួនតាមច្រាំងទន្លេ គួបផ្សំនឹងការស្វែងរកការងារធ្វើជាកម្មករស៊ីឈ្នួលដាំដំណាំអោយគេដែរ ។

### ៤.៦.២. ជួរទឹក និងអន្លង់ជ្រៅៗ

ការសិក្សាស្រាវជ្រាវនេះបានរកឃើញថា មានជួរទឹក និងអន្លង់ជ្រៅៗជាច្រើននៅក្នុងបរិវេណភូមិគោលដៅ ដែលជាទីជម្រកដ៏សំខាន់សំរាប់ត្រីជ្រក និងពងកូន (*MRC*,២០០២) ។ អ្នកភូមិបានបញ្ជាក់អោយដឹងផងដែរថា អន្លង់ជ្រៅៗទាំងនេះមានជម្រៅយ៉ាងហោចណាស់១០រហូតដល់៨០ម៉ែត្រ និងមានប្រវែងយ៉ាងហោចណាស់ ពី២៥-២០០ម៉ែត្រ ។ ករណីសិក្សារបស់ខ័ណ្ឌជលផលខេត្តក្រចេះក្រោមប្រធានបទមួយស្តីពី ***"ប្រើប្រាស់ភាសាជនជាតិដើមភាគតិច ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌអន្លង់ជ្រៅៗ"*** (*គ្មានចុះកាលបរិច្ឆេទ*) បានរកឃើញមានអន្លង់ជ្រៅៗចំនួន៣៧កន្លែងក្នុងស្រុកសំបូរ ។ តាមការវាស់វែងអន្លង់ជ្រៅៗទាំងនោះមានប្រវែងអតិបរិមាណ ២.០០០ ម៉ែត្រ និងទទឹងអតិបរិមាណ ៥០០ម៉ែត្រ ហើយជម្រៅអតិបរិមាណ ២០០ម៉ែត្រ (សូមមើលក្នុង តារាងទី៤ ខាងក្រោម) ។

**តារាងទី៥: អន្លង់ជ្រៅក្នុងតំបន់ស្រុកសំបូរ**

| ឈ្មោះអន្លង់ | ប្រវែង (ម៉ែត្រ) | ទទឹង(ម៉ែត្រ) | ជម្រៅ(ម៉ែត្រ) |
|---|---|---|---|
| ប៉ាក់ វិក | ១.០០០ | ៤០ | ១៥ |
| បារាំងគរ | ៨០០ | ៤០ | ១០-១២ |
| យ៉ាវ | ៦០០ | ៤០ | ១៥ |
| អន្ទ្យាងធ្លាក់ | ២.០០០ | ៤០ | ១៥-៤០ |
| អាចេន | ៣០០ | ៤០ | ១៥ |

| | | | |
|---|---|---|---|
| ព្រះថ្ងវាលាក់ | ២០០ | ៤០ | ១៥ |
| ព្រះថ្ងវាធំ | ៨០០ | ៥០ | ១០ |
| កោះត្បាល់ | ៨០ | ៥០ | ១០ |
| ចាបឆ្នូត | ៨០០ | ៥០ | ១៥ |
| ប្រចៀវ | ៥០០ | ៥០ | ១៥ |
| ជ្រោយសំយ៉ុង | ៤០០ | ៤០ | ១៥ |
| ប្រ៉ា | ១.០០០ | ៣៥ | ២៥ |
| គល់ប្រាំបីជ្រុង | ១.៥០០ | ៣៥ | ១៥ |
| កោះដំបង | ៨០០ | ៣៥ | ២០ |
| កណ្ដុរមួយរយ | ១.០០០ | ២០០ | ៤០ |
| ដីរបឹងចារ | ៥០០ | ១៥០ | ៣០ |
| ខ្សាច់ម្កាក់ | ២០០ | ២០ | ១០ |
| ខ្សាច់ស្វាយ | ១៥០ | - | - |
| ព្រះថ្ងវាកេត | ១.០០០ | ១៥០ | ៤០ |
| កាព្រាំងស្បូវ | ៣៥០ | ២៥០ | ២០ |
| ជ្រូកទា | ២០០ | ១៥០ | ២០០ |
| កំពង់ភ្នៅ | ៥០០ | ១៥០ | ២០០ |
| តាចាន | ២០០ | ២០០ | ១០ |
| យាយម៉ៅ | ២០០ | ៥០ | ១០ |
| សាកង្កែប | ១.៥០០ | ៥០០ | ៥០ |
| កោះស្នេហ៍ | ៤០០ | ២០០ | ៣០ |
| ស្រែគគីរ | ១.៥០០ | ៥០០ | ១៥ |
| ត្រឡុក | ៧០ | ៤០ | ២០ |
| ព្រះធាតុ | ១.៥០០ | ៥០០ | ១៥ |

| | | | |
|---|---|---|---|
| រើវាល់ | ១.៥០០ | ៣០ | ១៥ |
| គល់រន្ទះ | ១.៥០០ | ៤០ | ២៥ |
| កោះគ្មោត | ៣០០ | ១៥០ | ២០ |
| កន្ទុយកោះព្រេង | ៧០០ | ១០០ | ១៥ |
| ស្នាកោះរៀល | ១០០ | ៥០ | ១០ |
| កន្ទុយកោះការុងគាវ | ៨០០ | ១៥០ | ១០ |

*ប្រភព : Chan and Putrea (undated), Department of Fisheries, Kratie Province*

### ៤.៦.៣. គុណភាព និងបរិមាណទឹកទន្លេ

ការប្រែប្រួលនូវបរិមាណ និងគុណភាពទឹកទន្លេ ត្រូវបានរាយការណ៍ជូនអោយបានដឹងដោយប្រជាជនក្នុងភូមិ។ អ្នកស្រុកបានរកឃើញថា មានកាកសំណល់ប្រេងអណ្តែតលើផ្ទៃទឹក ហើយក្លិនស្អុយនៃទឹកធ្វើអោយមនុស្សវិលមុខ ទឹកប្រែជាល្អក់ និងមានសារ៉ាយបៃតង (អ្នកភូមិនិយមហៅស្លែ)។ ការប្រែប្រួលទៅលើគុណភាពទឹកនេះ ត្រូវបានសន្មត់ថា អាចមានការពាក់ព័ន្ធទៅនឹងការកើនឡើងនូវតំបន់សម្បទានមួយចំនួន និងរុករករ៉ែមាសក្នុងព្រៃនៅតំបន់នេះ ដែលជាហេតុអាចរួមចំណែកក្នុងការធ្វើអោយទឹកកខ្វក់។

របាយការណ៍បច្ចេកទេសរបស់មូលនិធិសង្គ្រោះសត្វព្រៃសាកល WWF (*Verne Dove,* ២០០៨) បានបញ្ជាក់អោយដឹងថា មានសារជាតិគីមីសរីរាង្គ និងជាតិបារតក្នុងទឹកទន្លេមេគង្គក្នុងបរិវេណស្រុកសំបូរ ដែលធ្វើឱ្យសត្វផ្សោតក្នុងតំបន់នេះស្លាប់ជាច្រើនក្បាល។ ចាប់ពីឆ្នាំ ២០០៣-២០០៨ សត្វផ្សោតបានស្លាប់ជារៀងរាល់ឆ្នាំជាមួយនឹងការរាយការណ៍មួយអោយដឹងថាមានផ្សោត ចំនួន៨៨ក្បាលហើយដែលបានស្លាប់ ហើយអត្រាស្លាប់របស់សត្វផ្សោតក្នុងឆ្នាំ២០០៦ គឺខ្ពស់ជាងគេបំផុត (*Verne Dove,* ២០០៨)។ ករណីសិក្សារបស់ WWF បានបញ្ជាក់អោយដឹងថាកំរិតខ្ពស់នៃជាតិបារត ដែលមាននៅក្នុងប្រភេទត្រីមួយចំនួនក្នុងទន្លេមេគង្គបានបង្កទុក្ខទោសដល់មនុស្ស។ នេះហាក់បីដូចជាមានទាក់ទងនឹងការកើនឡើងនូវចំការកសិកម្មធំៗ និងសកម្មភាពរុករករ៉ែនៅក្នុងស្រុកនេះ។

សារជាតិស្លែពណ៌បៃតង បានកត់សំគាល់ដោយអ្នកភូមិថាមានក្នុងរយៈពេលបីទៅបួនឆ្នាំមុន។ ស្លែបៃតងនេះ អាចស្តែងអោយឃើញ និងឡើងក្រាស់នៅរដូវប្រាំង ពិសេសនៅពេលចាំងនឹងពន្លឺថ្ងៃ ហើយតាមធម្មតានៅពេលទឹករាក់បំផុត។ ស្លែបៃតងដ៏ក្រាស់នេះ អាចបង្អាក់ដល់ដំណើរនាវាចរណ៍របស់កាណូតតូចធំបាន និងសកម្មភាពនេសាទ ហើយនឹងចរាចររបស់ត្រីផងដែរ។ អ្នកភូមិបានរាយការណ៍ថា ស្លែដ៏ក្រាស់នេះបានសៀតជាប់នឹងស្លាបចក្រកាណូត ធ្វើឱ្យពិបាកបញ្ឆេះ និងធ្វើដំណើរ។ អ្នកភូមិបានរាយការណ៍ថា ពេលពួកគាត់នេសាទត្រីដោយប្រើមង ឬសំណាញ់នៅកន្លែងទឹករាក់នោះ ហើយសំណាញ់ ឬមងរបស់ពួកគាត់បានរហែក ឬត្រូវបំផ្លាញ។ ស្លែដ៏ក្រាស់នេះ ក៏ធ្វើអោយ ស្ទះចរាចរណ៍របស់ត្រីតូចៗផងដែរ។

ការប្រែប្រួលទឹកនៃទន្លេមេគង្គឡើង និងស្រកត្រូវបានកត់សំគាល់ និងជួបប្រទះតាំងពីឆ្នាំ២០០២មកម្ល៉េះ។ អ្នកភូមិបានរៀបរាប់ថាពេលរដូវទឹកឡើងកំរិតទឹកទន្លេហាក់បីដូចជាមិនឡើងធំតាមរដូវកាល ហើយចំណែករដូវស្រកវិញកំរិតទឹកបែរជាស្រកចុះខ្លាំងហួសពីការស្មានបើប្រៀបធៀបមុនឆ្នាំ២០០២។ អ្នកភូមិមួយចំនួនបញ្ជាក់ថា ដោយសារតែមានការសាងសង់ទំនប់វ៉ារីអគ្គិសនីនៅផ្នែកខាងលើ ទើបធ្វើអោយមានការផ្លាស់ប្តូរទាំងនេះកើតមានឡើង។ ការប្រែប្រួលកំរិតទឹកនេះ បានធ្វើមានផលវិបាកក្នុងការបូមទឹកបញ្ចូលស្រែ និងតម្លៃកាន់តែថ្លៃទៅៗ ។

ប្រជាជនក្នុងភូមិជឿជាក់ថា ការបាក់ដីច្រាំងទន្លេក្នុងតំបន់នេះ និងការបាក់ដីនៅផ្នែកខាងលើធ្វើអោយទន្លេកាន់តែរាក់ទៅ និងធំទៅៗ។ ដីដែលកើតឡើងពីការបាក់ច្រាំងនេះ បានលុបបំបាត់នូវជួរទឹក និងអន្លង់ត្រីជាច្រើន ដែលជាទីជម្រកដ៏សំខាន់សំរាប់ត្រីជ្រក និងពងកូន។ អ្នកភូមិខ្លះបានបញ្ជាក់បន្ថែមថា ការធ្វើដំណើរជាមួយទូកធំៗមួយចំនួន គឺជាកត្តាមួយដែលបំផ្លាញដីច្រាំងទន្លេ និងបានពង្រួញបរិវេណដីសំរាប់ដាំបន្លែតាមច្រាំងទន្លេរបស់អ្នកភូមិទៀតផង។

## ៤.៧. វិស័យទេសចរណ៍

គំរោងកម្មវិធីអេកូទេសចរណ៍សហគមន៍ ត្រូវបាននឹងកំពុងអនុវត្តក្នុងភូមិគោលដៅសិក្សាចំនួនបីដែលបានចុះទៅសិក្សា ដូចជាភូមិសំភិន កោះផ្តៅ និងភូមិខ្សាច់លាវ។ គំរោងនេះទាក់ទាញអ្នកទេសចរណ៍ជាច្រើន ហើយអ្នកទេសចរណ៍បរទេសចំនួន ២០០នាក់ ត្រូវបានកត់ត្រា

ថាបានមកទស្សនានៅតំបន់នេះ។ ការសិក្សាទៅលើការចំណាយ និងការចំណេញដែលបានពីវិស័យគំរោងអេកូទេសចរណ៍ក្នុងភូមិទាំងនេះមិនមែនជាគោលបំណងនៃ ករណីសិក្សានេះទេ។ ប៉ុន្តែការឆ្លុះបញ្ចាំងរបស់សហគមន៍ ជាពិសេសចំពោះអ្នកដែលបានធ្វើការពាក់ព័ន្ធជាមួយ គម្រោងអេកូទេសចរណ៍នេះផ្ទាល់បានលើកឡើងថា ប្រាក់ចំណូលតិចតួចបំផុតដែលពួកគាត់អាចរកបាន តែមានប្រជាពលរដ្ឋមួយចំនួនយល់ថាពួកគាត់អាចរកចំណូលបានច្រើនពីវិស័យនេះ។

វិស័យទេសចរណ៍ក្នុងស្រុកហាក់បីដូចជាមានភាពលំអៀងជាមួយគោលបំណងនៃការអភិរក្សសត្វផ្សោត។ របាយការណ៍មូលនិធិសង្គ្រោះសត្វព្រៃសាកល WWF (*Verne Dove,* ២០០៨) បានចង្អុលប្រាប់អោយដឹងថា វិស័យទេសចរណ៍ទំនងជាទាក់ទាញអ្នកទេសចរណ៍បានច្រើនទើបធ្វើអោយមានកើនឡើងនូវចំនួនទូកនៅលើដងទន្លេមេគង្គ។ ការកើនឡើងនូវចំនួនទូកលើដងទន្លេមេគង្គដ៏ច្រើននេះ បានដាក់ទំងន់លើសត្វផ្សោតក្នុងទន្លេមេគង្គ ព្រោះថាសត្វផ្សោតត្រូវតែនៅក្នុងបាតទឹករយៈពេលយូរជាងធម្មតា។ ការដែលសត្វផ្សោតសំងំហែលនៅក្នុងទឹកយូរពេកជាកត្តា ដែលធ្វើអោយសត្វផ្សោតមានជំងឺ ពិសេសចំពោះផ្សោតដែលបង្កើតកូន ឬផ្សោតតូចទើបនឹងកើតអាចបណ្តាលអោយស្លាប់បាន។

ទោះជាយ៉ាងណាក៏ដោយ មានប្រជាជនក្នុងភូមិជាច្រើនបានបញ្ជាក់ថា គំរោងអភិរក្សសត្វផ្សោតនេះបាននាំអោយកើតមានគំរោងទេសចរណ៍នៅក្នុងភូមិរបស់ពួកគេ។ គំរោងទាំងពីរនេះត្រូវបានយល់ច្បាស់ដោយប្រជាជនក្នុងភូមិ ថាជាគំរោងដែលបានចំណាយធនធានថវិកាតិចបំផុតដើម្បីអនុវត្តវា ហើយជាការងារអភិរក្សថែរក្សាទៅលើអ្វីៗដែលពួកគេមានពីមុនមកក្នុងខេត្ត ដែលសព្វថ្ងៃគំរោងនេះ បានហាមឃាត់ទៅលើការប្រើប្រាស់ឧបករណ៍នេសាទបែបប្រពៃណីមួយចំនួនដូចជាមងធំៗជាដើម។ ការហាមឃាត់លើការប្រើប្រាស់ឧបករណ៍នេសាទប្រភេទនេះ ត្រូវបានប្រជាជនក្នុងភូមិធ្វើការទិទៀន ពិសេសចំពោះក្រុមដែលបាត់បង់ផលប្រយោជន៍។ ការផ្លាស់ប្តូរនូវប្រភេទមង និងទំហំរបស់វាក្នុងការនេសាទធ្វើអោយបរិមាណត្រីដែលចាប់បានថយចុះ។

## ៤.៨ កម្មវិធីអភិវឌ្ឍន៍ស្រុកសំបូរ

មានភ្នាក់ងារអភិវឌ្ឍន៍ផ្សេងៗគ្នាដែលធ្វើប្រតិបត្តិការនៅក្នុងស្រុកសំបូរនេះ រាប់បញ្ចូលទាំងភូមិដែលបានធ្វើការស្រាវជ្រាវ។ មានអង្គការអុកស្វាមអូស្ត្រាលី ធ្វើការងារលើគម្រោង

អភិវឌ្ឍន៍សហគមន៍ចំរុះ និងគម្រោងកាត់បន្ថយគ្រោះមហន្តរាយ អង្គការ WD ធ្វើការងារលើកម្មវិធីអប់រំរបស់កុមារក្រីក្រ អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED) ធ្វើការងារលើសហគមន៍ព្រៃឈើ និង សិទ្ធិជនជាតិដើមភាគតិច អង្គការមូលនិធិសង្គ្រោះសត្វព្រៃសាកល (WWF) ធ្វើការងារលើការអភិរក្សសត្វផ្សោតទន្លេមេគង្គ និង អង្គការក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT) ធ្វើការលើកម្មវិធីអេកូទេសចរណ៍ និង ការចិញ្ចឹមជីវិតរបស់សហគមន៍។ នៅក្នុងនោះក៏មានគម្រោងដែលអនុវត្តដោយភ្នាក់ងាររដ្ឋាភិបាលនៅមូលដ្ឋានផងដែរ។

ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ គឺមានដែនកំណត់នៅក្នុងភូមិនីមួយៗ ដែលបានធ្វើការស្រាវជ្រាវ ដែលភាគច្រើននៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តគឺផ្លូវលំ។ ប្រជាពលរដ្ឋនៅតំបន់នោះប្រើប្រាស់កង់ និងម៉ូតូ ដើម្បីជាមធ្យោបាយធ្វើដំណើរ ប៉ុន្តែសម្រាប់ភូមិដែលនៅលើកោះ គឺត្រូវប្រើប្រាស់ទូក ឬកាណូត ដើម្បីធ្វើដំណើរទៅទីរួម ស្រុកសំបូរ និងទីរួមខេត្តក្រចេះ។ នៅក្នុងស្រុកនេះមានកំពង់ចម្លងឯកជនផងដែរសម្រាប់បម្រើឱ្យការដឹកជញ្ជូនទៅមក ប៉ុន្តែទោះបីជាយ៉ាងណាការដឹកញ្ជូននេះគឺមានចំនួនកំណត់។

ផ្ទះមួយចំនួនធំ នៅក្នុងភូមិដែលបានធ្វើការស្រាវជ្រាវ មិនមានបង្គន់អនាម័យនោះទេ ប៉ុន្តែមានកន្លែងដែលបានកំណត់ថាជាបង្គន់សម្រាប់គ្រួសាររបស់ពួកគេនីមួយៗ។ កង្វះខាតបង្គន់អនាម័យគឺអាចជះឥទ្ធិពលដល់សុខភាពប្រជាពលរដ្ឋ ជាពិសេសប៉ះពាល់ដល់កុមារ និងមនុស្សចាស់។ម្យ៉ាងវិញទៀត បើយោងតាមតួលេខរបស់ វិទ្យាស្ថានជាតិស្ថិតិ ២០០៩ បានបញ្ជាក់ថាចំនួន ៧៣,៧៣% នៃប្រជាជនសរុបក្នុងខេត្តក្រចេះមានបង្គន់អនាម័យ ខណៈពេលដែលអាងទទួលទឹកសំអុយមានចំនួន ១៤,២៥%, បង្គន់ (Latrine) ចំនួន ៦,៥% និង បង្គន់បំពង់បង្ហូរ (Sewerage) ចំនួន ៣,២៣%។ នៅក្នុងភូមិនីមួយៗមានវត្តអារាមដែលបានសាងសង់ឡើងដោយកម្លាំង និងថវិការបស់ប្រជាពលរដ្ឋ។ មានតូបលក់ម្ហូបតូចៗដែលដាក់លក់ដូចជា អំបិល ស្ករស ប្រេងសាំង សាប៊ូ និងគ្រឿងផ្សេងៗទៀតដែលជាតម្រូវការរបស់គ្រួសារក្នុងសហគមន៍។

## ៤.៩ ប្រព័ន្ធអគ្គិសនី

ស្រុកសំបូរមានអ្នកផ្គត់ផ្គង់អគ្គិសនីឯកជនមួយ ដែលដំណើរការដោយម៉ាស៊ីនភ្លើង ប្រើប្រាស់ថាមពលប្រេងប្រព័ន្ធអគ្គិសនីក្នុងមួយគីឡូវ៉ាត់ម៉ោងមានតម្លៃ២.០០០រៀល។ ប៉ុន្តែ

ទោះជាយ៉ាងនេះក៏ដោយ ក៏ភូមិដែលបានធ្វើការស្រាវជ្រាវមិនមានការផ្គត់ផ្គង់ប្រព័ន្ធអគ្គិសនីនោះទេ ភាគច្រើននៃគ្រួសារប្រើប្រាស់អាគុយ និងចង្កៀងប្រេងកាត ដើម្បីបំភ្លឺនៅពេលយប់។ វិទ្យាស្ថានជាតិស្ថិតិ ២០០៩ បានបញ្ជាក់ថា ៤៨,៨៤% ប្រើប្រាស់ប្រេងកាត ៣៦% ប្រើប្រាស់អាគុយ និង ០,៦៤% ផ្សេងទៀតប្រើប្រាស់ថាមពលដែលបានមកពីម៉ាស៊ីនភ្លើង។

លោក ផាន់ ផល្លា អគ្គលេខាធិការរងនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិកម្ពុជា បានបញ្ជាក់កាលពីឆ្នាំ២០០៩ ថាមានប្រភពថាមពលផ្សេងទៀតដែលមានសក្តានុពលក្នុងប្រទេសកម្ពុជា ក្រៅពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីមានដូចជាថាមពលពន្លឺព្រះអាទិត្យ ជីវៈម៉ាស់ ជីវៈឧស្ម័ន ថាមពលខ្យល់ ថាមពលប្រេង និង ថាមពលឧស្ម័ន (Phan, ២០០៩)។ ការពិភាក្សាថ្មីៗនេះនៅឯសិក្ខាសាលាមួយស្តីអំពីព្រែកទាំងបួន (4P) នៃទន្លេមេគង្គ ដែលបានប្រារព្ធធ្វើឡើងនៅក្នុងខេត្តក្រចេះកាលពីថ្ងៃទី១៨-២០ ខែមករា ដើមឆ្នាំ២០១០ បានកំណត់ពីផែនការនានាដើម្បីសាងសង់ទំនប់វារីអគ្គិសនីខ្នាតតូចដែលមានទំហំ ១០មេហ្គាវ៉ាត់ នៅលើព្រែកទាំងបួន (4P) របស់ទន្លេមេគង្គ។ គម្រោងទំនប់វារីអគ្គិសនី ព្រែកទាំងបួន (4P) នេះត្រូវបានចាត់ទុកថាជាគម្រោងថាមពលវារីអគ្គិសនីដែលដើរតួនាទីយ៉ាងសំខាន់តូចមួយក្នុងការអភិវឌ្ឍន៍ ថាមពលរយៈពេលវែងនៅក្នុងប្រទេស។

# ៥. បញ្ហា និងការគំរាមកំហែងនានាទៅលើជីវភាពរស់នៅ

ការស្រាវជ្រាវបានធ្វើឡើង ដើម្បីបង្ហាញឱ្យឃើញនូវចំនួននៃបញ្ហា និងការគំរាមកំហែងនានាទៅនឹងជីវភាពរស់នៅលទ្ធផលទាំងអស់នេះ បានមកពីការសំភាសន៍នៅក្នុងភូមិចំនួន ៦ ដែលភូមិទាំងអស់នោះពឹងអាស្រ័យលើទន្លេនៅក្នុងស្រុកសំបូរ។ គំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីមេគង្គភាគខាងលើនៅក្នុងស្រុកសំបូរ បានធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់ការិតជីវភាព និងធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ទីជំរក។ បញ្ហាផ្សេងទៀតនោះត្រូវបានរកឃើញថាមានការជាប់ពាក់ព័ន្ធទៅនឹងធនធានព្រៃឈើ មូលដ្ឋានសេវាកម្មសង្គម អភិបាលកិច្ច និងសកម្មភាពខុសច្បាប់ដែលបានកាត់បន្ថយធនធាននានាប្រសិនបើមិនមានការត្រួតពិនិត្យជាប្រចាំទេនោះ។

## ៥.១ ការភ័យខ្លាច ការបារម្ភ និង ភាពមិនប្រាកដប្រជា

ភាគច្រើននៃភូមិទាំង ៥២ របស់ស្រុកសំបូរ គឺជាភូមិដែលនៅជាប់នឹងទន្លេ ហើយអាស្រ័យផលយ៉ាងខ្លាំងទៅលើលំហូរទឹកតាមរដូវកាលរបស់ទន្លេមេគង្គ និងធនធានវារីជាតិ។ គម្រោងទំនប់វារីអគ្គិសនីស្រុកសំបូរបានធ្វើឱ្យអ្នកភូមិគិត និងមានអារម្មណ៍ភ័យខ្លាយបារម្ភមានអារម្មណ៍អសន្តិសុខ និងមានភាពមិនប្រាកដប្រជា។ សេចក្តីបារម្ភភាគច្រើនដែលស្តែងចេញពីប្រជាពលរដ្ឋគឺ ការភ័យខ្លាយក្នុងការរើទីលំនៅ និងឥទ្ធិពលអាក្រក់ដែលកើតមានឡើងជាបន្តបន្ទាប់ទៀតដូចជាបាត់បង់ចំណូលក្នុងការចិញ្ចឹមជីវិត បាត់បង់ផ្ទះសម្បែង និង វិនាសកម្មនៃ ព្រៃឈើ និងទន្លេ ដែលពួកគេពឹងផ្អែកសម្រាប់ជីវភាពរស់នៅ។

ប្រជាពលរដ្ឋមានអារម្មណ៍មិនប្រាកដប្រជាពីតំបន់ដែលត្រូវតាំងទីលំនៅនាពេលអនាគតនោះ ហើយពួកគាត់កាន់តែមានការព្រួយបារម្ភអំពីការរស់នៅ និងជីវភាពរបស់ពួកគាត់ភាគច្រើនគាត់បាននិយាយថាឥឡូវនេះ ពួកគាត់ចាស់ហើយ ការផ្លាស់ប្តូរទីកន្លែងរស់នៅមានន័យថាចាប់ផ្តើមជីវិតថ្មី ដូចនេះគាត់ត្រូវចំណាយថវិកាដើម្បីសាងសង់ផ្ទះសម្រាប់គ្រួសារ។

សេចក្តីបារម្ភផ្សេងទៀតនោះគឺត្រូវបាត់ទីតាំងប្រវត្តិសាស្ត្រ និងវាលកប់ខ្មោចសាលារៀនមន្ទីរពេទ្យ មណ្ឌលសុខភាព ប៉ះពាល់សុខភាព បាត់បង់ដីដែលមានជីជាតិបាត់បង់វាលស្រែ បាត់បង់

ប្រព័ន្ធស្រោចស្រព បាត់បង់ការចិញ្ចឹមសត្វ និងធនធានវារីជាតិ ហើយពួកគេនឹងបាត់បង់ផងដែរនូវសារៈប្រយោជន៍ផ្សេងទៀត ដែលទន្លេមេគង្គបានផ្តល់ឱ្យពួកគាត់ ដូចជាការរស់នៅការចិញ្ចឹមជីវិត ព្រមទាំងអាហារ ហើយនឹងអ្វីៗស្ទើរតែគ្រប់យ៉ាងដែលផ្តល់ជីវិតរស់នៅដ៏ស្ងប់ស្ងាត់នៅក្នុងភូមិរបស់ពួកគេ។

## ៥.២ សន្តិសុខស្បៀង និង សុខភាព

ប្រជាពលរដ្ឋបានបញ្ជាក់ថាជីវភាពរស់នៅ និងប្រភពចំរុះនៃចំណូលបានផ្តល់ឱ្យពួកគាត់នូវស្បៀងហូបចុកគ្រប់គ្រាន់តាំងពីយូរយាណាស់មកហើយ ដោយសារតែភាពសំបូរបែបនៃទន្លេមេគង្គនេះ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាស្តីពីការតាំងទីលំនៅថ្មីហាក់ត្រូវបានផ្តាច់ប្រជាពលរដ្ឋពីទន្លេមេគង្គនេះ វាអាចនឹងជះឥទ្ធិពលដ៏ធ្ងន់ធ្ងរទៅដល់ការផ្គត់ផ្គង់ចំណីអាហាររបស់ពួកគេ និងប្រភពនៃសារធាតុបំប៉នផ្សេងៗទៀត ដូចជាត្រីដែលជាប្រភពនៃប្រូតេអ៊ីនដ៏សំខាន់។ ការផ្លាស់ប្តូរប្រព័ន្ធនៃការរស់នៅនាពេលបច្ចុប្បន្ន អាចមានឥទ្ធិពលទៅដល់ការផ្លាស់ប្តូររបបអាហារនិងវប្បធម៌របស់ពួកគេ។ សេចក្តីព្រួយបារម្ភដ៏ធ្ងន់ធ្ងរបំផុតដែលបានស្តែងចេញពីប្រជាពលរដ្ឋភាគច្រើន នៅក្នុងភូមិដែលបានធ្វើការស្រាវជ្រាវនោះបានបង្ហាញឱ្យឃើញថា ការផ្លាស់ប្តូរស្ថានភាពរបស់ពួកគេនៅថ្ងៃអនាគត នឹងមានការគំរាមកំហែងដល់សន្តិសុខស្បៀង។ ប្រជាពលរដ្ឋនៅបានគិតអំពីបញ្ហាសុខភាពនៅថ្ងៃអនាគតផងដែរ ហើយថែមទាំងកំពុងពិចារណាទៅលើលក្ខខ័ណ្ឌសុខភាពជាប្រចាំនៃប្រជាពលរដ្ឋនៅក្នុងភូមិរបស់ពួកគេ។

## ៥.៣ តម្លាភាព និង គណនេយ្យភាព

កង្វះខាតព័ត៌មានច្បាស់លាស់ទាក់ទងទៅនឹងស្ថានភាពនៃផែនការគម្រោងទំនប់វារីអគ្គិសនីសំបូរធ្វើឱ្យប្រជាពលរដ្ឋមានការភ័យខ្លាច អសន្តិសុខ និង សេចក្តីព្រួយបារម្ភកាន់តែខ្លាំងឡើង។ ការយល់ឃើញរបស់ ប្រជាពលរដ្ឋផ្សេងៗគ្នាធ្វើឱ្យមានប្រតិកម្ម និងការគិតក៏ផ្សេងគ្នាដែរ។ មនុស្ស ៣ទៅ៤នាក់ យល់ឃើញថាទំនប់វារីអគ្គិសនីនឹងផ្តល់ឱ្យពួកគេនូវភ្លើងប្រើប្រាស់ផ្លូវថ្នល់ និងស្ពាន ដែលមានសារៈសំខាន់ទៅដល់ការចិញ្ចឹមជីវិតរបស់ពួកគេ។ ប៉ុន្តែអ្នកខ្លះបានយល់ថាវាអាចរារាំងផែនការរយៈពេលវែងរបស់ខ្លួនដូចជាការសាងសង់ផ្ទះ ការដាំរុក្ខជាតិ ហូបផ្លែ ដូចជា

ដើមស្វាយជាដើម និងពីរទៅបីនាក់ផ្សេងទៀតគិតពីការបំលាស់ទីចេញពីភូមិរបស់ពួកគាត់តែម្តង ។ ប្រជាពលរដ្ឋបានរាយការណ៍ថា ពួកគេបានពន្យាការគិតអំពីផែនការអនាគតរបស់ខ្លួនដែលនេះគឺអាចជះឥទ្ធិពលទៅដល់កូនចៅរបស់គេពិសេសបញ្ហានៃការអប់រំ ។ ទោះបីជាផែនការនៃការសាងសង់ទំនប់នេះមិនទាន់លេចចេញជារូបរាងក៏ដោយ ក៏វាបានបណ្តាលឱ្យមានការព្រួយបារម្ភច្រើនយ៉ាងពីសំណាក់ប្រជាជនរួចទៅហើយ ។

ជាមួយគ្នានោះដែរ ឥទ្ធិពលនៃទំនប់វារីអគ្គិសនី ហាក់បីដូចជារីកសាយភាយទូលំទូលាយនៅក្នុងភូមិនានា ហើយប្រជាពលរដ្ឋកំពុងតែស្វែងរកការបញ្ជាក់ រឺចម្លើយមួយ ក៏ប៉ុន្តែមិនមាននរណាម្នាក់ទទួលខុសត្រូវ ឬអើពើក្នុងការពិភាក្សាជាមួយសហគមន៍ស្តីពីបញ្ហានេះឡើយ ។ អាជ្ញាធរមូលដ្ឋានមិនបានចែករំលែកព័ត៌មាន និងតែងតែច្រានចោលនូវទំរង់សំណួរនានាអំពីគម្រោងទំនប់វារីអគ្គិសនី ។ ទោះបីជាយ៉ាងណា អាជ្ញាធរទាំងនោះធានាចំពោះប្រជាពលរដ្ឋថារដ្ឋាភិបាលនឹងគិតគូដល់ប្រជាពលរដ្ឋ និងធ្វើការសិក្សាយ៉ាងប្រុងប្រយ័ត្នបំផុតនៅពេលដែលមានគម្រោងទំនប់វារីអគ្គិសនី ។

## ៥.៤ គម្រោងអភិវឌ្ឍន៍នានាបានរាំងស្ទះ

ផែនការគម្រោងទំនប់វារីអគ្គិសនីសំបូរជះឥទ្ធិពលទៅដល់កម្មវិធីអភិវឌ្ឍន៍ និង គម្រោងនានានៅក្នុងស្រុកសំបូរ ប្រជាពលរដ្ឋហាក់បាត់បង់នូវទឹកចិត្ត ការចាប់អារម្មណ៍នៅក្នុងការវិនិយោគ និងសកម្មភាពនៃការអភិវឌ្ឍន៍សហគមន៍ ដើម្បីកែលំអភូមិដ្ឋានរបស់ពួកគេ ដែលប្រជាពលរដ្ឋបច្ចុប្បន្នកំពុងតែត្រេកអរចំពោះការងាររបស់ភ្នាក់ងារអភិវឌ្ឍន៍ ឧទាហរណ៍ដូចជាអង្គការអុកស្វាមអង់គ្លេស ។ ម្យ៉ាងវិញទៀត គម្រោងទំនប់វារីអគ្គិសនី រាំងស្ទះដល់កម្មវិធីអភិវឌ្ឍន៍សហគមន៍ក្នុងស្រុករបស់ភ្នាក់ងារអភិវឌ្ឍន៍ និងរដ្ឋាភិបាលខ្លួនឯងទៀតផង ។ នៅក្នុងស្រុកសំបូរទាំងមូល មូលដ្ឋានសេវាកម្មសង្គមមានតិចតួចបំផុត និងកាន់តែតិចទៅៗព្រោះតែល័ក្ខខ័ណ្ឌគម្រោងទំនប់វារីអគ្គិសនីនេះ ។

## ៥.៥ សំណឹកច្រាំងទន្លេ

ប្រជាពលរដ្ឋបានសង្កេតឃើញថា ទន្លេគឺមានសភាពរាក់ជាងកាលពី ៥ ទៅ ១០ ឆ្នាំមុន ហើយនឹងកាន់តែរាក់ទៅៗ។ កត្តាផ្សេងៗទៀត ដូចជាការបាក់ច្រាំងធ្វើឱ្យទន្លេកាន់តែមានសភាពធំឡើង ដូចនេះវាកាត់បន្ថយដីកសិកម្ម សួនបន្លែកាន់តែតូចទៅៗ។ មានការព្រួយបារម្ភជាច្រើនអំពីសំណឹកដីច្រាំងទន្លេ និងសំណឹកដីទន្លេភាគខាងលើ ប្រជាពលរដ្ឋបានបញ្ជាក់ថា សំណឹកដីនេះធ្វើឱ្យទន្លេកាន់តែរាក់ខណៈពេលដែលដីទាំងអស់នោះចាក់បំពេញអន្លង់ជ្រៅៗនានានៅក្នុងបាតទន្លេ។

## ៥.៦ បរិមាណ និង គុណភាពទឹកទន្លេ

ការផ្លាស់ប្តូរបរិមាណ និងគុណភាពទឹកត្រូវបានធ្វើការអង្កេតនៅក្នុងឆ្នាំ២០០២។ ទឹកទន្លេមេគង្គខណៈពេលរដូវទឹកឡើងគឺទឹកទាបជាងពេលមុន ហើយនៅរដូវទឹកស្រក គឺទឹកមានសម្ថភាពរាក់ជាងពេល មុនផងដែរ។ ប្រជាពលរដ្ឋ ខ្លះបានចាត់ទុកថាការផ្លាស់ប្តូរនាពេលបច្ចុប្បន្ននេះគឺបណ្តាលមកពីទំនប់វារីអគ្គិនីដែលបានសាងសង់នៅទន្លេភាគខាងលើ បើទោះបីជាពួកគេទាំងនោះគ្មានភស្តុតាងដើម្បីបញ្ជាក់ក៏ដោយ។ ប្រជាពលរដ្ឋបានរាយការណ៍ផងដែរអំពីការថយចុះផលចាប់ត្រី ក្លិនប្លែករបស់ទឹកធ្វើឱ្យប្រជាពលរដ្ឋវិលមុខ និងកាកសំណល់ជាតិប្រេងនៅលើផ្ទៃទឹកទន្លេ។

សម្រាប់រយៈពេល ៣-៤ឆ្នាំមុន ប្រជាពលរដ្ឋបានសង្កេតឃើញថាមានសារ៉ាយបៃតង (green algae) ដែលពួកគាត់តែងហៅវាថាស្លែ (moss)។ ស្លែបៃតងអាចមើលឃើញកាន់តែច្បាស់នៅរដូវក្តៅ។ ស្លែបៃតងនេះនឹងកាន់តែក្រាស់ទៅៗនៅពេលដែលកំរិតទឹកកាន់តែរាក់ និងជាពិសេសនៅពេលដែលវាប៉ះទៅនឹងពន្លឺព្រះអាទិត្យ។ ស្លែបៃងប្រភេទនេះ អាចបំផ្លាញទូកកាណូត សំណាញ់ និងបង្អាក់ការបំលាស់ទីរបស់ត្រី ជាពិសេសត្រីតូចៗដែលបំលាស់ទីនៅក្នុងទឹករាក់។ ជាងនេះទៀត ជំងឺមួយចំនួនដែលមិនស្គាល់ឈ្មោះក្នុងភូមិបានធ្វើឱ្យប្រជាពលរដ្ឋស្លាប់ករណីដូចជាស្លាប់ដោយសារជំងឺធំពោះ (ស៊ីស្តូ) ដែលមានពាក់ព័ន្ធទៅនឹងទឹកទន្លេ។

មានការកើនឡើង នូវការបំពុលទឹកដោយសារតែសម្បទានខ្នាតធំ និងសកម្មភាពនៃការរុករករ៉ែនៅក្នុងព្រៃ។ សកម្មភាពនេះ បានប៉ះពាល់ទៅដល់ការប្រកបរបរចិញ្ចឹមជីវិតលក្ខណៈប្រពៃណីរបស់ជនជាតិដើមភាគតិចដែលរស់នៅក្បែរៗភូមិនេះ ដោយសារពួកគេត្រូវបានហាមឃាត់មិនឱ្យចូលទៅក្នុងព្រៃ ដើម្បីប្រមូលអនុផលព្រៃឈើសំរាប់ការចិញ្ចឹមជីវិតជាលក្ខណៈ

ប្រពៃណីដែលនេះ ធ្វើឱ្យមានការប៉ះពាល់ទៅដល់ប្រព័ន្ធនៃការចិញ្ចឹមជីវិត និងជីវិតរស់នៅរបស់ពួកគាត់។

## ៥.៧ សម្បទានដី និង សកម្មភាពនិស្សារណកម្ម

មានផ្នែកជាច្រើននៃព្រៃឈើដែលបច្ចុប្បន្ន ត្រូវបានផ្តល់សម្បទាន និង ឈូសឆាយសម្រាប់ចំការឈើដាំ។ អ្នកភូមិបានជឿជាក់ថាសកម្មភាពទាំងនេះបណ្តាលអោយមានសំណឹកដី។ ក្រុមហ៊ុនភាពីម៉ិច ដែលជាម្ចាស់ចំការឈើដាំដើម្បីផលិតក្រដាសនៃតំបន់សម្បទានមួយក្នុងចំណោមតំបន់សម្បទានដ៏ទៃទៀត ប្រើប្រាស់ទន្លេសម្រាប់ជាមធ្យោបាយដឹកជញ្ជូនឈើហ៊ុបរបស់គេ។ ក្រុមហ៊ុនរ៉ែមាសមួយ ដែលមានការពាក់ព័ន្ធនឹងក្រុមហ៊ុនខាងលើហៅថា ក្រុមហ៊ុនរ៉ែអន្តរជាតិ-កម្ពុជា បានធ្វើប្រតិបត្តិការរបស់ខ្លួននៅក្នុងព្រៃ។ ការប្រតិបត្តិការក្រុមហ៊ុនរ៉ែនេះត្រូវបានស្តីបន្ទោសដោយប្រជាពលរដ្ឋ ព្រោះក្រុមហ៊ុនធ្វើឱ្យមានការបំពុលទឹកទន្លេដែលធ្វើឱ្យប៉ះពាល់ដល់សត្វគោ ក្របីរបស់ប្រជាពលរដ្ឋ។

កាសែតក្នុងស្រុកមួយឈ្មោះថា រស្មីកម្ពុជាចេញផ្សាយកាលពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០០៨ បានដកស្រង់ពាក្យសម្តីរបស់ លោក គុយ ហួត ប្រធានមន្ទីរកសិកម្មខេត្តក្រចេះថា មានក្រុមហ៊ុនចំនួន ១០ ដែលបានផ្តល់ដីចំនួន ៧០.០០០ហិកតា សម្រាប់ដីសម្បទានសេដ្ឋកិច្ច នៅក្នុងខេត្តក្រចេះ។ ក្រុមហ៊ុនចំនួន ៦ នៅក្នុងចំណោម១០ខាងលើបាននឹងកំពុងតែប្រតិបត្តិការ នៅក្នុងស្រុកសំបូរ។ មុននេះនៅក្នុងឆ្នាំ២០០៦ ប្រទេសកម្ពុជាបានផ្តល់សម្បទានឱ្យក្រុមហ៊ុនសម្បទានចំនួន ៥៩ក្រុមហ៊ុន នូវផ្ទៃដីសរុបចំនួន ៩៤៣.០៦៩ ហិកតា នៅក្នុងខេត្តចំនួន១៥ ដែលសម្បទានខ្លះនៅក្នុងខេត្តក្រចេះ ជាមួយនឹងចំនួនដ៏ច្រើនលើសលប់ផ្តុំគ្នានៅក្នុងខេត្តស្ទឹងត្រែង។ ចំនួនសរុបនៃដីសម្បទានប្រតិបត្តិការនៅក្នុងខេត្តក្រចេះមានចំនួនប្រមាណជា ៥.២% នៃចំនួនសម្បទានសរុបក្នុងប្រទេស និង ១៤.៥% នៃចំនួនផ្ទៃដី ដែលអាចដាំដុះបានក្នុងប្រទេសកម្ពុជា (OHCHR, ២០០៧)។

## ៥.៨ ការឆ្លើយតបរបស់អ្នកភូមិ

ប្រជាពលរដ្ឋនៅក្នុងភូមិដែលបានធ្វើការស្រាវជ្រាវ បានបង្ហាញអំពីចំណង់ក្នុងការតស៊ូមតិ ដើម្បីបញ្ឈប់ផែនការគម្រោងតំបន់វារីអគ្គិសនីសំបូរភាគច្រើននៃប្រជាពលរដ្ឋទាំងអស់នោះ បាន និយាយថាពួកគេមិនចង់បានថាមពលអគ្គិសនីពីទំនប់នោះទេ បើទោះបីជាវាផ្តល់ថវិកាដល់ជីវភាព និង ការរស់នៅរបស់ពួកគេក៏ដោយមានប្រជាពលរដ្ឋចំនួន ៣នាក់ ក្នុងចំណោម ១០ ដែលបានផ្តល់ ចំលើយថា វាមានការល្អប្រសើរជាមួយនឹងទំនប់វារីអគ្គិសនី និងការតាំងទីលំនៅថ្មី ព្រោះថា សំណងសមស្របនឹងត្រូវបានផ្តល់ឱ្យពួកគេ។

# ៦. សេចក្តីសន្និដ្ឋាន

*"............ជីវិតរស់នៅ និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋមិនអាចដោះដូរដោយសំណង នោះទេ ហើយទឹក, ព្រៃឈើ និង ដី គឺមានតម្លៃមិនអាចកាត់ថ្លៃបាន............"*។

ការស្រាវជ្រាវទិន្នន័យមូលដ្ឋាននៃការចិញ្ចឹមជីវិតនៅក្នុងស្រុកសំបូរបានសន្និដ្ឋានថា ការដាក់បញ្ចូលគ្នា និង ការបំពេញបន្ថែមនៃកសិដ្ឋានដាំដុះដំណាំស្រូវ ការនេសាទ សួនបន្លែតាមច្រាំងទន្លេ ការចិញ្ចឹមសត្វ ការស៊ីឈ្នួល លក់កំលាំងពលកម្មតាមរដូវកាល និង ការកាប់ឈើជាលក្ខណៈគ្រួសារ គឺជាសកម្មភាពចំបងក្នុងការចិញ្ចឹមជីវិត និងជាប្រភពចំណូលស្ទើរតែគ្រប់ក្រុមគ្រួសារនៅក្នុងភូមិដែលបានធ្វើការស្រាវជ្រាវ ។

ប្រភពសំខាន់ផ្សេងទៀតនៃប្រាក់ចំណូល គឺបានមកពីការលក់រុក្ខជាតិហូបផ្លែ ការបរបាញ់សត្វព្រៃ និងការដកហូតអនុផលព្រៃឈើដូចជាជ័រទឹក។ ជាងនេះទៅទៀតប្រភពនៃប្រាក់ចំណូលបន្ថែមរួមមានការធ្វើការងារនៅមូលដ្ឋានពាណិជ្ជកម្មខ្នាតតូច និងការគាំទ្រកុមារ។ ទោះបីជាយ៉ាងណាក៏ដោយមុខរបរបន្ថែមខាងលើនេះគឺមាន តែ ៣-៤គ្រួសារប៉ុណ្ណោះ នៅក្នុងភូមិដែលបានធ្វើការស្រាវជ្រាវ ។

## ៦.១ ការចិញ្ចឹមជីវិត និង ទន្លេមេគង្គ

ការស្រាវជ្រាវនេះបានសន្និដ្ឋានថា កសិដ្ឋានដាំដុះដំណាំស្រូវ ការនេសាទ សួនបន្លែតាមច្រាំងទន្លេ និងការលក់កំលាំងពលកម្មតាមរដូវកាល គឺមានការទាក់ទងនឹងរដូវកាលនៃលំហូរទឹក និងធនធានវារីជាតិរបស់ទន្លេមេគង្គ។ នេះបញ្ជាក់ថាភាពពាក់ព័ន្ធគ្នារវាងប្រជាពលរដ្ឋ និងប្រភពប្រាក់ចំណូលចំរុះរបស់ពួកគេនៅក្នុងមួយឆ្នាំៗ។ ស្ថានភាពខាងលើនេះក៏មានអត្ថន័យថា ដើម្បីបំពេញនូវតម្រូវការអាហារប្រចាំថ្ងៃឱ្យគ្រប់គ្រាន់ និងមាននិរន្តរភាពសម្រាប់គ្រួសារនីមួយៗ ការរួមបញ្ចូលគ្នានៃប្រភពប្រាក់ចំណូលរបស់ប្រជាពលរដ្ឋគួរតែមានស្ថេរភាព និងមិនមានផលប៉ះពាល់។ ដូច្នេះបើមានការធ្វើឱ្យរាំងស្ទះដោយប្រការណាមួយដល់ប្រភពនៃប្របាក់ចំណូលរបស់ប្រជាពលរដ្ឋនោះវានឹងធ្វើឱ្យពួកគេងាយទទួលរងគ្រោះ និង ជួបប្រទះនូវភាពក្រីក្របំផុត ។

មានសំពាធដែលស្តែងចេញយ៉ាងច្បាស់លើធនធានធម្មជាតិ ទឹក ដី និងព្រៃឈើអាចមានអទិភាពក្នុងការកាត់ផ្តាច់ប្រភពនៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅថ្ងៃអនាគត ដូចជាការរាំងស្ទះដល់ការទទួលបាននូវធនធានសំខាន់ៗ ដែលជាហេតុបង្កឱ្យមានភាពអត់ឃ្លាន និងភាពក្រីក្រនៅពេលដែលគ្មានការគាំទ្រ និងការការពារពិតប្រាកដនៅទីនោះ។

## ៦.២ មូលដ្ឋានសេវាកម្មសង្គម

មូលដ្ឋានសេវាកម្មសង្គមនៅក្នុងភូមិដែលបានធ្វើការស្រាវជ្រាវ គឺមានកំរិតនៅឡើយ។ ការមិនបញ្ចប់ថ្នាក់បឋមសិក្សានៃការអប់រំ គឺជាចន្លោះខ្វះខាតដែលមាននៅក្នុងភូមិនីមួយៗនៅក្នុងកំឡុងពេលធ្វើការសំភាសន៍។ ទោះបីជាយ៉ាងណាក៏ដោយប្រជាពលរដ្ឋមានការសប្បាយចិត្តក្នុងការទទួលយកវិស័យសិក្សាអប់រំបឋមនៅក្នុងភូមិរបស់ពួកគេ បើទោះបីជាវិស័យសិក្សាអប់រំនេះមិនបានផ្តល់គ្រប់ជ្រុងជ្រោយ និងការសម្របសម្រួលការអប់រំរបស់គ្រូមានដែនកំណត់ក៏ដោយ។ ទោះបីជាយ៉ាងណា បញ្ហាខាងលើនេះអាចធ្វើឱ្យប៉ះពាល់ដល់កុមារក្នុងការចាប់យកការសិក្សាថ្នាក់បឋម និង ថ្នាក់មធ្យមបន្តទៀត។

មណ្ឌលសុខភាពមានតែនៅក្នុងឃុំប៉ុណ្ណោះ ហើយឆ្ងាយពីភូមិដែលបានធ្វើការសំភាសន៍។ ចំងាយពីភូមិរបស់ប្រជាពលរដ្ឋទៅទីរួមស្រុកសំបូរយ៉ាងតិចណាស់ពី ៣ទៅ ៩ គីឡូម៉ែត្រធ្វើដំណើរតាមផ្លូវទឹកទន្លេមេគង្គដោយទូក រឺកាណូត ដែលជាទូទៅពួកគេទៅនៅពេលដែលពួកគេមានជំងឺជាទំងន់។ នៅក្នុងស្រុកសំបូរទាំងមូលមានមណ្ឌលសុខភាពសរុបចំនួន១៣ ដែលក្នុងនោះមណ្ឌលសុខភាពចំនួន៣ ស្ថិតនៅក្នុងទីរួមស្រុកសំបូរ ហើយ ១០ ទៀតឋិតនៅក្នុងឃុំទាំង១០ រីផ្តល់សេវាឱ្យប្រជាជនចំនួន ៥៥.៧០២នាក់នៅក្នុងភូមិចំនួន៥២។ កង្វះខាតសេវា និងគម្រោងសុខភាពសំរាប់ប្រជាពលរដ្ឋនៅក្នុងភូមិ ពេលខ្លះបានធ្វើឱ្យមនុស្សស្លាប់ដោយសារតែជម្ងឺដែលអាចការពារឬអាចព្យាបាលបាន ករណីនេះកើតឡើងជាទូទៅចំពោះប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់ពួកគេ។ ថ្នាំពេទ្យ និង ការចូលសំរាកនៅមន្ទីរពេទ្យមានតម្លៃថ្លៃ បើគិតក្នុងក្របខ័ណ្ឌនៃប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅទីនោះ។

## ៦.៣ ស្ត្រី

ការងារផ្ទះភាគច្រើនគឺស្ត្រីជាអ្នកធ្វើ។ នេះបង្ហាញយ៉ាងច្បាស់ថា មានការបែងចែកតួនាទីច្បាស់លាស់រវាង បុរស និងស្ត្រី ហើយវាក៏ជាផ្នែកមួយនៃស្ថានភាពរបស់សហគមន៍ វប្បធម៌ និងប្រពៃណីរបស់ប្រជាពលរដ្ឋនៅទីនោះផងដែរ។ ដើម្បីលើកកំពស់សម្លេងរបស់ស្ត្រីនៅក្នុងដំណើរការនៃការចូលរួមធ្វើការសម្រេចចិត្តនៅក្នុងសហគមន៍ គឺតម្រូវឱ្យមានការសិក្សាស៊ីជម្រៅដើម្បីយល់ដឹងកាន់តែច្បាស់ថែមទៀត និងកំណត់ពីមធ្យោបាយ ផ្សេងៗដើម្បីពង្រីកការគាំទ្រសមស្រប និង ចំគោលដៅ។

## ៦.៤ ព្រៃឈើ

សំពាធដែលស្តែងចេញយ៉ាងច្បាស់លើធនធានព្រៃឈើសម្រាប់គោលដៅសេដ្ឋកិច្ចគឺ ដោយសារក្រុមហ៊ុន សម្បទានចំការឈើដាំ គម្រោងរ៉ែ និង គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជាគម្រោងទំនប់វារីអគ្គិសនី និងគម្រោងផ្លូវថ្នល់។ សំពាធទាំងនេះ មានសក្តានុពលក្នុងការរារាំងមិនអោយប្រជាពលរដ្ឋដកហូតធនធានធម្មជាតិ និងព្រៃឈើ ព្រមទាំងធនធានសំខាន់ៗផ្សេងទៀតសម្រាប់ជីវភាពរស់នៅ និង ប្រាក់ចំណូលរបស់ពួកគេ។

## ៦.៥ បញ្ហា និងការគំរាមកំហែងនានា

ផែនការគម្រោងទំនប់វារីអគ្គិសនីសំបូរបច្ចុប្បន្ន គឺកំពុងតែប៉ះពាល់ទៅដល់លក្ខខ័ណ្ឌសង្គម និងសេដ្ឋកិច្ច របស់ប្រជាពលរដ្ឋនៅក្នុងភូមិដែលបានធ្វើការស្រាវជ្រាវនៅក្នុងដំណាក់កាលចាប់ផ្តើមនេះ។ ច្បាស់ណាស់ដែលថា ការភ័យខ្លាច ការបារម្ភ អសន្តិសុខ និង ភាពមិនប្រាកដប្រជាកើតមានឡើងនៅក្នុងគ្រួសារនីមួយៗនៅក្នុងភូមិទាំងនេះ ហើយការព្រួយបារម្ភទាំងអស់នេះអាចធ្វើឱ្យមានស្ថានភាពមួយអាក្រក់ ប្រសិនបើបញ្ហានៃតម្លាភាព ការពិគ្រោះយោបល់សាធារណៈ និងការបង្ហាញព័ត៌មានមិនត្រូវបានដោះស្រាយឆាប់ៗនោះទេ។

ការបាត់បង់នានារបស់ប្រជាពលរដ្ឋ និងការបាត់បង់សក្តានុពលនៅក្នុងការអភិវឌ្ឍន៍ព្រមទាំងការបំផ្លាញ បរិស្ថាន និងជីវសាស្ត្រដោយមិនអាចវិលមករកភាពដើមវិញបាននោះ ក៏ព្រោះ

តែទំនប់វារីអគ្គិសនី ដូចនេះការបាត់បង់ទាំងអស់នេះគឺមិនអាចកាត់ថ្លៃ និងមិនអាចផ្លោះប្តូរដោយសំណងបាននោះទេ។ ជំនួសឱ្យការបាត់បង់នេះ វាអាចមានសក្តានុពលក្នុងការស្នើសុំឱ្យមានការបង្អាក់ដំណើរការធំៗដែលនាំឱ្យមានបញ្ហានៃភាពក្រីក្រ និងការអត់ឃ្លាន ដែលមានឥទ្ធិពលអាចធ្វើឱ្យមានបញ្ហាសង្គមយ៉ាងធំធេងដូចជា បញ្ហាសុខភាព សន្តិសុខស្បៀង បញ្ហាអត់ការងារធ្វើ បញ្ហាស្ថេភាពការចិញ្ចឹមជីវិត បញ្ហានៃការអប់រំ និងបញ្ហាផ្សេងទៀត។

## ៦.៦ គម្រោងអភិវឌ្ឍន៍នានា

គម្រោងអភិវឌ្ឍន៍ និង គម្រោងវិនិយោគផ្សេងៗតាមរយៈកម្មវិធី និងគម្រោងនានានៅក្នុងស្រុកសំបូរ គឺត្រូវបានរងផលប៉ះពាល់ដោយសារគម្រោងទំនប់វារីអគ្គិសនី។ ល័ក្ខខ័ណ្ឌនេះហើយដែលធ្វើឱ្យភូមិទាំងអស់នេះមានដំណើរការនៃការអភិវឌ្ឍន៍តិចបំផុត។ ជាងនេះទៅទៀតការវិនិយោគដែលមានស្រាប់នៃក្រុមហ៊ុនសម្បទានដែលដំណើរការនៅក្នុងព្រៃ ក្នុងស្រុកសំបូរ ក៏នឹងត្រូវរងផលប៉ះពាល់យ៉ាងខ្លាំងផងដែរ។

## ៧. អនុសាសន៍

បើតាមលទ្ធផលនៃការស្រាវជ្រាវនេះ គឺបានបញ្ជាក់ឱ្យឃើញថា ការទទួលបានព័ត៌មាន ការពិគ្រោះ យោបល់សាធារណៈ និងការចូលរួមរបស់សហគមន៍ក្នុងដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តនានាគឺមានសារៈសំខាន់ណាស់ដើម្បីរកជម្រើស និងដំណោះស្រាយផ្សេងៗលើការគំរាមកំហែង និងបញ្ហាក្នុងពេលបច្ចុប្បន្ន។ ខាងក្រោមនេះគឺជាអនុសាសន៍សម្រាប់សង្គមស៊ីវិល៖

**កិរិតសហគមន៍ ៖**

- ប្រឹក្សាយោបល់ជាបន្ទាន់ដល់សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីបង្ហាញព័ត៌មានច្បាស់ការណ៍ណាមួយ អំពីស្ថានភាពនៃផែនការគម្រោងទំនប់វារីអគ្គិសនីសំបូរ ដើម្បីបញ្ឈប់ការភ័យខ្លាចរបស់ប្រជាពលរដ្ឋ អសន្តិសុខ និងភាពមិនប្រាកដប្រជាព្រមទាំងក្នុងគោលបំណង ដើម្បីកាត់បន្ថយឥទ្ធិពលទៅដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងសហគមន៍។
- បង្កលក្ខណៈឱ្យសហគមន៍ចូលរួមការងារតស៊ូមតិនៅក្នុងថ្នាក់មូលដ្ឋាន ដើម្បីធ្វើឱ្យសាធារណៈជនអាចទទួលបានព័ត៌មានគ្រប់គ្រាន់ ការពិគ្រោះយោបល់សាធារណៈ និងការចូលរួមរបស់សហគមន៍។
- មានអង្គការមួយចំនួនឧទាហរណ៍ ដូចជាអង្គការអុកស្វាមដែលផ្តល់វគ្គបណ្តុះបណ្តាលទៅដល់ប្រជាពលរដ្ឋស្តីអំពីភាពធន់នឹងការប៉ះទង្គិច ដែលបណ្តាលមកពីការដំណើរការផ្លាស់ប្តូរនៃការអភិវឌ្ឍន៍ ឬគ្រោះមហន្តរាយផ្សេងៗ ឧទាហរណ៍ដូចជាទឹកជំនន់។ វាមានសារៈប្រយោជន៍ក្នុងការភ្ជាប់ជាមួយនឹងអង្គការទាំងនេះដើម្បីផ្តល់ការគាំទ្រសម្រាប់ប្រជាពលរដ្ឋនៅក្នុងស្រុកសំបូរ ឬលើសពីនេះទៀត។

**ករិតសង្គមស៊ីវិល ៖**

- បង្កើតការសិក្សាស៊ីជម្រៅទាក់ទងនឹងការចិញ្ចឹមជីវិតសម្រាប់បរិបទស្រុកសំបូរទាំងមូល និងក្រៅពីនេះ។ នៅក្នុងស្រុកសំបូរនេះមាន ឃុំ ចំនួន ១០ និង ភូមិ ចំនួន ៥២ ហើយក៏មានភូមិដែលមិនពឹងអាស្រ័យនឹងទឹកទន្លេផងដែរ ប៉ុន្តែអាចទទួលរងនូវឥទ្ធិពលអាក្រក់នេះដូចគ្នា។ នៅក្នុងភូមិនីមួយៗ មានលក្ខណៈពិសេសៗ ដោយឡែកៗពីគ្នា ដែលនេះតំរូវឱ្យមានការចងក្រងជាឯកសារលំអិតទៅតាមល័ក្ខខ័ណ្ឌនៃការប្រែប្រួលនានា។ ទាំងអស់នេះ ត្រូវតែរាប់បញ្ចូលឱ្យគ្រប់ជ្រុងជ្រោយ ព្រោះអ្វីៗទាំងនោះ គឺមានតម្លៃមិនអាចកាត់ថ្លៃបាន ហើយក៏មិនអាចដោះដូរដោយសំណងបានដែរ។ ឧបមាដូចជាការកំណត់ព្រំដែននៃការសិក្សានេះ គឺមិនបានបញ្ចូលចំពោះការសិក្សាទៅដល់ក្រុមគ្រួសារដែលក្រីក្របំផុត ហើយគ្រួសារទាំងនោះអាចនឹងត្រូវបានទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេបើប្រៀបទៅនឹងគ្រួសារដ៏ទៃទៀតនោះ។ ទាក់ទងទៅនឹងរយៈពេលនៃការធ្វើការសិក្សានេះ គឺជាការព្រួយបារម្ភមួយ។ ដូច្នេះរយៈពេលសមស្របទាក់ទងនឹងទំហំនៃការស្រាវជ្រាវគួរតែត្រូវយកមកពិចារណាផងដែរ។
- ការសិក្សាស៊ីជម្រៅដោយឡែកៗពីគ្នាស្តីពី ជលផល សម្បទានដីសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងព្រៃឈើ គឺជាប្រការមួយដ៏ប្រសើរដើម្បីគាំទ្រទៅដល់ការសិក្សាជីវភាពនេះឱ្យកាន់តែស៊ីជំរៅ។ ថ្មីៗនេះមានឯកសារ និង ការសិក្សាជាច្រើនទាក់ទងជាមួយនឹងវិស័យជលផល ហើយអាចរកបាននៅមជ្ឈមណ្ឌលត្រីពិភពលោក (World Fish Center) និង គណៈកម្មាធិការទន្លេមេគង្គ និង នៅស្ថាប័នផ្សេងៗទៀតដែលអាចយកមកចងក្រងជាឯកសារបាន។
- សេណារីយ៉ូ (scenario) ថ្ងៃអនាគតដែលនឹងមកដល់គឺ បញ្ហានៃការតាំងទីលំនៅដែលនឹងកើតមានឡើងនៅក្នុងស្រុកសំបូរ។ វាមានភាពប្រសើរបំផុតសម្រាប់សហគមន៍រងផលប៉ះពាល់ និង **សម្ព័ន្ធទន្លេកម្ពុជា** ក្នុងការរៀបចំយុទ្ធសាស្ត្រដើម្បីប្រឈមមុខទៅនឹងស្ថានភាពនេះ។ អនុសាសន៍មួយដែលមានសក្តានុពលនោះគឺការបង្កើតឱ្យមានការសិក្សាយ៉ាងប្រុងប្រយ័ត្ន ច្បាស់លាស់ និងស៊ីជម្រៅស្តីអំពី

បញ្ហានៃការតាំងទីលំនៅ ការផ្តល់ប្រាក់សំណង និងការកាត់បន្ថយឥទ្ធិពលគ្រោះថ្នាក់នៅក្នុងក្របខ័ណ្ឌច្បាប់មួយយ៉ាងច្បាស់លាស់ ហើយគួរតែធ្វើឱ្យបានឆាប់ជាទីបំផុត។ គម្រោងសំណើរសម្រាប់ការសិក្សានេះ គួរតែត្រូវបានបង្កើតឡើងពិចារណាឱ្យបានល្អិតល្អន់ពាក់ព័ន្ធទៅនឹង ពេលវេលា ទំហំ នៃការស្រាវជ្រាវ និងថវិកាផងដែរ។ ការសិក្សានេះនឹងក្លាយទៅជាឯកសារមួយដ៏ពេញនិយម និងមានសារៈសំខាន់សម្រាប់សង្គមស៊ីវិល និង ភ្នាក់ងារអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីប្រើប្រាស់នៅក្នុងករណីដែលស្ថានភាពប្រហាក់ប្រហែលគ្នានេះកើតឡើង។

- ជាងនេះទៅទៀត សង្គមស៊ីវិលត្រូវតែភ្ជាប់ខ្លួនទៅនឹងការងារតស៊ូមតិថ្នាក់ជាតិដោយគាំទ្រនូវគំនិតផ្តួចផ្តើមរបស់សហគមន៍ក្នុងការតស៊ូមតិថ្នាក់មូលដ្ឋាន។ សង្គមស៊ីវិលត្រូវរៀបចំដឹកនាំឱ្យមានការអត្ថាធិប្បាយណាមួយដែលទាក់ទងទៅនឹងទំនប់វារីអគ្គិសនី ព្រមទាំងបញ្ចុះបញ្ចូលអ្នកវិទ្យាសាស្ត្រ ដែលចាប់អារម្មណ៍លើរឿងនេះ និងភ្នាក់ងារអភិរក្សជីវៈចំរុះ ដូចជាមូលនិធិសង្គ្រោះសត្វព្រៃសាកល (WWF), សហព័ន្ធអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN), មជ្ឈមណ្ឌលត្រីពិភពលោក និងក្រុមអ្នកស្រាវជ្រាវសកលវិទ្យាល័យ ដើម្បីបង្កើតឱ្យមានជាវេទិកាដែលមានស្តង់ដាខ្ពស់ផ្សេងៗទាក់ទងទៅនឹងបញ្ហាទំនប់វារីអគ្គិសនីសំបូរនេះ។
- សង្គមស៊ីវិលគួរតែសហការ និងសម្របសម្រួលជាមួយនឹងក្រុមការងារថ្នាក់ជាតិថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដូចជាសម្ព័ន្ធការពារទន្លេមេគង្គ (Save the Mekong Coalition) ដើម្បីបង្កើតឱ្យមានការតស៊ូមតិមួយដ៏មានឥទ្ធិពលសម្រាប់ទំនប់វារីអគ្គិសនីសំបូរ។
- សង្គមស៊ីវិល ត្រូវបង្កើតឱ្យមានយុទ្ធនាការលើកកំពស់ការចូលរួមជាសាធារណៈ។ កម្ពុជាខ្វះប្រពៃណីនៃការចូលរួមសាធារណៈ ប៉ុន្តែការផ្សព្វផ្សាយជាសាធារណៈអាចមានសំពាធទៅលើរដ្ឋក្នុងការអនុវត្តច្បាប់ និង នយោបាយរបស់ខ្លួនឱ្យបានតឹងរឹង (មាត្រា ៣៥ នៃរដ្ឋធម្មនុញ្ញកម្ពុជា: ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា)។ អនុសាសន៍មួយទៀតគឺសូមឱ្យសង្គមស៊ីវិលធ្វើការភ្ជាប់ខ្លួនទៅនឹងការងារតស៊ូមតិថ្នាក់ខេត្ត ស្រុក និងឃុំ ផងដែរ។

**ក៏រិតអាជ្ញាធរ :**

- គប្បីបង្កើតគំនិតផ្តួចផ្តើមឱ្យមានដំណើរការនៃការពិគ្រោះយោបល់ផ្លូវការជាមួយនឹងអាជ្ញាធរ មូលដ្ឋាននានាដើម្បីឱ្យមានលំហូរព័ត៌មាននៅក្នុងថ្នាក់មូលដ្ឋាន និងលើកទឹកចិត្តអាជ្ញាធរទាំង នោះឱ្យមានការពិគ្រោះយោបល់ជាមួយសហគមន៍។
- ធ្វើឱ្យគោលនយោបាយ និងបទបញ្ញត្តិផ្សេងៗនៅក្នុងក៏រិតថ្នាក់ខេត្ត ស្រុក និងឃុំមានឥទ្ធិពល។ វាគឺមានសារៈសំខាន់ដែលគួរគប្បីធ្វើការត្រួតពិនិត្យឡើងវិញនឹងសិក្សាថាតើចំនុចអ្វីខ្លះដែលអាចធ្វើទៅបានក្នុងការធ្វើឱ្យគោលនយោបាយ និងបទបញ្ញត្តិផ្សេងៗនៅក្នុងក៏រិតថ្នាក់ខេត្តស្រុក និងឃុំមានឥទ្ធិពល។
- គប្បីអប់រំអាជ្ញាធរមូលដ្ឋានអំពីគោលគំនិតនៃការចូលរួម ព្រមទាំងលើកទឹកចិត្ត និងគាំទ្រពួកគេ ដើម្បីអនុវត្តដំណើរការនៃការធ្វើផែនការដោយមានការចូលរួម។ វាមានសារៈសំខាន់ស្មើគ្នាក្នុងការបង្កើតឱ្យមានការស្រាវជ្រាវ ទិន្នន័យមូលដ្ឋានស៊ីជម្រៅដើម្បីឱ្យមានទិន្នន័យច្បាស់លាស់ និងចាំបាច់ ដើម្បីធ្វើផែនការទៅថ្ងៃអនាគត ជាពិសេសដើម្បីស្វែងរកឱ្យឃើញនូវព័ត៌មានទាក់ទងទៅនឹងបញ្ហានៃជីវរូបសាស្ត្រដូចជាការចរាចរណ៍របស់ត្រី និងបញ្ហាពាក់ព័ន្ធជុំវិញនឹងជីវិតរបស់វារីជាតិ។
- អប់រំអាជ្ញាធរមូលដ្ឋានស្តីអំពីបទដ្ឋានគណៈកម្មការទំនប់វារីអគ្គិសនីពិភពលោក និងលើកកំពស់ រឺក៏បង្កើតយុទ្ធនាការដើម្បីធ្វើឱ្យមានការគោរពច្បាប់ និងការប្រកាន់ភ្ជាប់នូវច្បាប់ដែលបានចែង។ សង្គមស៊ីវិលគួរតែគាំទ្រទៅដល់អាជ្ញាធរមូលដ្ឋាន និងផ្តើមគំនិតឱ្យមានការចូលរួមអនុវត្តការងាររួមគ្នា។

# ៨. ឯកសារយោង

*A Study of the Downstream Impacts of the Yali Falls Dam in the Sesan River Basin in Ratanakiri Province, Northeast Cambodia*, 2000, Fisheries Office Ratanakiri Province and NTFP Project Ratanakiri Province.

*ADB Tonle Sap Sustainable Livelihoods Phase I TA CAM-4197*, 2004.

Asian Development Bank 2008, 'Building a Sustainable Energy Future the GMS'.

Asian Development Bank 2008, 'Economics of Energy Integration'.

Baird, I 2009, *Best Practices in Compensation and Resettlement for Large Dams: The Case of the Planned Lower SEsan 2 Hydropower Project in Northeastern Cambodia*.

Baran, E, et. al. 2009, *Dam and Fish: Impacts and Mitigation, Methods and Guidelines to Forecast, Assess and Mitigate the Impact of Hydropower Dams on Fish Resources on the Mekong Basin*, WorldFish Centre, Phnom Penh.

Bezuijen, MR, Timmins, R & Seng, T (eds) 2007, *Biological Surveys of the Mekong River Between Kratie and Stung Treng Towns, Northeast Cambodia, 2006-2007*, WWF, Phnom Penh.

Bezuijen, MR, Zanre, R & Goichot, M 2007, *The Don Sahong Dam and the Irrawaddy Dolphins, A Social Brief from WWF*, WWF, Vientiane.

CDRI 2002, *Working Paper 24, Land, Rural Livelihoods and Food Security Cambodia: A Perspective from Field Reconnaissance*, Phnom Penh, Cambodia.

Chan, S, Putrea, S, Sean, K & Hortle, KG undated, *Using Local Knowledge to Inventory Deep Pools, Important Fish Habitats in Cambodia*, Department of Fisheries, Provincial Office of Kratie, Phnon Penh.

'China Southern Power Grid to Invest in Cambodia's Hydropower Projects' 31 October 2006, *People's Daily*.

'Chinese Firm to Study Possible Mekong Dam Site' 5-6 May 2007, *Cambodia Daily*.

Chong, J 2005, *Technical Paper No.3, Valuing the Role of Aquatic Resources in Livelihoods: Economic Aspects of Community Wetland Management in Stung Treng Ramsar Site, Cambodia*, IUCN, Water, Nature and Economics.

CNMC & ADB 2010 '4P's River Workshop, Kratie province Cambodia' held on 18-20 January 2010 in Kratie province, Cambodia.

CNMC 2009, *Key SEA Framing Issues: Power demand and power trade development in the LMB and GMS Presentation*

CNMC & WorldFish Centre, 2007, Influence of Built Structures on Tonle Sap Fisheries –Findings and Recommendations, CNMC and WorldFish Centre, Phnom Penh, Cambodia

Deetes, P & Middleton, C 2009, *Upstream or Downstream, We All Have the Same Mother*.

Dove, V 2008, 'Investigating Neonatal Calf Mortalities in the Mekong River Irrawaddy Dolphin Population', Masters of Veterinary Studies in Conservation Medicine thesis, Murdoch University.

Dove, V 2009, *Mortality Investigation of the Mekong Irrawaddy River Dolphin (Orcaella Brevirostris) in Cambodia based on Necropsy Sample Analysis*, WWF, Cambodia.

Dove, V, Dove, D, Trujillo, F & Zanre, R 2008, *Abundance Estimation of the Mekong Irrawaddy Dolphin Oracaella Brevirostris Based on Mark and Recapture Analysis of Photo-Identified Individuals*, WWF, Cambodia.

Dugan, P 2008, 'Mainstream Dams as Barriers to Fish Migration: International Learning and Implications for the Mekong', *Catch and Culture*, vol. 14, no. 3.

Earthrights International, 2009, Mekong River Dams: National Laws to Address Environmental and Human Rights Issues, and Obstacles to Enforcement.

Friend, R 2009, 'Fishing for Influence: Fisheries Science and Evidence in Water Resources Development in the Mekong', *Water Alternatives*, vol. 2, no. 2, pp. 167-82.

*General Population Census of Cambodia 2008: National Final Census Report*, 2009, National Institute of Statistics, Ministry of Planning, Phnon Penh.

Helmers, K & Jegillos, S 2004, *Linkages Between Flood Drought Disaster and Cambodian Rural Livelihoods and Food Security: How can the CRC Community Disaster Preparedness Program further enhance livelihood and food security of Cambodian rural people in the face of natural disasters*, CDRI, Cambodia.

*http:///www.cambodiamirror.wordpress.com* accessed January 2010

http://cambodia.ohchr.org

http://www.cambodiamirror.wordpress.com accessed January 2010

http://www.cambodiaonline.net/articles2004117.htm accessed January 2010

http://www.elc.maff.gov.kh accessed January 2010

http://www.globalissues.org/news/2008/12/31/183

http://www.gsd.harvard.edu/~pollalis accessed January 2010

http://www.sithi.org accessed January 2010

http://www.unep.org/dams/documents accessed January 2010

http://ipsnews.net accessed January 2010

Huijbregts, R 1996, *Case Studies on BOT*, Delft University of Technology, Delft, The Netherlands.

IMF 2007, 'World Economic Outlook and Financial Surveys: Spillovers and Cycles in the Global Economy'.

Indigenous World 2007, International Workshop Group for Indigenous Affairs, Transaction Publisher, Copenhagen.

International Rivers & Rivers Coalition in Cambodia 2008, *Cambodia's Hydropower Development and China's Involvement.*

International Rivers 2006, *Mekong Under Threat: New Strategy Promotes Dams and Diversions.*

International Rivers 2009, 'Mekong Mainstream Dam: Threatening Southeast Asia's Food Security'.

Inter Press Service, 2008, "Environment-Cambodia: Opting for the Big Dam", http://www.globalissues.org/news/2008/12/31/183

JICA 2007, *The Master Plan Study of Hydropower Development in Cambodia,* JICA and Nippon Koei.

Joern Kristensen, 2001, *Food Security and Development in the Lower Mekong River Basin: A*
*Challenge for the Mekong River Commission*, Asia and Pacific Forum on Poverty: Reforming Policies and Institutions for Poverty Reduction, Asian Development Bank.

King, P, Bird, J & Hass, L 2007, *The Current Status of Environmental Criteria for Hydropower Development in the Mekong Region: A Literature Compilation*, Consultant Report to ADB, MRCS, WWF.

*Kingdom of Cambodia, National Religion King, Declaration of the Royal Government on Land Policy*, 2009.

*Kratie Province Investment Profile: The Gateway to Cambodia's Northeast,* 2008.

La, C 2007, 'The Sambor Dam: Potential Impacts of Relocation on Affected Island Communities', Earth Rights International.

LICADHO Nov. 2005, *Briefing Paper: Harmful Effects of Economic Land Concessions on Poor Cambodians.*

MAFF 2004, 'H.E. Chan Sarun, Minister, MAFF', *World Investment News and Far Eastern Economic Review*

Martonova, I (ed.) 2008, *Rethinking Investments in Natural Resources: China's Emerging Role in the Mekong Region*, Heinrich Boll Stiftung, Cambodia, WWF and International Institute for Sustainable Development.

McCallum, W 2008, *"Before the Dam" A Study of Environmental Impacts and Community Rights Community Rights Associated with the Constructions and Operation of the Approved Kirirom III Hydropower Scheme, Sre Ambel District, Southwest Cambodia*.

Menheere, Sebastiaan C. M., Spiro N. Pollalis, and Rick Huijbregts. 1996. *Case studies on build operate transfer / edited by Rick Huijbregts*. Delft, Netherlands: Delft University of Technology, Faculty of Architecture.

MIME & CNMC 2003, *Hydropower*, Mekong River Commission and Cambodia National Mekong Committee.

MRC SEA 2009, Key Framing Issues Presentations "Power Demand and Power Development in the LMB and GMS."

MRC & SEA, Vol. 11 2009. Hydropower on the Mekong Mainstream Inception Report: Mainstream Project Profile Summaries.

MRC 1998, 'Annual Report' Bangkok, Mekong Secretariat.

MRC 2001, MRC's Hydropower Development Strategy. Phnon Penh.

MRC 2002, Deep Pools as Dry Season Fish Habitats in the Mekong River Basin. Phnon Penh, Technical Paper No. 4.

MRC 2004, An Introduction to Cambodia's Inland Fisheries. Mekong Development Series No. 4, Phnom Penh, November 2004.

MRC 2005, Overview of the Hydrology of the Mekong Basin, Mekong River Commission, ISSN: 1728 3248, Vientiane, November 2005.

MRC 2007, Cambodia Baseline Data, 2007.

MRC 2008, "Fisheries Research and Development in the Mekong Region." Catch and Culture, (September).

MRC 2008, Cambodia Demographic Data.

MRC 2009, Basin Development Plan 2: Progress Report January - December 2009. MRC Secretariat. Vientiane, Lao PDR.

MRC 2009, BDP Phase 2 Progress Report January - December 2008. Vientiane, Laos.

Nette, A undated, 'Environment Cambodia: Opting For The Big Dam', *Inter-Press Service, http://www.ips.net*. Phnom Penh

NIS, 2009, Cambodia Socio-Economic Survey 2009, Phnom Penh, Cambodia

OHCHR, 2007. Economic Land Concessions in Cambodia: A Human Rights Prospective, Phnom Penh, Cambodia, June 2007.

Olsen, S undated, *Sub-Decree on Implementation of the Law on Concessions, The Kingdom of Cambodia.*

Oxfam Australia, 2007 Participatory Rural Appraisal Document for Sambor District, Kratie Province, Unpublished document.

Phan, P 2009, 'Energy Sector in Cambodia', PowerPoint Presentation presented to Seminar on Energy Development in The Greater Mekong Subregion, Intercontinental Hotel, Phnom Penh, Cambodia, 29 September 2009.

*Powering 21st Century Cambodia with Decentralised Generation: A Primer for Rethinking Cambodia's Electricity Future*, 2009, Phnom Penh.

*Procedures: issuing, revising, suspending, revoking or denying licenses, Electricity Authority of Cambodia*, 2002.

'Rare Cantor's Turtles Reappear, But Just Barely in Cambodia' 2007, 17 May, *International Herald Tribune*.

*Regional Civil Society Meeting on Lower Mekong Mainstream Dams*, 2007 September 12 -14,
Kratie, Cambodia.

*Regional Civil Society Meeting on Lower Mekong Mainstream Dams, Kratie*, Sept 2007, RCC and TERRA.

Royal Government of Cambodia 2001 (February 2), *NS/RKM/0201/ Electricity Law of the Kingdom of Cambodia*.

Royal Government of Cambodia 2007 (August 26), 'Legal Affairs Department. CIB/CDC Law on Concessions'.

Royal Government of Cambodia 2007 (March 20), 'Law on Fisheries Administration, Ministry of Agriculture, Fisheries, Forestry

Royal Government of Cambodia 2007, *Law on Water Resource Management of the Kingdom of Cambodia*, Royal Palace, Phnom Penh, Cambodia.

Royal Government of Cambodia 2007, *Legal Affairs Department CIB/CDC, Law on Concessions*.

Royal Government of Cambodia 2009 (July 1), *Declaration of the Royal Government on Land Policy*.

*Royal Government of Cambodia, Article 35 of Cambodia's Constitution*

Royal Kingdom of Cambodia 1996 (November 18), *NS-RKM-1296/36 Law on Environmental Protection and Natural Resource Management*.

Rutherford, J, Lazarus, K & Kelly, S 2008, *Rethinking Investments in Natural Resource: China's Emerging Role in the Mekong Region*.

Sarkkula, J, Keskinen, M, Kopenen, J, Kummu, M, Richey, J & VAris, O 2008, 'Mekong Hydropower and Fisheries - What are the Impacts', M-POWER Book 2.

Sophal, C 2009, 4 July - 6 July 'Doubts Over New Hydroelectric Dam', *Mekong Times*.

Starr, P 2008, 'Fisheries Research and Development in the Mekong Region', *Catch and Culture*, vol. 14, no. 2.

Swift, Peter.  2006, *Livelihoods in the Srepok River Basin in Cambodia: A Baseline Survey*. 3 S Protection Network, Cambodia

TACAM-4197 2004, *ADB Tonle Sap Sustainable Livelihoods Phase I*.

'Technical Symposium on Mekong Fisheries ', 2003, organized by the Mekong River Commission in Vientiane Laos.

TERRA, 2007. Sambor dam, Kratie province, Cambodia. Retrieved from http://www.terraper.org/articles/Sambor-TERRA%20Sept07.pdf

*The Mirror* 2008, vol. 12, no. 547, week 547.

Tiodolf, AM 2005, 'Limnological Study of the Sesan River in Cambodia: Focus on Toxic Algae', *STRIVER*.

UN 2007, *Economic Land Concessions in Cambodia: A Human Rights Perspectives*, Special Representatives of Secretary-General for Human Rights Cambodia.

Vannaren, C & Kin, S 2001, *Fisheries Presentation in the Mekong River Pools in Stung Treng and Kratie Province*. Unpublished report submitted to Cambodian Department of Fisheries

WWF 2007, *Addressing Environmental and Social Challenges Resulting from Large-Scale Agricultural Land Concessions in Cambodia and Laos, PDR*, WWF MPO and WWF GMPO - Cambodia and Laos Offices.

WWF, 2008, Biological Surveys on the Mekong River between Kratie and Stung Treng towns, northeast Cambodia, 2006-2007, WWF Greater Mekong-Cambodia Country Programme.

## ឧបសម្ព័ន្ធ : គំរូសំណួរណែនាំអំពីការស្រាវជ្រាវ

## ការចិញ្ចឹមជីវិតដែលពឹងអាស្រ័យលើទន្លេ : ការស្រាវជ្រាវទិន្នន័យមូលដ្ឋានសំណួរណែនាំអំពីការស្រាវជ្រាវសហគមន៍ស្រុកសំបូរ

ឈ្មោះភូមិ :

ឈ្មោះអ្នកផ្តល់ចម្លើយ :

កាលបរិច្ឆេទ :

| កំរងឯកសារភូមិ | |
|---|---|
| តើឈ្មោះភូមិរបស់អ្នកមានន័យដូចម្តេច? | |
| តើភូមិនេះកើតឡើងតាំងពីពេលណាមក? | |
| តើអ្នកស្នាក់នៅក្នុងភូមិនេះយូរប៉ុណ្ណាហើយ? | |

| | |
|---|---|
| តើមានប្រជាពលរដ្ឋប៉ុន្មានអ្នករស់នៅក្នុងភូមិនេះ? | |
| តើមានមនុស្សប្រុសប៉ុន្មានអ្នករស់នៅក្នុងភូមិនេះ? | |
| តើមានមនុស្សស្រីប៉ុន្មានអ្នករស់នៅក្នុងភូមិនេះ? | |
| ចំនួនគ្រួសារនៅក្នុងភូមិនេះមានប៉ុន្មាន? | |
| តើមានជនជាតិដើមភាគតិចរស់នៅក្នុងភូមិនេះទេ? | |
| តើជនជាតិដើមភាគតិចមានប៉ុន្មានប្រភេទ? | |
| តើពីភូមិទៅទីរួមខេត្តមានចំងាយប៉ុន្មាន? | |
| តើទំហំផ្ទៃដីសរុបក្នុងភូមិមានប៉ុន្មាន? | |
| តើភូមិនេះនៅក្នុងតំបន់អ្វី | |

| | |
|---|---|
| តើអ្នកមានផែនទីភូមិដែរឬទេ? (ផែនទីថតចម្លង) | |
| តើអ្វីដែលជាប្រភពចំណូលចំបងរបស់អ្នក? | |
| តើអ្នករកបានប៉ុន្មានក្នុងមួយខែៗ (សួររកទិន្នផលស្រូវ/ប្រសិនបានលក់) ប្រសិនបើមិនបានលក់តើយកវាទៅណា? | |
| តើអ្វីដែលជាប្រភពចំណូលបន្ទាប់បន្សំរបស់អ្នក? | |
| តើអ្នករកបានប៉ុន្មានក្នុងមួយខែៗ (ប្រសិនជាបានលក់)? តើយកលុយដែលរកបាននោះទៅប្រើប្រាស់ធ្វើអ្វីខ្លះ? | |
| តើអ្នកមានដីដែលជាកម្មសិទ្ធរបស់ខ្លួនដែររឺទេ? | |
| តើអ្នកដាំរុក្ខជាតិអ្វីខ្លះ? ហេតុអ្វីបានជាអ្នកដាំវា? | |
| តើអ្នកមានចិញ្ចឹមសត្វដែររឺទេ? | |

| | |
|---|---|
| តើអ្នកចិញ្ចឹមសត្វអ្វីខ្លះ? | |
| តើអ្នកលក់សត្វចិញ្ចឹមដែររឺទេ? បើលក់តើយកលុយទៅប្រើប្រាស់លើអ្វី? | |
| តើអ្នកលក់កំលាំងពលកម្មតាមរដូវកាលដែររឺទេ? | |
| លក់កំលាំងពលកម្មឱ្យអ្នកណា? ហើយបានតម្លៃប៉ុន្មាន? | |
| តើអ្នកមានប្រភេទកសិដ្ឋានដូចម្តេច? | |
| **បញ្ហានានាក្នុងការចិញ្ចឹមជីវិត** | |
| តើអ្នកមានការបារម្ភចំពោះប្រភពនៃការចិញ្ចឹមជីវិតរបស់អ្នកនាពេលបច្ចុប្បន្នដែររឺទេ? | |
| តើហេតុអ្វីបានជាអ្នកបារម្ភពីប្រភពនៃការចិញ្ចឹមជីវិតរបស់អ្នកនាពេលបច្ចុប្បន្ន? | |
| តើអ្នកមានគំនិតអ្វីក្នុងការដោះស្រាយបញ្ហានេះដែររឺទេ? | |

| **មូលដ្ឋានសេវាកម្មសង្គម** | |
|---|---|
| តើនៅក្នុងភូមិនេះមានសាលារៀនដែររឺទេ? | |
| ប្រសិនបើមាន តើមានគ្រូប៉ុន្មាននាក់នៅក្នុងសាលានេះ? | |
| តើសាលានៅឯណា? | |
| តើកូនរបស់អ្នកបានទៅរៀនដែររឺទេ? បើទៅតើហេតុអ្វី? បើមិនទៅតើហេតុអ្វី? | |
| តើកូនរបស់អ្នកមានមធ្យោបាយអ្វីក្នុងការធ្វើដំណើរទៅសាលា? ឧទាហរណ៍, ទូក,កង់... | |
| តើក្មេងនៅក្នុងភូមិនេះចូលរៀនដែររឺទេ? ប្រសិនបើមិនចូលរៀនតើហេតុអ្វី? | |
| តើមានភាគរយសរុប ឬក៏បាន់ស្មានទេសម្រាប់ចំនួនកូនសិស្សនៅក្នុងភូមិនេះ? (ក្មេងប្រុសប៉ុន្មាន, ក្មេងស្រីប៉ុន្មាន?) | |

| | |
|---|---|
| តើភូមិនេះមានមណ្ឌលសុខភាពដែររឺទេ? | |
| តើអ្នក និង អ្នកភូមិផ្សេងទៀតទៅមណ្ឌលសុខភាពដើម្បីពិនិត្យជំងឺដែររឺទេ? បើមិនទៅ<br>តើហេតុអ្វី? | |
| តើអ្នកទៅណានៅពេលដែលមានបញ្ហាសុខភាព? | |
| តើបញ្ហាសុខភាពជាចំបងដែលប្រជាពលរដ្ឋច្រើនជួបប្រទះគឺបញ្ហាអ្វី? | |
| **ធនធានព្រៃឈើ** | |
| តើពីភូមិទៅព្រៃមានចំងាយប៉ុន្មាន? | |
| តើអ្នកទទួលបានអ្វីខ្លះពីព្រៃឈើ ( អនុផលព្រៃឈើ ) ? | |
| តើការចូលព្រៃរកអនុផលព្រៃឈើអាចជួយដល់គ្រួសារដែររឺទេ?<br>ហើយបានលុយមកចំណាយលើអ្វីខ្លះ? | |

| | |
|---|---|
| តើអ្នកមានបញ្ហានៅក្នុងការចូលព្រៃដើម្បីប្រកបរបរចិញ្ចឹមជីវិតដែររឺទេ? | |
| តើបញ្ហាទាំងនេះគឺអ្វី? | |
| តើអ្វីដែលបណ្តាលឱ្យកើតជាបញ្ហានេះ? | |
| តើអ្នកមានគំនិតអ្វីដើម្បីដោះស្រាយបញ្ហានេះដែររឺទេ? | |
| តើអ្នកត្រូវការអ្វីខ្លះដើម្បីដោះស្រាយបញ្ហានេះ? | |
| តើអ្នកយល់អំពីច្បាប់ដែររឺទេ និងបទបញ្ញាផ្សេងៗទាក់ទងនឹងព្រៃឈើដែររឺទេ? | |
| បើសិនជាយល់ពីច្បាប់តើអាចឱ្យឧទាហរណ៍បានដែររឺទេ? | |
| ប្រសិនបើមិនយល់ពីច្បាប់ទាំងនោះ តើហេតុអ្វីបានជាមិនយល់? | |
| **ការអនុវត្តនីការដកហូតព្រៃឈើជាលក្ខណៈប្រពៃណី** | |

| | |
|---|---|
| តើអ្នកចូលព្រៃដែររឺទេ? បើចូលហេតុអ្វី? បើមិនចូលហេតុអ្វី? | |
| តើមានស្រែចំការនៅក្នុងព្រៃដែររឺទេ? តើអ្នកដាំអ្វីខ្លះ? ហូបចុកខ្លួនឯង រឺ លក់? | |
| តើអ្នកប្រើប្រាស់ព្រៃឈើជាលក្ខណៈប្រព្រៃណីយ៉ាងដូចម្តេច? | |
| តើមានអ្វីផ្លាស់ប្តូរទេមកដល់បច្ចុប្បន្ននេះ (ប្រៀបធៀបកាលពី ៥-១០ឆ្នាំមុន នឹងពេលបច្ចុប្បន្ន) | |
| តើអ្នកប្រមាញ់សត្វព្រៃដែររឺទេ? | |
| តើសត្វព្រៃអ្វីខ្លះដែលអ្នកតែងតែប្រមាញ់? | |
| តើសត្វដែលប្រមាញ់បានយកទៅណា? | |
| **ធនធានទឹក/ទន្លេ** | |

| | |
|---|---|
| តើមានប្រភពទឹក/ទន្លេ នៅក្បែរភូមិរបស់អ្នកដែររឺទេ? | |
| តើអ្នកប្រើទឹកទន្លេដែររឺទេ? ដើម្បីអ្វីខ្លះ? | |
| តើអ្នកអាចពិព័ណ៌នាអំពីស្ថានភាពទឹកទន្លេនេះកាលពី ៥-១០ឆ្នាំមុនដែររឺទេ?<br>(ឧទាហរណ៍ដូចជា : ល្បឿនលំហូរទឹក, អន្លង់ត្រី, វាលទឹកលិច, ដីខ្សាច់ ជាដើម)? | |
| តើវាមានភាពខុសគ្នាអ្វីខ្លះទៅនឹងស្ថានភាពទន្លេសព្វថ្ងៃនេះ (ទាំងបរិមាណ និង គុណភាព)? | |
| តើនៅពេលណាដែលទឹកទន្លេឡើងខ្ពស់? ហើយមានរយៈពេលប៉ុន្មាន?<br>ហើយឡើងប៉ុន្មានដងក្នុងមួយឆ្នាំ? | |
| តើសកម្មភាពរបស់ប្រជាពលរដ្ឋនៅកំឡុងពេលរដូវទឹកតំឡើងធ្វើអ្វីខ្លះ? (សួរពីបុរស និង<br>ស្ត្រី) | |
| តើនៅពេលណាដែលទឹកស្រកមកវិញ? មានរយៈពេលប៉ុន្មាន? ហើយប៉ុន្មានដងក្នុងមួយឆ្នាំ? | |

| | |
|---|---|
| តើសកម្មភាពរបស់ប្រជាពលរដ្ឋនៅកំឡុងពេលរដូវទឹកសំរកធ្វើអ្វីខ្លះ? (សួរពីបុរស និង ស្ត្រី) | |
| តើពេលណាដែលអ្នកចុះទៅនេសាទ និង<br>អាស្រ័យផលពីធនធានផ្សេងៗទៀតដែលបានមកពីទន្លេក្នុងមួយឆ្នាំៗ?<br>ហើយញឹកញាប់ប៉ុណ្ណាដែរ? | |
| តើអ្នកប្រើឧបករណ៍ប្រភេទអ្វីខ្លះដើម្បីនេសាទត្រី? | |
| តើអ្នកទទួលបានត្រីចំនួនប៉ុន្មានគីឡូក្រាមក្នុងពេលនេសាទមួយលើកៗ? | |
| តើអ្នកលក់ត្រីដែលនេសាទបានរឺក៏ទុកបរិភោគខ្លួនឯង?<br>បើសិនលក់ត្រីនោះតើបានមួយគីឡូប៉ុន្មាន? | |
| ក្រៅពីត្រីតើមានសត្វអ្វីផ្សេងទៀតដែលរស់នៅក្នុង និង ពឹងអាស្រ័យលើទន្លេ? ផ្សោត... | |
| តើអ្នកអាចរាប់ឈ្មោះប្រភេទសត្វដែលរស់នៅក្នុង និង ពឹងអាស្រ័យលើទន្លេបានដែររឺទេ? | |

| | |
|---|---|
| ហើយហេតុអ្វីបានជាទន្លេ មានសារៈសំខាន់សំរាប់សត្វទាំងនោះ? | |
| តើមានឧបសគ្គ រឺក៏បញ្ហាអ្វីទាក់ទងនឹងការប្រើប្រាស់ទឹកទន្លេដែររឺទេ? | |
| តាមអ្វីដែលអ្នកដឹងតើទន្លេងអាចប្រើដើម្បីធ្វើអ្វីផ្សេងទៀតបានដែររឺក៏យ៉ាងណា?<br>ដូចជាជាផ្លូវទឹកគមនាគមន៏, ជាកន្លែងសម្រាប់លំហែកាយ,<br>ការបង្កើតឳកាសផ្សេងៗទាក់ទងនឹងប្រពៃណី? | |
| តើការប្រើប្រាស់ខាងលើទាំងអស់នេះមានសារៈសំខាន់ដែររឺទេ? ហេតុអ្វី? | |
| **ការរៀបចំបង្កើត និង ការផ្លាស់ប្តូរ** | |
| តើអ្នកសំគាល់ឃើញថាមានការផ្លាស់ប្តូរទេនៅក្នុងទន្លេសម្រាប់រយៈពេល ៤-៥ឆ្នាំមុន?<br>មុន(៥-១០ឆ្នាំ)? តើវាខុសគ្នាយ៉ាងដូចម្តេចបើគិតមកដល់សព្វថ្ងៃនេះ? | |
| តើអ្នកអាចពិព័ណនាការផ្លាស់ប្តូរទាំងអស់នេះបានដែររឺទេ?<br>តើបានកើតរឿងនេះនៅពេលណាមក? តើវាកើតឡើង | |

| | |
|---|---|
| ញឹកញាប់ប៉ុណ្ណានៅក្នុងរយៈពេលនៃឆ្នាំ? | |
| តើបញ្ហាទាំងនេះអាចប៉ះពាល់ដល់អ្នក ក្រុមគ្រួសារ និង សហគមន៍ដែររឺទេ? | |
| តើអ្នកមានការបារម្ភណ៍ រឺក៏បញ្ហាអ្វីដែលអ្នកចង់និយាយដែររឺទេទាក់ទងទៅនឹងបញ្ហានេះ? | |
| តើមានគំនិតអ្វីខ្លះក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងខាងលើនេះ? | |
| តើអ្វីខ្លះដែលអ្នកគិតថាជាតម្រូវការក្នុងការគាំទ្រ? | |
| **ការចូលរួមយេនឌ័រ** | |
| តើស្ត្រីទៅនេសាទដែររឺទេ? តើដឹងថាគាត់រកបានប៉ុន្មានគីឡូក្រាមដែររឺទេក្នុងការទៅរកម្តង? | |
| តើកុមារទៅនេសាទដែររឺទេ? | |
| តើឧបករណ៍អ្វីដែលកុមារ និងស្ត្រីប្រើប្រាស់ក្នុងការនេសាទ? | |

| | |
|---|---|
| តើកន្លែងណាដែលស្ត្រី និង បុរសទៅនេសាទ? ឆ្ងាយប៉ុណ្ណាដែរ? | |
| តើអ្នកដឹងអំពីការងារផ្សេងៗទៀតដែលស្ត្រីធ្វើនៅក្នុងភូមិដែររឺទេ? | |
| **កសិកម្មតាមច្រាំងទន្លេ** | |
| តើមានសកម្មភាពការដាំដើមឈើចំការនៅតាមច្រាំងទន្លេនៅក្នុងភូមិរបស់អ្នកដែររឺទេ? | |
| តើអ្នកអាចពិពណ៌នាអំពីសកម្មភាពនេះបានដែររឺទេ (កសិកម្មតាមច្រាំទន្លេ)? | |
| តើអ្នកណាជាអ្នកធ្វើសកម្មភាពទាំងអស់នេះ? ហើយក្នុងគោលបំណងអ្វី? | |
| តើមានការផ្លាស់ប្តូរថ្មីៗទាក់ទងនឹងសកម្មភាពទាំងអស់នេះដែររឺទេ? | |
| តើអ្នកអាចពិពណ៌នាពីការផ្លាស់ប្តូរទាំងអស់នេះដែររឺទេ? | |
| តើអ្វីដែលធ្វើឱ្យមានការផ្លាស់ប្តូរទាំងអស់នេះ? | |

| | |
|---|---|
| តើការផ្លាស់ប្តូរទាំងអស់នេះធ្វើឱ្យប៉ះពាល់ដល់អ្នក, ក្រុមគ្រួសារ, និង សហគមន៍យ៉ាងដូចម្តេច? | |
| តើអ្នកគិតថាបញ្ហាទាំងអស់នេះអាចត្រូវបានដោះស្រាយដែររឺទេ? | |
| តើអាចដោះស្រាយបានក្នុងមធ្យោបាយណា? | |
| **សកម្មភាពទេសចរណ៍** | |
| តើមានសកម្មភាពទេសចរណ៍នៅក្នុងភូមិរបស់អ្នកដែររឺទេ? | |
| តើអ្នកអាចពិពណ៌នាអំពីសកម្មភាពទាំងអស់នេះបានដែររឺទេ? | |
| តើអ្នកបានពាក់ព័ន្ធនៅក្នុងការងារទេសចរណ៍នេះដែររឺទេ? | |
| តើសារៈប្រយោជន៍អ្វីខ្លះដែលអ្នកទទួលបានពីសកម្មភាពទេសចរណ៍នៅក្នុងភូមិ រឺក៏នៅជិតៗភូមិរបស់អ្នក? | |

| | |
|---|---|
| **បណ្ដាញអគ្គិសនី** | |
| តើផ្ទះអ្នកមានបណ្ដាញអគ្គិសនីប្រើប្រាស់ដែររឺទេ?<br>ប្រសិនបើគ្មានតើអ្នកប្រើអ្វីដើម្បីបំភ្លឺនៅពេលយប់? | |
| ប្រសិនបើមាន, តើគេភ្ជាប់ពីណាមក? ហើយគេចំណាយប៉ុន្មានក្នុងមួយខែៗ? | |
| តើអ្នកភូមិផ្សេងទៀតមានបណ្ដាញអគ្គិសនីប្រើប្រាស់ដែររឺទេ? ប្រសិនបើគ្មាន,<br>តើគេប្រើអ្វីនៅពេលយប់? | |
| ប្រសិនបើមាន, តើគេភ្ជាប់ពីណាមក? តើអ្នកដឹងដែររឺទេ<br>មានបណ្ដាញអគ្គិសនីចំនួនប៉ុន្មានក្នុងភូមិ? តើគេចំណាយ ប្រាក់អស់ប៉ុន្មានក្នុងមួយខែៗ? | |
| **ឧបសគ្គធំៗ និង ក្ដីបារម្ភនានានៅក្នុងភូមិ** | |
| តើអ្នកគិតថាអ្វីជាបញ្ហាចំបងដែលបានជួបប្រទះនៅក្នុងភូមិរបស់អ្នក? | |

| | |
|---|---|
| ហើយតើវាប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ អ្នកដែររឺទេ? | |
| តើអ្វីជាសេចក្តីបារម្ភទាក់ទងទៅនឹងឧបសគ្គទាំងអស់នេះ? | |
| តើអ្នកមានសំណូមពរអ្វីក្នុងការដោះស្រាយឧបសគ្គទាំងអស់នេះដែររឺទេ? | |

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**
អាសយដ្ឋាន : ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ: ២២៩៥ ភ្នំពេញ-៣ កម្ពុជា
ទូរស័ព្ទលេខ : (៨៥៥-២៣) ២១៤ ៤២៩
ទូរសារលេខ : (៨៥៥-២៣) ៩៩៤ ០៦៣
អ៊ីម៉ែល: **ngoforum@ngoforum.org.kh**
គេហទំព័រ: **www.ngoforum.org.kh**